**រាជរដ្ឋាភិបាលកម្ពុជា**

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

# ប្លង់មេរៀន

# ស្តីពី

# ការលើកកម្ពស់សេវាសង្គមប្រកបដោយសមធម៌

354.968
SOC
Sh. Training

library.ncdd.gov.kh
013526

**ខែតុលា ឆ្នាំ២០១២**

## មាតិកា

ការចាប់ផ្តើមវគ្គបណ្តុះបណ្តាល ៖ ........ ១

**ផ្នែកទី១ ៖ តម្រង់ទិស**

ប្លង់មេរៀនទី១ ៖ គោលវិធីវដ្តជីវិត និងសារៈសំខាន់នៃការវិនិយោគកុមារវ័យដំបូង........ ៥

ប្លង់មេរៀនទី២ ៖ ផលប៉ះពាល់នៃគ្រោះមហន្តរាយទៅលើការអភិវឌ្ឍកុមារ........ ១៣

ប្លង់មេរៀនទី៣ ៖ តួនាទី និងភារកិច្ចរបស់ គ.ក.ន.ក........ ២១

ប្លង់មេរៀនទី៤ ៖ ការប្រើប្រាស់ទិន្នន័យបង្កើនសមត្ថភាពកសាងផែនការ និងការចាត់អាទិភាព.... ២៥

ប្លង់មេរៀនទី៥ ៖ ការកសាងផែនការថវិកាផ្តោតលើសមធម៌ និងការកៀរគរធនធាន ........ ៣៧

ប្លង់មេរៀនទី៦ ៖ ការតាមដានត្រួតពិនិត្យ ការវាយតម្លៃ និងរបាយការណ៍........ ៤១

**ផ្នែកទី២ ៖ ការផ្តោតស៊ីជម្រៅលើសមធម៌សង្គម**

ប្លង់មេរៀនទី១ ៖ កិច្ចសហការជាមួយសហគមន៍ ដើម្បីត្រៀមបម្រុងសម្រាប់គ្រោះមហន្តរាយ និងការដោះស្រាយ........ ៤៥

ប្លង់មេរៀនទី២ ៖ ការថែទាំកុមារនៅជាមួយគ្រួសារ និងយន្តការគាំទ្រសហគមន៍ ........ ៥៦

ប្លង់មេរៀនទី៣ ៖ ការប្រើប្រាស់ទិន្នន័យ ដើម្បីឱ្យមានឥទ្ធិពលលើអ្នកដទៃ........ ៦២

ការសន្និដ្ឋានបញ្ចប់វគ្គបណ្តុះបណ្តាល ........ ៦៧

# ប្លង់មេរៀន

# ការចាប់ផ្តើមវគ្គបណ្តុះបណ្តាល

## ប្លង់មេរៀន

## ការចាប់ផ្ដើមវគ្គបណ្ដុះបណ្ដាល

| | |
|---|---|
| **គោលបំណង** | នៅចុងបញ្ចប់នៃមេរៀននេះសិក្ខាកាមនឹងអាច ៖<br>• បង្កើនទំនាក់ទំនងឱ្យកាន់តែល្អប្រសើររវាងអ្នកចូលរួម<br>• រៀបរាប់ពីគោលដៅ គោលបំណង និងកាលវិភាគរបស់វគ្គបណ្ដុះបណ្ដាល<br>• រំលឹកគោលការណ៍មួយចំនួនសម្រាប់អនុវត្តន៍ក្នុងវគ្គបណ្ដុះបណ្ដាល |
| **ខ្លឹមសារមេរៀន** | • គោលដៅ គោលបំណង និងកាលវិភាគរបស់វគ្គ<br>• គោលការណ៍សម្រាប់អនុវត្តន៍ |
| **រយៈពេល** | ៦០នាទី |
| **សម្ភារៈ** | • ក្រដាសផ្ទាំងធំ ក្រដាសពណ៌ ហ្វឺត ស្កុត និងកន្ត្រៃ<br>• គោលដៅ គោលបំណង និងកាលវិភាគនៃវគ្គបណ្ដុះបណ្ដាល |
| **វិធីសាស្ត្រ** | • ការបំផុសគំនិត<br>• បទបង្ហាញ |

**សកម្មភាពសម្របសម្រួលមេរៀន**

| **រយៈពេល** | **ជំហាន និងវិធីសាស្ត្រ** | **សម្ភារៈ** |
|---|---|---|
| ០៥ នាទី | **១. ការចុះឈ្មោះអ្នកចូលរួម**<br>• អ្នកសម្របសម្រួលត្រៀមជាស្រេចនូវបញ្ជីវត្តមាន និងសម្ភារៈសិក្សា<br>• អញ្ជើញអ្នកចូលរួមចុះវត្តមាន និងចែកសិក្សា | បញ្ជីវត្តមាន សិក្សា |
| ០៥នាទី | **២. ការបើកវគ្គបណ្ដុះបណ្ដាល**<br>• អ្នកសម្របសម្រួលគួររៀបចំសុន្ទរកថាជាស្រេចឬក៏ពិភាក្សាផ្ទាល់ជាមួយគណៈអធិបតីអំពីសកម្មភាពសំខាន់ៗនៃវគ្គបណ្ដុះបណ្ដាល ។<br>• អញ្ជើញគណៈអធិបតីឡើងថ្លែងសុន្ទរកថា | សុន្ទរកថា |
| ១០ នាទី | **៣. បង្ហាញសេចក្ដីផ្ដើម និងគោលបំណងមេរៀន**<br>• **សេចក្ដីផ្ដើម ៖** វគ្គតម្រង់ទិសនេះ ផ្ដោតទៅលើទិដ្ឋភាពរួមនៃការលើកកម្ពស់សេវាសង្គមប្រកបដោយសមធម៌ និងបញ្ហាផ្សេងៗ។ ដើម្បីទទួលបាននូវចំណេះដឹង និងជំនាញទាមទារឱ្យមានការចូលរួមក្នុងកិច្ចការនានាក្នុងមេរៀននីមួយៗ ឱ្យបានពេញលេញ។<br>• **បង្ហាញគោលបំណងមេរៀន ៖**<br>– បង្កើនទំនាក់ទំនងឱ្យកាន់តែល្អប្រសើររវាងអ្នកចូលរួម ។<br>– រៀបរាប់គោលដៅ និងគោលបំណង និងកាលវិភាគបណ្ដុះបណ្ដាល<br>– រំលឹកគោលការណ៍មួយចំនួនសម្រាប់អនុវត្តន៍ក្នុងវគ្គបណ្ដុះបណ្ដាល | |

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | សម្ភារៈ |
|---|---|---|
| ១៥នាទី | **៤. ការណែនាំឱ្យស្គាល់គ្នា**<br>• អ្នកសម្របសម្រួលអាចប្រើប្រាស់វិធីសាស្ត្រផ្សេងៗ ក្នុងការណែនាំឱ្យស្គាល់គ្នា ដើម្បីឱ្យស្គាល់ឈ្មោះ តួនាទី ទីកន្លែងធ្វើការងារ និងចំណង់ចំណូលចិត្ត...។ល។ | |
| ១០នាទី | **៥. ការរំពឹងទុក បទបង្ហាញគោលដៅ គោលបំណង និងកាលវិភាគ**<br>• អ្នកសម្របសម្រួលចែកសិក្ខាកាមជាគូៗ<br>• អ្នកសម្របសម្រួលចែកក្រដាសកាតពណ៌០២សន្លឹកក្នុង១ក្រុម(ពណ៌ផ្សេងគ្នា)<br>• ក្រុមនីមួយៗ សរសេរការរំពឹងទុកពីវគ្គ១សន្លឹក និង១ទៀតពីការបារម្ភ<br>• អ្នកសម្របសម្រួលប្រមូលបិទលើក្ដារខៀន ឬក្រដាសផ្ទាំងធំ រួចបូកសរុប<br>• អ្នកសម្របសម្រួលបង្ហាញគោលដៅ និងគោលបំណង និងកាលវិភាគ | គោលដៅ គោលបំណង និង កាលវិភាគ |
| ១០នាទី | **៦. ការកំណត់វិន័យ ឬគោលការណ៍សម្រាប់អនុវត្តក្នុងវគ្គ**<br>• អ្នកសម្របសម្រួលបង្ហាញវិន័យ ឬគោលការណ៍សម្រាប់អនុវត្តន៍ក្នុងវគ្គរួចស្នើ ឱ្យសិក្ខាកាមកែសម្រួលឡើងវិញ បើចាំបាច់ | |
| ១០នាទី | **៧. ការគ្រប់គ្រងថ្នាក់**<br>• ចែកសិក្ខាកាមជា ៣ក្រុម ដោយមួយក្រុមទទួលខុសត្រូវមួយថ្ងៃ<br>• ក្រុមនីមួយៗត្រូវតែទទួលខុសត្រូវក្នុងការ ៖<br>– រៀបចំថ្នាក់ពេញមួយថ្ងៃ<br>– គ្រប់គ្រងពេលវេលា<br>– ល្បែងថាមពល<br>– ជំនួយអ្នកសម្របសម្រួល(បើចាំបាច់) និង<br>– រំលឹកមេរៀនពេលព្រឹកថ្ងៃបន្ទាប់ | |
| ៥នាទី | **៨. ការសន្និដ្ឋានបញ្ចប់មេរៀន**<br>• សង្ខេបមេរៀន<br>• តើអ្នកបានរៀនចំណុចសំខាន់អ្វីខ្លះពីមេរៀននេះ? | |

## គោលដៅវគ្គ គោលបំណង និងកាលវិភាគរបស់វគ្គបណ្តុះបណ្តាល

**ក). គោលដៅវគ្គ ÷**

សិក្ខាកាមមានសមត្ថភាពក្នុងការរៀបចំផែនការសកម្មភាព និងថវិកា សម្រាប់លើកកម្ពស់សេវាសង្គមប្រកបដោយសមធម៌។

**ខ). គោលបំណងវគ្គ ÷** នៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាលនេះសិក្ខាកាមនឹងអាច ៖

- រៀបរាប់បានពីសារៈសំខាន់នៃការវិនិយោគកុមារតូច និងសារៈសំខាន់នៃការអភិវឌ្ឍកុមារក្នុងគ្រួសារ
- ពិពណ៌នាបានពីតួនាទី និងភារកិច្ចរបស់គ.ក.ន.កក្នុងការលើកកម្ពស់សេវាសង្គម ប្រកបដោយសមធម៌ និងត្រៀមបម្រុងសម្រាប់គ្រោះមហន្តរាយ
- ប្រើប្រាស់សូចនាករសំខាន់ៗ ដែលបានមកពីឧបករណ៍នានា ក្នុងការប្រមូលទិន្នន័យ ដើម្បីរៀបចំផែនការសកម្មភាព និងថវិកា ប្រកបដោយសមធម៌ និងឆ្លើយតបទៅ នឹងតម្រូវការរបស់ ស្ត្រី និងកុមារព្រម ទាំងជនដែលងាយរងគ្រោះ
- ប្រើប្រាស់ទម្រង់តាមដានត្រួតពិនិត្យ និងវាយតម្លៃ និងទម្រង់របាយការណ៍
- កំណត់បានបញ្ហាជាយុទ្ធសាស្ត្រ ដែលមានឥទ្ធិពលដល់ស្ត្រី និងកុមារងាយរងគ្រោះ នៅក្នុងសហគមន៍របស់ពួកគេ និងបង្កើតហេតុផលមួយដើម្បីស្វែងរកមតិគាំទ្រសម្រាប់ស្ត្រី និងកុមារដែលងាយរងគ្រោះ។

**គ). កាលវិភាគ**

| ពេលវេលា | ប្រធានបទ | អ្នកសម្របសម្រួល |
|---|---|---|
| | **ថ្ងៃទី១ ៖ ផ្នែកទី១** | |
| ០៧:៣០-០៨:០០ | ការចុះឈ្មោះ | |
| ០៨:០០-០៩:០០ | ការបើកវគ្គបណ្តុះបណ្តាល: កិច្ចស្វាគមន៍ និងសេចក្តីផ្តើម | |
| ០៩:០០-០៩:៣០ | មេរៀនទី១ : គោលវិធីវដ្តជីវិត និងសារៈសំខាន់នៃការវិនិយោគនៅវ័យដំបូង | |
| ០៩:៣០-០៩:៤៥ | **សម្រាកអាហារសម្រន់** | |
| ០៩:៤៥-១១:០០ | មេរៀនទី១ : គោលវិធីវដ្តជីវិត និងសារៈសំខាន់នៃការវិនិយោគនៅវ័យដំបូង | |
| ១១:០០-១១:៣០ | មេរៀនទី២ : ផលប៉ះពាល់នៃគ្រោះមហន្តរាយទៅលើការអភិវឌ្ឍកុមារ | |
| ១១:៣០-០២:០០ | **អាហារថ្ងៃត្រង់** | |
| ០២:០០-០៣:០០ | មេរៀនទី២ : ផលប៉ះពាល់នៃគ្រោះមហន្តរាយទៅលើការអភិវឌ្ឍកុមារ | |
| ០៣:០០-០៣:៣០ | មេរៀនទី៣ : តួនាទី និងគោលបំណងរបស់ គ.ក.ន.ក | |
| ០៣:៣០-០៣:៤៥ | **សម្រាកអាហារសម្រន់** | |
| ០៣:៤៥-០៥:០០ | មេរៀនទី៣ : តួនាទី និងគោលបំណងរបស់ គ.ក.ន.ក | |

| ពេលវេលា | ប្រធានបទ | អ្នកសម្របសម្រួល |
|---|---|---|
| **ថ្ងៃទី២៖ ផ្នែកទី១** | | |
| ០៧:៣០-០៨:០០ | មេរៀនទី៣ : តួនាទី និងគោលបំណងរបស់ គ.ក.ន.ក (ត) | |
| ០៨:០០-០៩:៣០ | មេរៀនទី៤ : ប្រើប្រាស់ទិន្នន័យ ដើម្បីបង្កើនសមត្ថភាពកសាងផែនការ និងចាត់អាទិភាព | |
| ០៩:៣០-០៩:៤៥ | **សម្រាកអាហារសម្រន់** | |
| ០៩:៤៥-១១:០០ | មេរៀនទី៤ : ប្រើប្រាស់ទិន្នន័យ ដើម្បីបង្កើនសមត្ថភាពកសាងផែនការ និងចាត់អាទិភាព | |
| ១១:០០-១១:៣០ | មេរៀនទី៥ : ការកសាងផែនការថវិកាផ្តោតលើសមធម៌ និងការកៀរគរធនធាន | |
| ១១:៤៥-០២:០០ | **សម្រាកអាហារថ្ងៃត្រង់** | |
| ០២:០០-០២:៣០ | មេរៀនទី៥ : ការកសាងផែនការថវិកាផ្តោតលើសមធម៌ និងការកៀរគរធនធាន | |
| ០២:៣០-០៣:៣០ | មេរៀនទី៦ : ការត្រួតពិនិត្យ ការវាយតម្លៃ និងរបាយការណ៍ | |
| ០៣:៣០-០៣:៤៥ | **សម្រាកអាហារសម្រន់** | |
| ០៣:៤៥-០៤:៣០ | មេរៀនទី៦ : ការត្រួតពិនិត្យ ការវាយតម្លៃ និងរបាយការណ៍ | |
| ០៤:៣០-០៥:០០ | ធ្វើរំលឹកឡើងវិញនូវមេរៀនថ្ងៃទី១ និងថ្ងៃទី២<br>• ធ្វើការឆ្លុះបញ្ចាំងថ្ងៃទី១ និងទី២<br>• បង្ហាញពីមាតិកា និងលទ្ធផលរំពឹងទុកថ្ងៃទី៣<br>ការឆ្លុះបញ្ចាំងលើការងាររបស់ គ.ក.ន.ក ជោគជ័យ និងការប្រឈម | |
| **ថ្ងៃទី៣៖ ផ្នែកទី២** | | |
| ០៧:៣០-០៩:០០ | មេរៀនទី១ : ការជួយសហគមន៍មុនពេល និងក្នុងអំឡុងពេលអាសន្ន | |
| ០៩:០០-០៩:៣០ | មេរៀនទី២ : ការថែទាំកុមារនៅជាមួយគ្រួសារ និងយន្តការគាំទ្រសហគមន៍ | |
| ០៩:៣០-០៩:៤៥ | **សម្រាកអាហារសម្រន់** | |
| ០៩:៤៥ -១០:៣០ | មេរៀនទី២ : ការថែទាំកុមារនៅជាមួយគ្រួសារ និងយន្តការគាំទ្រសហគមន៍ | |
| ១០:៣០-១១:៣០ | មេរៀនទី៣ : ការប្រើប្រាស់ទិន្នន័យដើម្បីមានឥទ្ធិពលលើអ្នកដទៃ | |
| ១១:៣០-០២:០០ | **សម្រាកអាហារថ្ងៃត្រង់** | |
| ០២:០០-០៣:៣០ | មេរៀនទី៣ : ការប្រើប្រាស់ទិន្នន័យដើម្បីមានឥទ្ធិពលលើអ្នកដទៃ | |
| ០៣:៣០-០៣:៤៥ | **សម្រាកអាហារសម្រន់** | |
| ០៣:៤៥-០៣:៤៥ | បិទវគ្គ | |

# ផ្នែកទី១

# វគ្គតម្រង់ទិស

# ប្លង់មេរៀនទី១

# គោលវិធីវដ្តជីវិត និងសារៈសំខាន់នៃការវិនិយោគកុមារវ័យដំបូង

## ប្លង់មេរៀនទី ១

## គោលវិធីវដ្តជីវិត និងសារៈសំខាន់នៃការវិនិយោគកុមារវ័យដំបូង

| | |
|---|---|
| **គោលបំណង** | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹងអាច៖<br>• ពិព័ណនាបានពីភាពខុសៗគ្នានៅក្នុងដំណាក់កាលនីមួយៗនៃវដ្តជីវិត<br>• ពិព័ណនាបានពីសារៈសំខាន់នៃការវិនិយោគនៅក្នុងដើមឆ្នាំដំបូង<br>• រៀបរាប់បានពីអត្ថន័យសេវាសង្គមប្រកបដោយសមធម៌<br>• វិភាគបានទៅលើចំណុចនៃការអភិវឌ្ឍក្នុងដំណាក់កាលនីមួយៗ នៃវដ្តជីវិត រួមមាន ៖ តម្រូវការ បញ្ហាផ្សេងៗ និងការទទួលខុសត្រូវរបស់ គ.ក.ន.ក។ |
| **ខ្លឹមសារមេរៀន** | ១. សារៈសំខាន់នៃការវិនិយោគកុមារតូចនៅក្នុងដើមឆ្នាំដំបូង<br>២. វិធីសាស្ត្រគ្រប់ជ្រុងជ្រោយទៅលើការអភិវឌ្ឍកុមារ<br>៣. តម្រូវការរួមរបស់កុមារ<br>៤. អ្វីទៅជាសមធម៌ និងហេតុអ្វីបានជាផ្តោតទៅលើសមធម៌<br>៥. តួនាទី គ.ក.ន.ក ក្នុងការវិភាគពី បញ្ហា តម្រូវការ និងការទទួលខុសត្រូវ |
| **រយៈ ពេលសរុប** | ១៥៥ នាទី |
| **សម្ភារៈចាំបាច់** | ប៊ិចហ្វឺត កាតពណ៌ ក្រដាសផ្ទាំងធំ សៀវភៅណែនាំសម្រាប់សមាជិក គ.ក.ន.ក ផ្នែកទី១មេរៀនទី ១ ទំព័រ ១ដល់ទី ៨ |
| **វិធីសាស្ត្រ** | ពិភាក្សាក្រុមតូច ពិភាក្សាក្រុមធំ ការធ្វើបទបង្ហាញ និងពិពណ៌ព័ត៌មាន។ |

**សកម្មភាពសម្របសម្រួលមេរៀន៖**

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | សម្ភារៈ |
|---|---|---|
| ១៥ នាទី | **១. បទបង្ហាញពីសេចក្តីផ្តើម និងគោលបំណងនៃមេរៀន**<br>**ក). សំណួរបំផុស និងបទបង្ហាញ**<br>អ្នកសម្របសម្រួលផ្តើមសេចក្តីដោយនិយាយប្រយោគខាងក្រោម៖ លោក លោកស្រី បានដឹងហើយថាការងាររបស់គ.ក.ន.ក គឺផ្តោតទៅលើស្ត្រី និងកុមារ។ ដូច្នេះដើម្បីបំពេញការងារឱ្យមានប្រសិទ្ធភាព លោក លោកស្រី ត្រូវដឹងពីបញ្ហានានា ដែលអាចកើតមាន និងអាចរាំងដល់ការអភិវឌ្ឍនៅក្នុងដំណាក់កាលនីមួយៗនៃវដ្តជីវិតជាពិសេសដំណាក់កាលដំបូង។<br>• អ្នកសម្របសម្រួលបន្ទាប់មកធ្វើការពន្យល់ទៅលើគោលបំណងនៃមេរៀនដូចខាងក្រោម ៖<br>– ពិព័ណនាបានពីភាពខុសៗគ្នានៅក្នុងដំណាក់កាលនីមួយៗនៃវដ្តជីវិត<br>– ពិព័ណនាបានពីសារៈសំខាន់នៃការវិនិយោគនៅក្នុងដើមឆ្នាំដំបូង<br>– រៀបរាប់បានពីអត្ថន័យសេវាសង្គមប្រកបដោយសមធម៌<br>– វិភាគបានទៅលើចំណុចនៃការអភិវឌ្ឍ រួមមាន តម្រូវការបញ្ហា | |

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | សម្ភារៈ |
|---|---|---|
| | ផ្សេងៗ និងការទទួលខុសត្រូវរបស់ គ.ក.ន.ក ក្នុងការកសាងផែនការសកម្មភាពសេវាសង្គមប្រកបដោយសមធម៌។<br><br>**កំណត់សម្គាល់**<br>នៅក្នុងមេរៀននេះ យើងនឹងពិភាក្សាពីវដ្តជីវិតនៃការអភិវឌ្ឍពីសារៈសំខាន់នៃការវិនិយោគនៅវ័យដំបូង និងពីអត្ថន័យនៃការផ្តល់សេវាសង្គមប្រកបដោយសមធម៌។ បន្ទាប់មកយើងនឹងដកស្រង់គំនិតទាំងអស់នោះ ទៅធ្វើការវិភាគពីតម្រូវការ និងបញ្ហានានា ដែលប៉ះពាល់ទៅដល់ស្ត្រី និងកុមារនៅដំណាក់កាលផ្សេងៗនៃវដ្តជីវិត ព្រមទាំងកំណត់ពីការទទួលខុសត្រូវនានារបស់ គ.ក.ន.ក ដែលអាចធ្វើទៅបាន។ មេរៀននេះជួយសិក្ខាកាមឱ្យកាន់តែយល់ច្បាស់អំពីវិធីសាស្ត្រនៃវដ្តជីវិត ការគាំពារ និងការអភិវឌ្ឍកុមារតូច និងរបៀប ដែលសមាជិក គ.ក.ន.ក ធ្វើការគាំទ្រទៅដល់ស្ត្រី និងកុមារ នៅក្នុងឃុំរបស់អ្នក។ | គោលបំណងមេរៀន |
| ៤៥ នាទី | **២. គោលវិធីវដ្តជីវិត និងសារៈសំខាន់នៃការវិនិយោគកុមារវ័យដំបូង**<br>**២.១. ទស្សនៈរួមនៃវដ្តជីវិត**<br><br>**ក). សំណួរបំផុស ៖ តើអ្វីទៅគឺជាគោលវិធីវដ្តជីវិត?**<br>• អ្នកសម្របសម្រួលសួរ សំណួរបំផុសគំនិតទៅក្រុមធំថា តើវដ្តនៃជីវិតបែក ចែកជាប៉ុន្មានដំណាក់កាល? ដំណាក់កាលនីមួយៗត្រូវការអ្វីខ្លះ? តើអាចមានបញ្ហាប្រឈមអ្វីខ្លះ ក្នុងដំណាក់កាលនីមួយ?<br>• អ្នកកត់ត្រាត្រូវកត់ត្រាចម្លើយរបស់សិក្ខាកាមនៅលើក្រដាសធំ<br>• អ្នកសម្របសម្រួលបង្ហាញនិយមន័យគោលវិធីវដ្តជីវិត និងឧទាហរណ៍ ៖ ក្នុងដំណាក់កាលនីមួយៗ។<br><br>ចំណាំ៖ អ្នកសម្របសម្រួលបញ្ជាក់ថា តម្រូវការ បញ្ហា និងការអន្តរាគមន៍ក្នុងដំណាក់កាលនីមួយៗ នឹងយកទៅពិភាក្សាលម្អិតបន្ថែមទៀត<br><br>**ខ). ពន្យល់ពាក្យ**<br>• ការអភិវឌ្ឍរបស់កុមារពី(-៩ខែ) ដល់៥ឆ្នាំ មានន័យថា ជារយៈពេលដែលកុមារអភិវឌ្ឍន៍ចាប់តាំងពីពេលក្នុងផ្ទៃម្តាយរយៈពេលជាង៩ខែរហូតដល់ពេលអាយុ៥ឆ្នាំ។<br><br>**២.២. គោលវិធីចម្រុះទៅលើការអភិវឌ្ឍកុមារ**<br>**ក). បង្ហាញរូបភាព និងពន្យល់ខ្លឹមសារ**<br>• អ្នកសម្រួលសម្រួលចាប់ផ្តើមបង្ហាញ រូបភាព គោលវិធីចម្រុះទៅលើការអភិវឌ្ឍកុមារ ព្រមទាំងពន្យល់បន្ថែមនូវខ្លឹមសារដូចជា ៖ នៅក្នុងរូបភាព | |

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | សម្ភារៈ |
|---|---|---|
| | នៃការអភិវឌ្ឍទាំង ៥ផ្នែកនេះមានសារៈសំខាន់ណាស់ចំពោះកុមារ ហើយចំណុចទាំងអស់នេះមិនអាចបំបែកចេញពីគ្នាបានទេ។ | |

**ឧទាហរណ៍៖**

បើសិនជាកុមារអាយុ៧ឆ្នាំញ៉ាំតែបបរសជម្មតានោះកុមារមិនបានទទួលប្រភេទអាហាររូបត្ថម្ភដ៏ត្រឹមត្រូវទេ(តម្រូវការខាងរាងកាយ) វាអាចធ្វើឱ្យការអភិវឌ្ឍផ្នែកស្មារតីរបស់កុមារនេះមានភាពយឺតយ៉ាវ។ កុមារដែលមិនត្រូវបានទទួលការគាំទ្រផ្នែកស្មារតី និងការស្រលាញ់បីបាច់ ថែរក្សាអាចធ្វើឱ្យការសិក្សាជួបការលំបាក។

វិធីសាស្ត្រគ្រប់ជ្រុងជ្រោយទៅលើការអភិវឌ្ឍកុមារ នឹងពិចារណាគ្រប់ជ្រុងជ្រោយទៅលើតម្រូវការទាំងអស់របស់កុមារ។

**កំណត់ចំណាំ៖**

អ្នកសម្របសម្រួលអាចចម្លងខ្លឹមសារការអភិវឌ្ឍចម្រុះដាក់លើក្រដាសផ្ទាំងធំ និងបិទនៅជញ្ជាំង។

**២.៣ ហេតុអ្វីបានជាត្រូវវិនិយោគកុមារនៅវ័យដំបូង?**

**ក). សំណួរបំផុស**

- តើលោក លោកស្រីភាគច្រើនមានកុមារតូចៗនៅក្នុងផ្ទះ តើលោក លោកស្រីបានធ្វើអ្វីខ្លះដើម្បីពួកគេ?
- ហេតុអ្វីបានជាត្រូវវិនិយោគកុមារនៅវ័យដំបូង?
  - អ្នកសម្របសម្រួលចែកក្រដាសកាតពណ៌ឱ្យសិក្ខាកាមម្នាក់ៗ
  - អ្នកសម្របសម្រួលឱ្យសិក្ខាកាមពិភាក្សាជាក្រុមតូចពីរនាក់ៗ
  - សិក្ខាកាមសរសេរលើក្រដាសពណ៌នូវចម្លើយ ដែលពួកគេពិភាក្សាមួយក្រដាសកាតមួយគំនិត
  - អ្នកសម្របសម្រួលឱ្យសិក្ខាកាមអាន រួចអ្នកសម្របសម្រួលបូកសរុបដាក់លើក្រដាសផ្ទាំងធំ
  - អ្នកសម្របសម្រួលធ្វើការបូកសរុប និងបង្ហាញ ការវិនិយោគកុមារនៅវ័យដំបូងដែលវាមានសារៈ ប្រយោជន៍ក្នុងវិធីកាន់តែមានប្រសិទ្ធភាព និងទទួលលទ្ធផលខ្ពស់។

**ខ). សេចក្តីសង្ខេប ៖**

- អ្នកសម្របសម្រួលនឹងធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបដូចខាងក្រោម៖ ការគាំពារ និងការអភិវឌ្ឍកុមារតូចគឺមានសារៈសំខាន់ខ្លាំងណាស់។ ការទទួលអាហាររូបត្ថម្ភមិនគ្រប់គ្រាន់ចំពោះកុមារតូច គឺជាបញ្ហាដ៏ធំនៅក្នុង

| រយៈពេល | ដំណាក់ និងវិធីសាស្ត្រ | សម្ភារៈ |
|---|---|---|
| | ប្រទេសកម្ពុជា។ ៤៤% នៃកុមារអាយុក្រោម៥ឆ្នាំកើតជំងឺក្រិន (អាយុពួកគេក៏ខ្លីផងដែរ) កង្វះរបបអាហារ និងការផ្ដល់អាហារមិនបានគ្រប់គ្រាន់ ការបំបៅ ដោះកូនមិនបានត្រឹមត្រូវ ការឆ្លងជំងឺរាំរ៉ៃ និងកង្វះការយកចិត្តទុកដាក់ក្នុងដំណាក់កាលនេះ នាំឱ្យប៉ះពាល់ដល់ការអភិវឌ្ឍពេញលេញរបស់កុមារ និងអាចជះផលជាអវិជ្ជមានថែមទៀត ដល់ពួកគេនាពេលអនាគតដូចជា ៖ បញ្ហាសុខភាពទន់ខ្សោយ អវិជ្ជា និងភាពក្រីក្រដែលនៅភ្ជាប់ជា មួយពួកគេរហូតដល់ពេញវ័យ។<br>• ដូច្នេះវាមានសារៈសំខាន់ណាស់សម្រាប់ គ.ក.ន.ក ត្រូវធ្វើការផ្ដោតទៅលើការគាំពារ និងការអភិវឌ្ឍកុមារតូច ដើម្បីជួយឱ្យសមាជិកសហគមន៍ក្នុងការយល់ដឹងពីតម្រូវការ ក្នុងការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការគាំពារ និងការអភិវឌ្ឍកុមារតូច ចាប់តាំងពីដំណាក់កាលលូតលាស់ដំបូងរហូតដល់អាយុ៦ឆ្នាំ។ ការវិនិយោគនៅក្នុងវ័យដំបូង គឺជាកត្តាដែលធ្វើឱ្យមានសមភាពបំផុតក្នុងការកាត់បន្ថយនូវគម្លាតផ្នែកសេដ្ឋកិច្ច និងបង្ការកើនឡើងនៃគម្លាតនេះ។<br>• មុនពេលចូលទៅផ្នែកបន្ទាប់ អ្នកសម្របសម្រួល ប្រាប់អ្នកចូលរួមមើលទៅលើឯកសារយោងនៃអាហាររូបត្ថម្ភនៅក្នុងឯកសារជំនួយស្មារតី។ | |
| ៣០ នាទី | **៣. សេវាសង្គមប្រកបដោយសមធម៌**<br>**ក). តើអ្វីទៅគឺជាសមធម៌?**<br>**បំផុសគំនិត និងលំហាត់ ៖**<br>• អ្នកសម្របសម្រួលឱ្យសិក្ខាកាមលើកឧទាហរណ៍។ ហើយធ្វើការកត់ចំណាំដោយប្រុងប្រយ័ត្ន និងប្រាកដថាគឺមិនមានការច្រលំជាមួយនឹងសមភាពឡើយ។<br>• អ្នកសម្របសម្រួលបង្ហាញនិយមន័យ។ អ្នកសម្របសម្រួលអាចធ្វើលំហាត់១.១ បើសិក្ខាកាមមិនទាន់យល់ច្បាស់ពីអត្ថន័យសមធម៌ ត្រូវសួរសិក្ខាកាមពីប្រយោគដែលបានអាន តើអ្វីជាសមភាព ឬសមធម៌?<br>**សមភាព** ៖ ភាពស្មើគ្នា មិនថាធំ ឬតូច មាន ឬក្រ<br>**សមធម៌** ៖ យុត្តិធម៌ អ្នកក្រក៏ទទួលបានសេវា អ្នកមានក៏ទទួលបាន។ ដោយសារតែអ្នកមានលទ្ធភាពទទួលសេវា គ.ក.ន.ក ក៏ដូចជា អាជ្ញាធរមូលដ្ឋាន ត្រូវយកចិត្តទុកដាក់ទៅលើក្រុមប្រជាពលរដ្ឋក្រីក្រ ឬក្រុមដែលងាយរងគ្រោះ ធ្វើបែបណាឱ្យពួកគេទទួលបានសេវាសុខភាព និងសេវាផ្សេងៗ ទៀតដូចជាអប់រំ។ | |

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | សម្ភារៈ |
|---|---|---|
| | ខ). ហេតុអ្វីបានជាត្រូវឱ្យមានសមធម៌?<br>**បទបង្ហាញពីសារៈសំខាន់នៃសមធម៌**<br>• អ្នកសម្របសម្រួលបង្ហាញពីសារៈសំខាន់នៃសមធម៌ និងបញ្ជាក់ពីឫសគល់នៃបញ្ហាអសមធម៌ចេញមកពីកត្តាក្រីក្រ។<br>• បន្ទាប់មក អ្នកសម្របសម្រួលនិយាយថា ការផ្តល់សេវាសង្គមប្រកបដោយសមធម៌មានន័យថាផ្តោតទៅលើប្រជាជនដែលងាយរងគ្រោះ។<br>• អ្នកសម្របសម្រួលសួរសំណួរបន្ថែមថា ៖ តើយើងអាចដឹងថាអ្នកទាំងនោះជាជនដែលងាយរងគ្រោះ ដោយរបៀបណាដែរ?<br>• បន្ទាប់មក តាមការកំណត់ពីគ្រួសារដែលងាយរងគ្រោះ ដើម្បីធ្វើការយល់ដឹងទៅលើអត្ថន័យនៃគ្រួសារដែលងាយរងគ្រោះ ព្រមទាំងរបៀប ដែលអាចជួយឱ្យ គ.ក.ន.ក នៅតំបន់គោលដៅងាយស្រួល ក្នុងការអនុវត្តសកម្មភាពរបស់ខ្លួនផ្សេងៗ។<br>– ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា បានឱ្យនិយមន័យទៅលើកុមារដែលងាយរងគ្រោះ<br>– ក្រសួងផែនការ និតិវិធីនៃអត្តសញ្ញាណប័ណ្ណក្រីក្រ សម្រាប់ធ្វើការកំណត់គ្រួសារក្រីក្រ។<br>**កំណត់ចំណាំ ៖**<br>– យោងទៅឯកសារជំនួយស្មារតី ស្តីពី ប័ណ្ណគ្រួសារក្រីក្រ និងផែនទីសេវាសង្គម។<br>– រំលឹកសិក្ខាកាមអំពីសារៈប្រយោជន៍នៃទិន្នន័យដែលអាចប្រើប្រាស់បាននៅក្នុងទិន្នន័យឃុំ។<br>• ចុងបញ្ចប់អ្នកសម្របសម្រួលនឹងផ្តល់ឱ្យសិក្ខាកាមនៅពេលវេលាដ៏សមរម្យ ដើម្បីសួរសំណួរ ក៏ដូចជាការបញ្ជាក់ផ្សេងៗឱ្យកាន់តែច្បាស់មុននឹងចូលទៅផ្នែកមួយទៀត។ | |
| ១ ម៉ោង | **៤. លំហាត់ការពិពណ៌នាលទ្ធផលពិភាក្សា**<br>• អ្នកសម្របសម្រួលចាប់ផ្តើមពន្យល់គោលបំណងនៃការពិភាក្សា៖ ការពិភាក្សានេះ នឹងផ្តល់ឱ្យអ្នកទាំងអស់គ្នានូវឱកាសដើម្បីធ្វើការអនុវត្តវិភាគពីការលូតលាស់ តម្រូវការ និងបញ្ហាផ្សេងៗនៃដំណាក់កាលនីមួយៗ និងព្រមទាំងធ្វើការពិភាក្សា តើវិធីណាដែល គ.ក.ន.ក អាចធ្វើការឆ្លើយតបទៅនឹងបញ្ហាដែលបានរកឃើញ។<br>**ការពិភាក្សាក្រុមតូច ៖**<br>• អ្នកសម្របសម្រួលបែងចែកសិក្ខាកាមជា៤ក្រុម ទៅតាមដំណាក់កាល | |

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | សម្ភារៈ |
|---|---|---|
| | នីមួយៗ នៃវដ្តជីវិត។<br>– ចាប់តាំងពីការលូតលាស់ដំបូង ទៅ អាយុ៥ឆ្នាំ (វ័យដំបូង)<br>– ៦ ទៅ ១២ឆ្នាំ (បឋមវ័យ)<br>– ១៣ ទៅ ១៨ឆ្នាំ (វ័យជំទង់)<br>– មនុស្សពេញវ័យ<br>• អ្នកសម្របសម្រួល និងផ្តល់ជូនជាឧទាហរណ៍ ដែលធ្វើការបង្ហាញពីការវិភាគពីបញ្ហា នៃដំណាក់កាលនីមួយៗ ព្រមទាំងធ្វើការកំណត់រកឱ្យឃើញពីការទទួលខុសត្រូវរបស់សមាជិក គ.ក.ន.ក។<br>• ក្រុមនីមួយៗនឹងធ្វើតាមឧទាហរណ៍នៃទម្រង់ដែលបានបង្កើតនៃបទពិសោធន៍ បញ្ហា និងការទទួលខុសត្រូវរបស់ គ.ក.ន.ក ព្រមទាំងសរសេរចម្លើយដាក់នៅលើក្រដាសផ្ទាំងធំ។<br>• នៅពេលដែលក្រុមពិភាក្សាចប់ អ្នកសម្របសម្រួលស្នើសុំទៅអ្នកចូលរួមដើម្បីធ្វើការបង្ហាញលទ្ធផលដែលបានវិភាគដោយការដើរមើលជុំវិញតាមក្រុមនីមួយៗ<br>• ក្នុងខណៈពេលដែលដើរមើល អ្នកសម្របសម្រួលនឹងលើកឡើងនូវបញ្ហាមួយចំនួន និងការទទួលខុសត្រូវរបស់ គ.ក.ន.ក ដើម្បីជានាថាកិច្ចពិភាក្សានោះ មានការផ្តោតទៅលើសមធម៌ និងតម្រូវការចាំបាច់របស់កុមារតូច។<br>• មុនពេលបញ្ចប់មេរៀននៃផ្នែកនេះ អ្នកសម្របសម្រួលនឹងយោង ផងដែរទៅលើមូលនិធិសមធម៌សុខភាព និងសៀវភៅអាសយដ្ឋានសេវាកម្មសម្រាប់អ្នកងាយរងគ្រោះ ឆ្នាំ២០១០ ដែលមានរៀបរាប់ដូចខាងក្រោម។<br>**មូលនិធិសមធម៌សុខភាព**<br>• អ្នកសម្របសម្រួលសួរទៅអ្នកចូលរួម តើនរណាខ្លះស្គាល់ ឬធ្លាប់ឮពីមូលនិធិសមធម៌សុខភាពនៅក្នុងមូលដ្ឋាន?។<br>• បន្ទាប់មកអ្នកសម្របសម្រួល អនុញ្ញាតឱ្យអ្នកចូលរួម ធ្វើការពិព័ណនាសង្ខេបនៃបទពិសោធរបស់ពួកគេ។<br>• អ្នកសម្របសម្រួលបង្ហាញអំពីមូលនិធិសមធម៌សុខភាព។<br>**កំណត់ចំណាំ៖**<br>• មូលនិធិសមធម៌សុខភាព គឺជាប្រព័ន្ធដើម្បីធ្វើឱ្យប្រសើរឡើង នៃលទ្ធភាពទៅរកសេវាសុខភាពដោយ អ្នកក្រីក្រ។<br>**សៀវភៅអាសយដ្ឋានសេវាកម្មសម្រាប់អ្នកងាយរងគ្រោះ ឆ្នាំ២០១០**<br>• ព័ត៌មានក្នុងសៀវភៅនេះជួយយ៉ាងសំខាន់ទៅដល់ប្រជាជន ដែលងាយ | |

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | សម្ភារៈ |
|---|---|---|
| | រងគ្រោះក្នុងការស្វែងរកសេវាកម្មសំខាន់នានា។<br>• ការបោះពុម្ពសៀវភៅនេះ មានបំណងផ្តល់ជូននូវអាសយដ្ឋាន និងលេខទូរស័ព្ទទាក់ទងដែលងាយ ស្រួលអាចទៅរកសេវាជាច្រើនដូចជា៖ ការថែទាំសុខភាព ការគាំទ្រចិត្តសាស្ត្រ វគ្គបណ្តុះបណ្តាល និងការអប់រំស្តីពីការស្វែងរកមតិគាំទ្រ ជំនួយផ្នែកសិទ្ធិមនុស្ស និងការបង្កើនប្រាក់ចំណូល...<br>• អ្នកសម្របសម្រួលផ្តល់ឧទាហរណ៍នៃព័ត៌មានដែលផ្តល់ឱ្យនៅក្នុងសៀវភៅអាសយដ្ឋានសេវាកម្ម។<br>• **សន្និដ្ឋាន ៖** អ្នកសម្របសម្រួលសរុប និងផ្តល់អនុសាសន៍។ | |
| ៥នាទី | **៥. សន្និដ្ឋាន**<br>១. វដ្តជីវិតនៃការអភិវឌ្ឍ គឺជាឧបករណ៍មួយមានសារៈប្រយោជន៍ ដើម្បីធ្វើការវិភាគបញ្ហា និងតម្រូវការនានាដែលបានជះឥទ្ធិពលទៅដល់ស្ត្រី និងកុមារនៃដំណាក់កាលនីមួយៗនៃជីវិត។<br>២. ការអភិវឌ្ឍគ្រប់ជ្រុងជ្រោយ គឺមានសារៈសំខាន់ខ្លាំងណាស់ដូចជា៖ ការអភិវឌ្ឍផ្នែករាងកាយ(សុខភាព និងអាហារូបត្ថម្ភ គឺវាមានទំនាក់ទំនងយ៉ាងជិតស្និតទៅនឹងការអភិវឌ្ឍផ្នែកស្មារតី អារម្មណ៍ និងសង្គម)។<br>៣. មានភស្តុតាងច្បាស់លាស់ថាការវិនិយោគកុមារនៅវ័យដំបូង គឺមានសារៈសំខាន់ខ្លាំងណាស់ ព្រមទាំងនាំឱ្យមានភាពជាវិជ្ជមាន និងលទ្ធផលមានប្រសិទ្ធិភាពខ្ពស់។<br>**ឧទាហរណ៍ ៖** ការវិនិយោគទៅលើការអប់រំក្មេងស្រី គឺវាមានទំនាក់ទំនងធ្វើឱ្យមានការឆ្លងទន្លេប្រកបដោយសុវត្ថិភាព និងមានសុខភាពល្អ។ វាមានសារៈសំខាន់ផងដែរ ដើម្បីធ្វើឱ្យប្រាកដថាសេវាសង្គមជួយកាត់បន្ថយបញ្ហាមិនមានសមធម៌មួយចំនួន និងជាពិសេសតម្រូវការក្រុមមួយចំនួនកាន់តែតូចទៅៗ មនុស្សដែលរស់នៅក្នុងភាពក្រីក្របំផុត កុមារដែលពុំមានសមត្ថភាពក្នុងការរៀន និងបញ្ហាផ្សេងៗមួយចំនួនទៀត។ | |

**លំហាត់១.១ ÷ សមភាព និងសមធម៌**

១. ក្រុមប្រជាជនក្រីក្របំផុត មានអត្រាស្លាប់នៃកុមារក្រោម៥ឆ្នាំ ២ដងច្រើនជាងក្រុមប្រជាជនមានបំផុត(អសមធម៌)

២. កុមារីមានអត្រាគ្រេះគ្រិន១៦% ច្រើនជាងកុមារា (អសមធម៌)

៣. អត្រាចូលរៀនកុមារីជនជាតិភាគតិចទាបជាងអត្រាចូលរៀននៃកុមារីនៅតំបន់ដាច់ស្រយាលឯទៀត (អសមធម៌)

៤. ទារកទើបកើតភេទស្រីមានទំងន់ទាបជាងទារកទើបកើតភេទប្រុស (អសមភាព)

៥. ក្រុមមនុស្សអាយុ៦០ឆ្នាំ ឬលើសមានអត្រាជំងឺបេះដូងខ្ពស់ជាងក្រុមមនុស្សអាយុ២៥ឆ្នាំ (អសមភាព)

# ប្លង់មេរៀនទី២

# ផលប៉ះពាល់នៃគ្រោះមហន្តរាយ

# ទៅលើការអភិវឌ្ឍកុមារ

## ប្លង់មេរៀនទី២

## ផលប៉ះពាល់នៃគ្រោះមហន្តរាយទៅលើការអភិវឌ្ឍកុមារ

| | |
|---|---|
| **គោលបំណង** | នៅចុងបញ្ចប់នៃមេរៀននេះសិក្ខាកាមទាំងអស់នឹងអាចៈ<br>• រៀបរាប់បានពីផលប៉ះពាល់នៃគ្រោះមហន្តរាយទៅលើការអភិវឌ្ឍរបស់កុមារ<br>• កំណត់បាននូវវិធីកសាងសហគមន៍ឱ្យបានរឹងមាំដើម្បីឆ្លើយតបទៅនឹងវិបត្តិ<br>• រៀបរាប់បានពីសារៈសំខាន់ក្នុងការត្រៀមបម្រុងសម្រាប់គ្រោះមហន្តរាយ<br>• កំណត់បាននូវរបៀបដែល គ.ក.ន.ក អាចធ្វើទៅបានក្នុងការជួយសហគមន៍ដែលរងគ្រោះដោយគ្រោះមហន្តរាយ។ |
| **ខ្លឹមសារមេរៀន** | ១. ផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ<br>២. គ្រោះមហន្តរាយអាចបង្អាក់ការអភិវឌ្ឍកុមារ<br>៣. សហគមន៍ងាយរងគ្រោះ<br>៤. សហគមន៍រឹងមាំ<br>៥. ការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់<br>៦. ការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ(តួនាទីរបស់គ.ក.ន.ក) |
| **រយៈពេល** | ៩០ នាទី |
| **សម្ភារៈ** | ហ្វីតក្រដាសព័ណ៌ក្រដាសផ្ទាំងធំ ឯកសារចែក ស្លាយបញ្ចាំង សៀវភៅណែនាំសម្រាប់សមាជិកគ.ក.ន.កផ្នែកទី១មេរៀនទី២ទំព័រ១៦ សៀវភៅជំនួយស្មារតី |
| **វិធីសាស្ត្រ** | ការពិភាក្សាក្រុមតូចការពិភាក្សាក្រុមធំការធ្វើបទបង្ហាញ និងការបញ្ចាំងស្លាយ |

**សកម្មភាពសម្របសម្រួលមេរៀនៈ**

| **រយៈពេល** | **ជំហាន និងវិធីសាស្ត្រ** | **ធនធាន** |
|---|---|---|
| ៥នាទី | **១. ការបង្ហាញគោលបំណងនៃមេរៀន**<br>• អ្នកសម្របសម្រួល ៖ រំលឹកពីសារៈសំខាន់នៃគោលវិធីវដ្តជីវិត និងការវិនិយោគក្នុងវ័យដំបូង។<br>**ឧទាហរណ៍ ៖**<br>– កង្វះអាហារូបត្ថម្ភជាបញ្ហាចម្បងនៅក្នុងប្រទេសកម្ពុជា<br>– កុមារអាយុក្រោម ៥ឆ្នាំចំនួន ៤០% មានជម្ងឺគ្រិន(តឿ)<br>– ការចិញ្ចឹមបីបាច់កុមារមិនបានដិតដល់ក្នុងវ័យដំបូង<br>– ការឆ្លងជម្ងឺរាំរ៉ៃ និង<br>– កង្វះខាតការលើកទឹកចិត្ត។<br>**បញ្ហាទាំងនេះ៖**<br>– បានបង្អាក់ និងកាត់បន្ថយការលូតលាស់សក្តានុពលរបស់កុមារ<br>– បណ្តាលឱ្យកុមារមានសុខភាពទន់ខ្សោយនិង<br>– បន្សល់ទុកនូវភាពក្រីក្ររហូតដល់ពួកគេពេញវ័យ។ | |

| រយៈពេល | ដំណាក់ និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| | ក្នុងមេរៀននេះយើងពិភាក្សាអំពី៖<br>– ផលប៉ះពាល់នៃគ្រោះមហន្តរាយដល់សហគមន៍ទាំងមូលជាពិសេសទៅលើស្ត្រី និងកុមារ។<br>– វិធីកសាងសហគមន៍ឱ្យបានរឹងមាំ ក្នុងគោលបំណងត្រៀមបម្រុងសម្រាប់សង្គ្រោះបន្ទាន់ណាមួយ និង<br>– វិធីដែល គ.ក.ន.ក គាំទ្រគ្នាទៅវិញទៅមកដើម្បីឆ្លើយតបទៅនឹងគ្រោះមហន្តរាយ។ | |
| ១៥នាទី | **២. គ្រោះមហន្តរាយជះឥទ្ធិពលដល់ស្ត្រី និងកុមារ**<br>**២.១. និយមន័យនៃគ្រោះមហន្តរាយ**<br>**សំណួរបំផុស**<br>• អ្នកសម្របសម្រួល ៖<br>– តើធ្លាប់មានគ្រោះមហន្តរាយណាមួយកើតឡើងនៅក្នុងឃុំ សង្កាត់ របស់លោក លោកស្រីដែរ ឬទេ?<br>– តើមានបញ្ហាអ្វីខ្លះកើតឡើងក្នុងពេលនោះ?<br>– តើដូចម្តេចដែលហៅថា "គ្រោះមហន្តរាយ"?<br>**គ្រោះមហន្តរាយ ៖**<br>• សំដៅទៅលើស្ថានភាពណាមួយដែលគម្រាមកំហែងជីវិតនិងសុខមាលភាពរស់នៅរបស់ប្រជាពលរដ្ឋដែលតម្រូវឱ្យមានសកម្មភាពការពារបន្ថែមទៀតដើម្បីធានាថាជីវិតរបស់ពួកគាត់មានការថែរក្សា ការពារ និងអាចរស់នៅបាន។<br>• សំដៅផងដែរទៅលើស្ថានភាពណាមួយ ដែលកើតឡើងយ៉ាងឆាប់រហ័ស មិនបានរំពឹងទុកជាមុន ហើយស្ថានភាពនោះបណ្តាលឱ្យមាន គ្រោះថ្នាក់បាត់បង់ជីវិត បំផ្លាញទ្រព្យសម្បត្តិ និងបង្អាក់ដល់សកម្មភាព នានាជាបុគ្គល ជាគ្រួសារ ឬសហគមន៍ដែលទាមទារឱ្យមានការប្រុងប្រយ័ត្ន និងស្វែងរកដំណោះស្រាយភ្លាមៗចំពោះគ្រោះអាសន្ននោះ។<br>• គ្រោះមហន្តរាយអាចជាទឹកជំនន់ភ្លើងឆេះផ្ទះភាពរាំងស្ងួត។ល។<br>**២.២. គ្រោះមហន្តរាយជះឥទ្ធិពលដល់ស្ត្រី និងកុមារ**<br>**សំណួរបំផុសគំនិត និងបទបង្ហាញ ៖**<br>• តើការប្រែប្រួលអាកាសធាតុមានផលប៉ះពាល់អ្វីខ្លះ?<br>អ្នកសម្របសម្រួល ៖<br>• បង្ហាញ "ផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ"<br>• ផ្សារភ្ជាប់ខ្លឹមសារនៃផលប៉ះពាល់នីមួយៗ ទៅនឹង ៖<br>– ផលប៉ះពាល់ដល់កុមារ<br>– ការថប់អារម្មណ៍ និងភាពងាយរងគ្រោះរបស់កុមារ | |

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| | អ្នកសម្របសម្រួល៖<br>• បញ្ជាក់ពីតំបន់ណាខ្លះដែលងាយរងគ្រោះដោយទឹកជំនន់ ឬភាពរាំងស្ងួតដោយបង្ហាញទៅក្នុងផែនទីដោយដែលមានពណ៌ជាសម្គាល់។<br>**កំណត់សម្គាល់ ៖**<br>• គ្រោះមហន្តរាយប៉ះពាល់ទៅដល់ក្រុមគោលដៅផ្សេងៗទៀត ដូចជាស្ត្រី ជនពិការ និងចាស់ជរា។ | |
| ១៥នាទី | **៣. សហគមន៍ងាយរងគ្រោះ និងសហគមន៍ដែលរឹងមាំ**<br>**ក). សហគមន៍ងាយរងគ្រោះ**<br>**សំណួរបំផុសគំនិត ៖**<br>• តើអ្វីទៅជាសហគមន៍ងាយរងគ្រោះ?<br>• តើមានសមាសភាពអ្វីខ្លះដែលចង្អុលបង្ហាញថាសហគមន៍មួយងាយរងគ្រោះ ឬរឹងមាំ?<br>**អ្នកសម្របសម្រួល ៖**<br>• សហគមន៍មួយចំនួនងាយនឹងទទួលភាពរងគ្រោះជាងសហគមន៍ឯទៀត<br>• ភាពងាយរងគ្រោះនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងភាពក្រីក្រ និងភាពនៅដាច់ឆ្ងាយពីសង្គម។<br>• ភាពងាយរងគ្រោះមានសមាសភាពសំខាន់ៗពីរ៖<br>១. ហានិភ័យ ៖ ទឹកជំនន់ វិបត្តិសេដ្ឋកិច្ច ការប្រមូលផលមិនបាន សង្គ្រាម ភាពអត់ការងារធ្វើ និងជំងឺធ្ងន់ផ្សេងៗ។<br>២. សមត្ថភាព ៖ សមត្ថភាពឆ្លើយតបទៅនឹងគ្រោះមហន្តរាយ និងសមត្ថភាពសម្របខ្លួននៅពេលដែលជួបគ្រោះមហន្តរាយ។<br>**សំណួរបំផុសគំនិត ៖**<br>• តើគ្រោះមហន្តរាយជះឥទ្ធិពលអ្វីខ្លះដល់អារម្មណ៍ និងសកម្មភាពជន រងគ្រោះ?<br>**សញ្ញាណខ្លះៗនៃការកើនឡើងនូវភាពតានតឹងផ្លូវចិត្ត ៖**<br>– ប្រើប្រាស់គ្រឿងស្រវឹងនិងថ្នាំញៀន<br>– ខឹង(ឆាប់ផ្ទុះកំហឹង)<br>– នៅដាច់ឆ្ងាយពីសង្គម<br>– មានការថប់អារម្មណ៍និងបាក់ទឹកចិត្ត<br>– សម្ព័ន្ធភាពប្រេះឆា<br>– ខ្វះការយកចិត្តទុកដាក់លើការរៀនសូត្រការងារ និងលទ្ធផលការងារធ្លាក់ចុះ និងមានជំងឺរ៉ាំរ៉ៃ រោគសញ្ញាមិនច្បាស់លាស់ឬមូលហេតុមិនគ្រប់គ្រាន់។<br>**ខ). សហគមន៍រឹងមាំ** | |

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| | **សំណួរបំផុសគំនិត ៖**<br>• តើអ្វីទៅជាសហគមន៍រឹងមាំ?<br>**អ្នកសម្របសម្រួល ៖**<br>• ភាពរឹងមាំ៖ គឺជាសមត្ថភាពនៃប្រព័ន្ធមួយ ដូចជាសហគមន៍ ឬសង្គម ក្នុងការសម្របខ្លួនឱ្យត្រឡប់មកដំណើរការល្អឡើងវិញបន្ទាប់ពីជួបគ្រោះមហន្តរាយណាមួយ។<br>• នេះមានន័យថាសហគមន៍នោះអាចបង្កើនសមត្ថភាពរបស់ខ្លួនតាមរយៈគ្រោះមហន្តរាយពីអតីតកាលនិងសម្រាប់ការការពារពេលអនាគតនិងធ្វើឱ្យប្រសើរឡើងនូវវិធានការកាត់បន្ថយហានិភ័យ។<br>**សណួរបំផុសគំនិត ៖**<br>• តើមូលហេតុអ្វីខ្លះដែលធ្វើឱ្យសហគមន៍មួយរឹងមាំ?<br>**សហគមន៍ខ្លះមានភាពរឹងមាំដោយសារ ៖**<br>– ស៊ាំទៅនឹងភាពតក់ស្លុតដែលកើតឡើង ហើយសហគមន៍នៅតែដំណើរការការងាររបស់ខ្លួនបានដដែល<br>– អាចរៀបចំចាត់ចែង និងដោះស្រាយបានដោយខ្លួនឯងនៅពេលដែលសហគមន៍ជួបវិបត្តិ<br>– ពួកគេបង្កើតឡើងដើម្បីសង្គ្រោះជីវិត។<br>**សហគមន៍ដែលរឹងមាំគឺជាសហគមន៍ដែល ៖**<br>– គាំទ្រនិងពង្រីកការប្រាស្រ័យទាក់ទង និងភាពសុខដុមក្នុងសង្គម<br>– ពង្រឹងការជួយគ្នាក្នុងសហគមន៍និងអ្នកជិតខាង ឧទាហរណ៍ ៖ ក្រុមជួយខ្លួនឯង<br>– ពង្រឹងបន្ថែមលើចំណុចខ្លាំងមិនមែនចំណុចខ្សោយ<br>– លើកកម្ពស់ការចូលរួមរៀបចំដោយខ្លួនឯង និងភាពជាម្ចាស់<br>– ប្រើប្រាស់ធនធាននៅក្នុងសហគមន៍ដើម្បីឆ្លើយតបទៅនឹងគ្រោះមហន្តរាយ និងកាត់បន្ថយផលប៉ះពាល់នោះ។<br>**អ្នកសម្របសម្រួល** ត្រូវបញ្ជាក់ថា ៖<br>• ភាពរឹងមាំដែលយើងនិយាយនេះប្រៀបដូចជាកៅស៊ូកងអញ្ចឹង<br>– វាតែងតែប្តូររូបរាងរបស់វានៅពេលដែលទទួលភាពតក់ស្លុត ការប៉ះទង្គិចណាមួយ ប៉ុន្តែវាតែងតែត្រលប់មករករូបរាងដូចដើមវិញ។<br>សំណួរត្រួតពិនិត្យការយល់ដឹង ៖<br>• តើលោក លោកស្រីមានចំណុចណាដែលនៅមានចម្ងល់ ឬចង់បន្ថែមដែរឬទេ? | |

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| ១០នាទី | **៤. ការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់**<br>**សំណួរបំផុសគំនិត ៖**<br>• តើនៅឃុំ សង្កាត់លោក លោកស្រីធ្លាប់កើតមានគ្រោះមហន្តរាយដែរ ឬទេ?<br>• តើមានផលប៉ះពាល់អ្វីខ្លះក្នុងកំឡុងពេលនោះ?<br>• តើលោក លោកស្រីដោះស្រាយដោយរបៀបណា?<br>• តើដំណោះស្រាយទាំងនោះ មានប្រសិទ្ធិភាពកម្រិតណាដែរ?<br>• តើដំណោះស្រាយទាំងនោះ លោក លោកស្រីបានត្រៀមបម្រុងទុកជាមុន ឬក៏ដោះស្រាយភ្លាម?<br>**អ្នកសម្របសម្រួល ៖**<br>• មេរៀននេះនឹងពិភាក្សាអំពីសារៈសំខាន់ ក្នុងការត្រៀមលក្ខណៈសម្រាប់ការសង្គ្រោះបន្ទាន់។<br>• (ជាជម្រើស)៖ អ្នកសម្របសម្រួលអាចរំលឹកពីទឹកជំនន់នៅឆ្នាំ២០១១ដែលធ្វើឱ្យប្រជាពលរដ្ឋភាគច្រើនទទួលរងគ្រោះពីទឹកជំនន់នេះ។ នៅខែកុម្ភៈឆ្នាំ២០១២ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុនសែន** ដែលជាប្រធានអង្គប្រជុំ អង្គការអន្តរជាតិ អង្គការក្នុងស្រុក និងស្ថាប័នរដ្ឋាភិបាលបានសង្កត់ធ្ងន់ពីសារៈសំខាន់នៃការធ្វើផែនការ និងការឆ្លើយតបឱ្យមានប្រសិទ្ធិភាពជាមុនទៅនឹងគ្រោះមហន្តរាយ។<br>• យើងដឹងហើយថាផលប៉ះពាល់នៃគ្រោះមហន្តរាយមានទំហំខុសៗគ្នាពីសហគមន៍មួយទៅសហគមន៍មួយពីគ្រួសារមួយទៅគ្រួសារមួយ។<br>• កម្រិតនៃការត្រៀមបម្រុងនៅក្នុងសហគមន៍បានជួយរួមចំណែក ក្នុងការធ្វើឱ្យប្រសើរឡើងនូវភាពរឹងមាំរបស់សហគមន៍ ឆ្លើយតបទៅនឹងគ្រោះមហន្តរាយ។<br>**កំណត់សម្គាល់ ៖**<br>• ព័ត៌មានពិស្តារដែលរៀបរាប់អំពីភាពរឹងមាំរបស់សហគមន៍ និងភាពតក់ស្លុតមាននៅក្នុងសៀវភៅណែនាំទំព័រទី៨-៩ និងក្នុងសៀវភៅជំនួយស្មារតីទំព័រទី១៦៩-១៧៨។ | |

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| ៣៥នាទី | **៥. ការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ**<br>**ក). សំណួរបំផុសគំនិត**<br>• តើហេតុអ្វីបានចាំបាច់ត្រូវមានផែនការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់?<br>• តើលោក លោកស្រី រៀបចំផែនការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់ដោយរបៀបណា?<br>**ខ). ការពិភាក្សាក្រុម** ៖ ករណីសិក្សាស្តីពីទឹកជំនន់នៅឃុំអំពិល ៖<br>• បែងចែងក្រុមពិភាក្សាជា៤ក្រុម<br>• ក្រុមនីមួយៗអានឯកសារករណីសិក្សាស្តីពីទឹកជំនន់នៅឃុំអំពិល<br>• បន្ទាប់មក ធ្វើការវិភាគពីស្ថានភាពនោះដោយផ្អែកតាមសំណួរណែនាំដូចខាងក្រោម ៖<br>១. តើមានបញ្ហាអ្វីកើតឡើង?<br>២. តើការងារអ្វីខ្លះដែលគ.ក.ន.កធ្វើបានល្អ?<br>៣. តើបណ្តាញណាខ្លះដែលពួកគាត់ព្យាយាមទាក់ទង?<br>៤. តើពួកគាត់ទទួលបានការគាំទ្រពីនរណាខ្លះ?<br>៥. តើចំណុចណាខ្លះនៅក្នុងករណីនេះដែលលោកលោកស្រីមិនធ្លាប់បានអនុវត្ត?<br>៦. ប្រសិនបើករណីស្រដៀងគ្នានេះកើតឡើងក្នុងឃុំ សង្កាត់ លោក លោកស្រី តើចំណុចណាខ្លះ ដែលលោក លោកស្រី អាចយកទៅអនុវត្តបាន និងអនុវត្តមិនបាន?<br>៧. តើលោក លោកស្រី មានគំនិតយោបល់យ៉ាងណា ដើម្បីធ្វើឱ្យការឆ្លើយតបទៅនឹងស្ថានភាពនេះ មានភាពប្រសើរឡើង?<br>**គ). ការធ្វើបទបង្ហាញ** ៖<br>• ក្រុមនីមួយៗ ៖ ធ្វើបទបង្ហាញពីលទ្ធផលនៃការពិភាក្សា។<br>• អ្នកសម្របសម្រួល ៖ ធ្វើសេចក្តីសន្និដ្ឋានសង្ខេបដោយបញ្ជាក់ពីសារៈសំខាន់នៃទំនាក់ទំនងរវាងបណ្តាញគាំទ្រនានា។<br>កំណត់សម្គាល់ (ចម្លើយតបទៅនឹងសំណួរខាងលើ)៖<br>១. មានទឹកជំនន់កើតឡើងនៅឃុំអំពិល<br>២. ការងារដែល គ.ក.ន.ក ធ្វើបានល្អ ៖<br>– ធ្វើការសហការ និងរាយការណ៍ជាប្រចាំទៅក្រុមប្រឹក្សា<br>– ក្តាប់ព័តមានតាមវិទ្យុ និងទូរទស្សន៍<br>– បង្កើតកិច្ចប្រជុំ<br>– ជម្លៀសគ្រួសាររងគ្រោះមកកាន់ទីទួលសុវត្ថិភាព<br>– ធានាសុវត្ថិភាពផ្ទះសម្បែងរបស់ប្រជាពលរដ្ឋ | |

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| | – ទំនាក់ទំនងជាមួយក្រុមគ្រូពេទ្យដើម្បីធ្វើការអប់រំពីសុវត្ថិភាពអាហារ អនាម័យ ការការពារជម្ងឺឆ្លង ការបរិភោគទឹកស្អាត ព្រមទាំងជំងឺផ្សេងៗ ដូចជា ៖ ជម្ងឺរាគរូសនិងគ្រុនចាញ់ជាដើម។<br>– ធ្វើការឆ្លុះបញ្ចាំង និងរៀនសូត្រពីបទពិសោធន៍<br>– រៀបផែនការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់បន្តទៀត<br>៣. បណ្តាញដែលពួកគាត់បានព្យាយាមធ្វើការទាក់ទង ៖<br>– ក្រុមសហគមន៍នៃសាទដើម្បីត្រៀមលក្ខណៈជួយប្រជាជន(ត្រៀមទូក កាណូត...)<br>– រាយការណ៍ទៅគណៈកម្មាធិការស្រុក និងខេត្តផ្នែកគ្រោះមហន្តរាយ មណ្ឌលសុខភាព អប់រំ និងដៃគូអភិវឌ្ឍន៍ផ្សេងៗ(ផ្តល់ជាតង់ កញ្ចប់ថ្នាំពេទ្យ, ម្ហូបអាហារ...)<br>៤. ពួកគាត់បានទទួលការគាំទ្រ៖ ដូចចំលើយទី៣<br>៥. ៦. និង ៧. ចំលើយផ្អែកលើគំនិតយោបល់ក្រុមនីមួយៗ<br>**កំណត់ចំណាំ ៖**<br>ឧទាហរណ៍នៃសហគមន៍ដែលរឹងមាំទាក់ទងទៅនឹង ៖<br>– សមត្ថភាពក្នុងការទទួលយកភាពតក់ស្លុតដែលកើតឡើង និងអាចវិលត្រលប់មកសភាពដើមវិញបានយ៉ាងឆាប់រហ័ស<br>– សមត្ថភាពនៃការរៀនពីបទពិសោធន៍ និងធ្វើផែនការត្រៀមបម្រុងសម្រាប់គ្រោះមហន្តរាយដែលអាចនឹងកើតមានឡើងនាពេលខាងមុខ<br>– ជាពិសេសការភ្ជាប់ទំនាក់ទំនងទៅនឹងបណ្តាញគាំទ្រនានា ដូចជាមេឃុំ សមាជិកក្រុមប្រឹក្សាឃុំ សេវាសង្គមថ្នាក់ស្រុកខេត្ត និង សមាជិក គ.ក.ស.ក និងអង្គការនានាដែលធ្វើការនៅក្នុងតំបន់នោះ។ | |
| ៥នាទី | **៦. សេចក្តីសន្និដ្ឋាន**<br>ការសន្និដ្ឋានសម្រាប់មេរៀនទាំងមូល ៖<br>• កុមារជាជនដែលងាយរងគ្រោះបំផុតនៅក្នុងពេលគ្រោះមហន្តរាយ<br>• សហគមន៍ខ្លះងាយរងគ្រោះជាងសហគមន៍មួយទៀត<br>• សម្រាប់សហគមន៍ដែលរឹងមាំសមាជិកម្នាក់ៗត្រូវតែរួចរាល់នៅក្នុងការឆ្លើយតបទៅនឹងគ្រោះអាសន្ន ឬវិបត្តិអ្វីមួយ<br>• គ.ក.ន.កអាចជួយសហគមន៍ដោយផ្តល់ព័ត៌មានឱ្យសហគមន៍ ពីវិធីដែលពួកគាត់ឱ្យឆ្លើយតបទៅនឹងគ្រោះអាសន្នណាមួយ<br>• អំឡុងពេលគ្រោះអាសន្នគ.ក.ន.កអាចជួយក្រុមប្រឹក្សាឃុំ និងសហគមន៍ដើម្បីឆ្លើយតបទៅនឹងបញ្ហានោះ។ | |

**ឯកសារ ១.២.១**

## ការឆ្លើយតបនឹងភាពអាសន្ន

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ (គ.ក.ន.ក) នៅឃុំអំពិលបានបង្កើតឡើងនៅឆ្នាំ២០១០។ ចាប់តាំងពីពេលនោះមកសមាជិក គ.ក.ន.ក បានដើរតួយ៉ាងសំខាន់រួមដៃគ្នាដោះស្រាយតម្រូវការស្ត្រី និងកុមាររងាយរងគ្រោះបំផុត។ នៅក្នុងឆ្នាំ២០១១ មានទឹកជំនន់យ៉ាងធ្ងន់ធ្ងរនៅក្នុងស្រុកជាច្រើននៅភាគពាយព្យនៃប្រទេសកម្ពុជា។

គ.ក.ន.ក នៅឃុំអំពិលបានទុកការងារប្រចាំថ្ងៃរបស់ពួកគាត់មួយអន្លើសិន ហើយចាប់ផ្តើមធ្វើការប៉ាន់ប្រមាណតម្រូវការបន្ទាន់របស់សហគមន៍ ដែលរងគ្រោះដោយទឹកជំនន់អស់រយៈពេល២៤ ទៅ៧៤ម៉ោង។ តាមរយៈការប្រើប្រាស់បញ្ជីដែលរៀបចំរួចស្រេចនោះ ក្រុមការងារប្រមូលបានព័ត៌មានដ៏មានប្រយោជន៍ជាច្រើន ហើយ គ.ក.ន.កបានប្រើប្រាស់ព័ត៌មានទាំងនោះ ដើម្បីកៀរគរប្រជាពលរដ្ឋ និងធនធានផ្សេងៗ។ ឧទាហរណ៍ ក្រុមប្រឹក្សាឃុំ សង្កាត់បានរៀបចំកិច្ចប្រជុំជាមួយនគរបាលប្រចាំមូលដ្ឋាន និងក្រុមសហគមន៍នេសាទ ដើម្បីត្រៀមទប់ទល់ទៅនឹងគ្រោះទឹកជំនន់។ ពួកគាត់បានរៀបចំផ្គត់ផ្គង់ និងទូក ដើម្បីផ្តល់ផ្គត់ផ្គង់ទាំង នោះទៅឱ្យគ្រួសារដែលជាប់គាំងដោយសារ ទឹកជំនន់។ ជារៀងរាល់ថ្ងៃ គ.ក.ន.ក ធ្វើការជាមួយនគរបាល ដើម្បីត្រួតពិនិត្យស្ថានភាពតាមហេតុការណ៍។ គ.ក.ន.ក បានជិះទូកទៅសួរសុខទុក្ខប្រជាជននៅទីនោះ។ នៅពេលដែលពួកគាត់ឆ្លងកាត់ប្រទះឃើញគ្រួសារដែលទទួលរងការលិចផ្ទះសម្បែង ពួកគាត់បានជួយជម្លៀសគ្រួសារទាំងនោះមកកាន់ទីទួលសុវត្ថិភាព ថែមទាំងដឹកជញ្ជូនសត្វពាហនៈ និងចំបើងដែលជាចំណីវាផងដែរ។ មិនតែប៉ុណ្ណោះ គ.ក.ន.ក បានសហការជាមួយនគរបាល ដើម្បីការពារទ្រព្យសម្បត្តិ និងផ្ទះសម្បែងរបស់ប្រជាពលរដ្ឋឱ្យមានសុវត្ថិភាពទៀតផង។ ពួកគាត់ក៏បានតាមដាននូវលំហូរព័ត៌មានរបស់សហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងៗផងដែរ(តាមរយៈអាយកូម ការស្តាប់ វិទ្យុ និងការមើលទូរទស្សន៍)។ ពួកគាត់បានរាយការណ៍ជូនគណៈកម្មាធិការស្រុក និងខេត្តផ្នែកគ្រប់គ្រងគ្រោះមហន្តរាយ ព្រមទាំងរាយការណ៍ទៅបុគ្គលិកមណ្ឌលសុខភាព អប់រំ និងដៃគូ អភិវឌ្ឍន៍ផ្សេងៗទៀតដែលមានវត្តមាននៅក្នុងខេត្តនេះ។ ការកៀរគរភ្លាមៗនោះក៏មានការឆ្លើយតបជាមួយនឹងការផ្តល់ជំនួយដូច ជាស្បៀង ធុងទឹក ធុងចម្រោះទឹក សាប៊ូដុំ និងសម្ភារៈសម្រាប់សង់ ជម្រកមួយចំនួនទៀត។ ក្រុមគ្រូពេទ្យបានរៀបចំសេវាគាំទ្រសុខភាព ចល័តជួយប្រជាពលរដ្ឋដែលត្រូវការជំនួយ ចាំបាច់(ការរក្សាសុខភាព ឬថ្នាំសង្កូវផ្សេងៗ)។ លើសពីនេះទៀតពួកគាត់បានផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើស្ត្រីមានផ្ទៃពោះ កុមារតូច ជនពិការ និងជនចាស់ជរា។ ក្រុមគ្រូពេទ្យក៏បានធ្វើការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងពីគ្រោះថ្នាក់ដោយពស់ចឹក វិធានការការពារប្រឆាំងនឹងគ្រោះថ្នាក់មួយចំនួន ដូចជា ជំងឺរាគរូស រាគមួល គ្រុនចាញ់ និងគ្រុន ឈាមផងដែរ។ ការផ្តល់ដំបូន្មានដ៏មានតម្លៃទាក់ទងទៅនឹងសារៈសំខាន់នៃការទទួលបានទឹកស្អាត(ដោយសារ ការដាំទឹកឱ្យពុះ ចម្រោះទឹក និងដាក់ថ្នាំក្លរ៉ាមីន)ការប្រើប្រាស់បង្គន់អនាម័យ និងការលាងដៃនឹងសាប៊ូ នៅមុនពេលទទួលទានអាហារមុនពេលរៀបចំអាហារ បន្ទាប់ពីចេញពីបង្គន់ ប៉ះសត្វ និងលាងគូទឱ្យកុមារ។ល។ ការងារទាំងនេះបានទទួលជោគជ័យជាស្ថាពរ ក្រោមកិច្ចសហការជាមួយស្ថាប័ន និងអង្គការផ្សេងៗមួយចំនួន(រួមទាំងអង្គការជនពិការផងដែរ)។

ចំណុចសំខាន់មួយទៀតនោះគឺ បន្ទាប់ពីទឹកជំនន់បានស្រកចុះទៅវិញ សមាជិក គ.ក.ន.ក បាន ធ្វើការឆ្លុះបញ្ចាំងទៅលើបទពិសោធន៍ និងអ្វីដែលពួកគាត់បានរៀនសូត្រពីបទពិសោធន៍នោះ។ បន្ទាប់មក ពួកគាត់បានរៀបចំផែនការត្រៀមបម្រុងដើម្បីឆ្លើយតបទៅនឹងគ្រោះអាសន្ន ក្នុងការជួយឱ្យការងារ ពួកគាត់កាន់តែមានប្រសិទ្ធភាពក្នុងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយក្នុងករណីវាកើតឡើងម្តងទៀត។ ផែនការរបស់ពួកគាត់រួមមានសកម្មភាពមួយចំនួនដែលត្រូវធ្វើក្នុងករណីដែលកើតមានគ្រោះទឹកជំនន់ម្តងទៀត ឬក្នុងករណីមានគ្រោះរាំងស្ងួតធ្ងន់ធ្ងរ។

# ប្លង់មេរៀនទី៣

# ការបញ្ជាក់ពីតួនាទី និងភារកិច្ចរបស់

# គ.ក.ន.ក

## ប្លង់មេរៀនទី៣

## ការបញ្ជាក់ពីតួនាទី និងភារកិច្ចរបស់គ.ក.ន.ក

| | |
|---|---|
| **គោលបំណង** | នៅចុងបញ្ចប់នៃមេរៀនសិក្ខាកាមនឹងអាច៖<br>• ពិពណ៌នាបានពីតួនាទី និងភារកិច្ចរបស់គ.ក.ន.ក<br>• ពិពណ៌នាពីទំនាក់ទំនងរវាងគ.ក.ន.កនិង គ.ក.ស.ក និងក្រុមផ្សេងៗទៀត ដែលគាំទ្រគ.ក.ន.កក្នុងការបំពេញតួនាទីនិងការទទួលខុសត្រូវរបស់គាត់។<br>• រៀបរាប់បានពីសារៈសំខាន់នៃការចុះបញ្ជីអត្រានុកូលដ្ឋាន<br>• រៀបរាប់បានពីដំណើរការ និងរបៀបវារៈ នៃការប្រជុំរបស់គ.ក.ន.ក |
| **ខ្លឹមសារមេរៀន** | ១. តួនាទី និង គោលបំណងរបស់គ.ក.ន.ក<br>២. ទំនាក់ទំនងរវាងបណ្តាញគាំទ្រនានារួមទាំងគ.ក.ស.ក<br>៣. សារៈសំខាន់នៃការចុះបញ្ជីអត្រានុកូលដ្ឋាន |
| **រយៈពេល** | ១៣០ នាទី |
| **សម្ភារៈ** | ក្រដាសពណ៌ក្រដាសផ្ទាំងធំហ្វីត ស្កុត និងកន្ត្រៃ<br>សៀវភៅណែនាំសម្រាប់គ.ក.ន.ក ផ្នែកទី១មេរៀនទី៣ទំព័រ១១ |
| **វិធីសាស្ត្រ** | ការបំផុសគំនិតពិភាក្សាក្រុមតូច/ក្រុមធំបង្ហាញការឆ្លុះបញ្ចាំង និងបង្ហាញស្លាយ |

**សកម្មភាពសម្របសម្រួលមេរៀន ÷**

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | សម្ភារៈ |
|---|---|---|
| ៥នាទី | **១. បង្ហាញសេចក្តីផ្តើម និងគោលបំណង**<br>• **សេចក្តីផ្តើម** ៖ លោក លោកស្រីបានរៀនរួចហើយអំពីគោលវិធីវដ្តជីវិត និង សារៈសំខាន់នៃការវិនិយោគកុមារវ័យដំបូងព្រមទាំងផលប៉ះពាល់នៃគ្រោះមហន្តរាយទៅលើការអភិវឌ្ឍកុមារ។ ក្នុងមេរៀននេះយើងនឹងបានដឹងពី តួនាទី និងភារកិច្ចរបស់ គ.ក.ន.ក រួមទាំង តួនាទីអ្នកពាក់ព័ន្ធផ្សេងៗ ទៀត និងពីសារៈសំខាន់នៃការចុះបញ្ជីអត្រានុកូលដ្ឋាន<br>• **គោលបំណងមេរៀន** ៖ បង្ហាញគោលបំណងនៃមេរៀន ព្រមទាំងសួរបញ្ជាក់ទៅពួកគាត់ប្រសិនបើគាត់មានចម្ងល់។ | |
| ៤៥នាទី | **២. តួនាទី និងភារកិច្ចរបស់គ.ក.ន.ក**<br>**សំណួរបំផុសគំនិត**<br>• រំលឹកមេរៀន(៥នាទី) ៖ អ្នកសម្របសម្រួលឱ្យសិក្ខាកាមរំលឹកមេរៀន ទី២ ឡើងវិញ (តំណាងក្រុម)<br>• អ្នកសម្របសម្រួលបំផុសគំនិតភ្ជាប់មេរៀននោះទៅនឹងតួនាទី និង ភារកិច្ចរបស់ គ.ក.ន.ក ដោយប្រើសំណួរដូចខាងក្រោម៖<br>– តើ(គ.ក.ន.ក) ឬ គណៈកម្មាធិការទទួលកិច្ចការនារី និងកុមារឃុំ សង្កាត់មានតួនាទីនិងភារកិច្ចដូចម្តេចខ្លះ? (ចម្លើយ ៤ដល់៩) | |

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | សម្ភារៈ |
|---|---|---|
| | – ដើម្បីលើកកម្ពស់ដល់ការចូលរួមរបស់ស្ត្រី តើគណៈកម្មាធិការនេះ ត្រូវមានសមាជិកជានារីយ៉ាងតិចប៉ុន្មានភាគរយនៃសមាជិកទាំង អស់? (ចម្លើយទី៤ដល់៩)<br>– អ្នកសម្របសម្រួលកត់ត្រាលើក្រដាសផ្ទាំងធំ បន្ទាប់មកពន្យល់ និងបង្ហាញខ្លឹមសារមេរៀន<br>• ក្រោយពីទទួលបានចម្លើយពីសិក្ខាកាមមក អ្នកសម្របសម្រួលបង្ហាញពីតួនាទី និងភារកិច្ចរបស់គ.ក.ន.ក ហើយបញ្ជាក់ប្រាប់ពួកគាត់ថាមានការកែសម្រួលតួនាទី និងភារកិច្ចខ្លះរបស់ គ.ក.ន.ក ដោយបន្ថែមពីអ្វីដែលលោក លោកស្រីធ្លាប់ដឹងរួចមក ហើយអាស្រ័យតាមការឆ្លុះបញ្ចាំង ពីសមធម៌។ ចំពោះភាពពិស្តារនៃការចុះបញ្ជីអត្រានុកូលដ្ឋានមាននៅ ក្នុងសៀវភៅណែនាំ។<br>**កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល ៖**<br>• ទិដ្ឋភាពទូទៅនៃតួនាទី និងភារកិច្ច របស់ គ.ក.ន.ក មានក្នុងសៀវភៅការអនុវត្តមុខងាររបស់គណៈកម្មាធិការ ទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ ដែលយើងបានឃើញតាំងពី ព្រឹកមករហូតដល់ពេលនេះ។<br>• អ្នកសម្របសម្រួលពន្យល់ថា ៖ ការឆ្លើយតបទាំងនេះជាឧទាហរណ៍នៃ តួនាទី និងការទទួលខុសត្រូវរបស់ គ.ក.ន.ក (សៀវភៅណែនាំទំព័រ១១ និង ១២)។ | |
| ៣០នាទី | **៣. ការចុះបញ្ជីអត្រានុកូលដ្ឋាន**<br>**ក). សំណួរបំផុសគំនិត**<br>• អ្នកសម្របសម្រួលបង្ហាញពីតួនាទីដ៏សំខាន់របស់ គ.ក.ន.ក ទាក់ទងនឹងការងារអត្រានុកូលដ្ឋាន។<br>• អ្នកសម្របសម្រួលសួរសំណួរបំផុសឱ្យសិក្ខាកាមគិតពិចារណាពីចម្លើយ<br>១. តើអត្រានុកូលដ្ឋានផ្តល់នៅសារប្រយោជន៍សំខាន់ៗប៉ុន្មានយ៉ាង? អ្វីខ្លះ ?<br>២. តើផលប្រយោជន៍នៃការចុះបញ្ជីអត្រានុកូលដ្ឋានចំពោះបុគ្គលម្នាក់ៗ (ចំពោះខ្លួនយើង) និងចំពោះគ្រួសារ(ចំពោះសង្គមជាតិ) មានអ្វីខ្លះ?<br>• អ្នកសម្របសម្រួលចែកកាតដល់សិក្ខាកាម(១កាតមួយ មួយគំនិត)។<br>• បន្ទាប់មក អ្នកសម្រួលស្នើសិក្ខាកាមស្ម័គ្រចិត្ត១៦នាក់(ឈរជាពីរជួរ មួយជួរ ៨នាក់)<br>• សិក្ខាកាមមួយជួរត្រូវឆ្លើយអំពីសារៈសំខាន់នៃអត្រានុកូលដ្ឋានចំពោះបុគ្គល និងមួយក្រុមទៀតឆ្លើយពីសារៈសំខាន់ចំពោះជាតិ។ អ្នកកត់ត្រាកត់ចម្លើយសិក្ខាកាមដាក់លើក្រដាសផ្ទាំងធំ។ | |

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | សម្ភារៈ |
|---|---|---|
| | ខ). បទបង្ហាញខ្លឹមសារមេរៀនអត្រានុកូលដ្ឋាន<br>• អ្នកសម្របសម្រួលបង្ហាញខ្លឹមសារមេរៀន | |
| ១៥ នាទី | **៤. ការរៀបចំ និងការចាត់ចែងកិច្ចប្រជុំឱ្យមានប្រសិទ្ធភាព**<br>**បទបង្ហាញ ៖ ការរៀបចំ និងការចាត់ចែងកិច្ចប្រជុំឱ្យមានប្រសិទ្ធភាព**<br>• អ្នកសម្របសម្រួលអាចសួរសំណួរបំផុស ទាក់ទងនឹងការរៀបចំការប្រជុំ និងការចាត់ចែងកិច្ចប្រជុំ ប្រកបដោយប្រសិទ្ធភាព<br>• បន្ទាប់មកអ្នកសម្របសម្រួលស្នើសុំឱ្យសិក្ខាកាមអានគោលការណ៍ណែនាំអំពីការប្រជុំ ដូចមានក្នុងសៀវភៅណែនាំពីទំព័រទី ១៧ ដល់ ២២។<br>**កំណត់ចំណាំ៖**<br>អ្នកសម្របសម្រួលគួរសង្កត់ធ្ងន់ពីសារៈសំខាន់នៃទិន្នន័យ និងសូចនាករ ដែលសមាជិកនីមួយៗនៃអង្គប្រជុំ ដូចជា ៖ ប៉ូលីស មន្ត្រីអត្រានុកូលដ្ឋាន អប់រំ... បានរាយការណ៍នៅក្នុងកិច្ចប្រជុំប្រចាំខែរបស់ គ.ក.ន.ក ដែលគួរធ្វើមុនកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ។ | |
| ៣០នាទី | **៥. ការឆ្លុះបញ្ចាំងដំណើរការរៀនសូត្រ**<br>**សំណួរបំផុសគំនិត**<br>• បន្ទាប់មកអ្នកសម្របសម្រួលសួរថា ៖<br>– ទាក់ទងទៅនឹងតួនាទី និងភារកិច្ចរបស់គ.ក.ន.កនៅក្នុងសៀវភៅ ណែនាំ តើតួនាទី និងភារកិច្ចមួយណាដែលលោក លោកស្រី មានអារម្មណ៍ថាបំពេញបានល្អបំផុត?<br>– តើតួនាទី និងភារកិច្ចមួយណាដែលលោកលោកស្រីមានអារម្មណ៍ថាបំពេញមិនទាន់បានល្អ?<br>– តើអ្វីដែលលោកលោកស្រីអាចធ្វើបានបើសិនជាជួបប្រទះនូវបញ្ហាណាមួយដែលលោកលោកស្រីយល់មិនបានច្បាស់ និងជាបញ្ហាដែលលោក លោកស្រីមិនធ្លាប់ជួបពីមុនមក?<br>– ឧទាហរណ៍ ៖ កុមារ (មិនទាន់ចុះបញ្ជីកំណើតមិនបានចាក់ថ្នាំបង្ការ មិនទៅសាលារៀន តែទៅធ្វើការនៅឡូតដូ)<br>– តើលោក លោកស្រីនឹងនាំយកបញ្ហានេះទៅជូន គ.ក.ស.ក ថ្នាក់ ស្រុក និងថ្នាក់ខេត្តដូចម្តេចខ្លះ?<br>សំណួរនេះនឹងនាំឱ្យមានការណែនាំទៅរកការពិភាក្សាពីទំនាក់ទំនងរបស់ គ.ក.ន.ក និងសេវារដ្ឋបាលថ្នាក់មូលដ្ឋាន។<br>– តើលោក លោកស្រីអាចរកបានការបញ្ជាក់ និងការគាំទ្របានពីអ្នកណាខ្លះទៀត? | |

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | សម្ភារៈ |
|---|---|---|
| | • អ្នកសម្របសម្រួលនឹងផ្តល់ជាឧទាហរណ៍ខ្លះៗ នូវបណ្តាញនៃការគាំទ្រ នឹងពីរបៀបដែលគ.ក.ន.កអាចប្រើប្រាស់បណ្តាញគាំទ្រនេះ ដើម្បីដោះស្រាយបញ្ហាប្រឈមខ្លះៗ ដែលពួកគាត់បានលើកមកបង្ហាញ ដូចជាទំនាក់ទំនងជាមួយ គ.ក.ស.ក ជាមួយជនបង្គោលត្រួតពិនិត្យ និងវាយតម្លៃនៅក្នុងឃុំ ឬអ្នកពាក់ព័ន្ធផ្សេងៗទៀត។ | |
| ៥នាទី | **៤. សន្និដ្ឋានមេរៀន**<br>• អ្នកសម្របសម្រួលធ្វើការសន្និដ្ឋានពីសារៈសំខាន់នៃតួនាទីរបស់ គ.ក.ន.ក និងសារៈសំខាន់នៃការចុះបញ្ជីកំណើត។ | |

# ប្លង់មេរៀនទី៤

# ប្រើប្រាស់ទិន្នន័យ ដើម្បីធ្វើឱ្យប្រសើរ
# ឡើងនូវសមត្ថភាពនៃការកសាងផែនការ
# និងការចាត់អាទិភាព

## មេរៀនទី ៤

## ការប្រើប្រាស់ទិន្នន័យដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពនៃការកសាងផែនការ និងការចាត់អាទិភាព

| | |
|---|---|
| **គោលបំណង** | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹងអាច៖<br>• រៀបរាប់បានពីឧបករណ៍សម្រាប់កសាងផែនការ និងការសម្រេចចិត្ត<br>• អាចប្រើប្រាស់សូចនាករសំខាន់ៗ ដែលបានមកពីឧបករណ៍នានា ក្នុងការប្រមូលទិន្នន័យ ដើម្បីរៀបចំផែនការសកម្មភាព ប្រកបដោយសមធម៌ និងឆ្លើយតបទៅ នឹងតម្រូវការរបស់ស្ត្រី និងកុមារ ព្រមទាំងជនដែលងាយរងគ្រោះ |
| **ខ្លឹមសារមេរៀន** | • ឧបករណ៍សម្រាប់កសាងផែនការ និងការសម្រេចចិត្ត<br>• ការប្រើប្រាស់សូចនាករសំខាន់ៗ ដើម្បីរៀបចំផែនការសកម្មភាពប្រកបដោយ សមធម៌ និងឆ្លើយតបទៅនឹងតម្រូវការរបស់ស្ត្រី និងកុមារព្រមទាំងជនដែលងាយរងគ្រោះ |
| **រយៈពេល** | ១៥០នាទី |
| **សម្ភារៈ** | ប៊ិចហ្វឺត ក្រដាសកាតពណ៌ ក្រដាសផ្ទាំងធំ ស្លាយ ឯសារទិន្នន័យឃុំអំពិល(សូចនាករ) កូនសៀវភៅណែនាំសម្រាប់សមាជិក គ.ក.ន.ក ផ្នែកទី៤ អំពីការប្រើប្រាស់ទិន្នន័យ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពនៃការកសាងផែនការ និងការចាត់អាទិភាពពីទំព័រទី១៦ ដល់ ២៥ |
| **វិធីសាស្ត្រ** | ពិភាក្សាក្រុមតូច ពិភាក្សាក្រុមធំ លំហាត់ទីផ្សារ និងការធ្វើបទបង្ហាញ។ |

**សកម្មភាពសម្របសម្រួលមេរៀន ÷**

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | |
|---|---|---|
| ៥នាទី | **១. សេចក្តីផ្តើម និងគោលបំណង**<br>អ្នកសម្របសម្រួលរំលឹកមេរៀនទី៣ និងបង្ហាញគោលបំណងមេរៀន<br>• រៀបរាប់បានពីឧបករណ៍សម្រាប់កសាងផែនការ និងការសម្រេចចិត្ត<br>• អាចប្រើប្រាស់សូចនាករសំខាន់ៗ ដែលបានមកពីឧបករណ៍នានាក្នុងការប្រមូលទិន្នន័យ ដើម្បីរៀបចំផែនការសកម្មភាពប្រកបដោយសមធម៌ និងឆ្លើយតបទៅនឹងតម្រូវការរបស់ស្ត្រី និងកុមារ ព្រមទាំងជនដែលងាយរងគ្រោះ។ | |
| ៣០នាទី | **២. ឧបករណ៍សម្រាប់កសាងផែនការ និងការសម្រេចចិត្ត**<br>ក). សំណួរបំផុស<br>• ដើម្បីឱ្យការរៀបចំផែនការ និងការសម្រេចចិត្តប្រកបដោយប្រសិទ្ធភាព និងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ តើគ.ក.ន.ក និងក្រុមប្រឹក្សាឃុំសង្កាត់ទាមទារការយកចិត្តទុកដាក់ និងពិចារណាទៅលើចំណុចសំខាន់អ្វីខ្លះ?<br>• ហេតុត្រូវការមានទិន្នន័យ ឬព័ត៌មាន?<br>• តើឧបករណ៍ព័ត៌មានមានអ្វីខ្លះ?<br>• តើមានឧបករណ៍ណាផ្សេងពីឧបករណ៍ខាងលើដែរឬទេ?<br>• ព័ត៌មានអ្វីខ្លះ ដែលលោក លោកស្រីអាចប្រមូលបានពីឧបករណ៍ទាំងនោះ? | |

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | |
|---|---|---|
| | ខ). បទបង្ហាញមេរៀន ៖ អ្នកសម្របសម្រួលបង្ហាញខ្លឹមសារមេរៀន | |
| | **ចំណាំ ៖**<br>• ដំណើរការនៃការធ្វើផែនការ បើសិនជាការអនុវត្តទៅដោយមានការចូលរួម នោះឱ្យអ្នកពាក់ព័ន្ធផ្សេងៗធ្វើការផ្លាស់ប្តូរគំនិត ឯកភាពទៅលើតម្រូវការផ្សេងៗគ្នា ព្រមទាំងមានការចេចារទទួលយកផែនការសកម្មភាព។ ដំណើរការនេះ លើកទឹកចិត្តឱ្យមានភាពជាម្ចាស់ និងគាំទ្រក្នុងការអនុវត្តផែនការ។<br>• ផែនការសកម្មភាពដែលឆ្លើយតបទៅនឹងតម្រូវការរបស់ស្ត្រី និងកុមារ និងក្រុមជនដែលងាយរងគ្រោះត្រូវធ្វើសមាហរណកម្មទៅក្នុង និងស្របទៅនិងកម្មវិធីវិនិយោគរបស់ឃុំ សង្កាត់។ | |
| | ☞ **ហេតុត្រូវការមានទិន្នន័យ ឬព័ត៌មាន?**<br>• ជួយឱ្យ គ.ក.ន.ក ធ្វើការវិភាគបញ្ហា និងកំណត់ជាអាទិភាពដែលទាក់ទងទៅនឹងការចុះបញ្ជីអត្រានុកូលដ្ឋាន កិច្ចការពារជនដែលងាយរងគ្រោះបំផុត សុខមាលភាពមាតា ទារក កុមារនិងអាហាររូបត្ថម្ភ មត្តេយ្យសិក្សាសហគមន៍ កែលម្អអនាម័យអាងលាងដៃនឹងសាប៊ូ និងទឹកស្អាត និងអនាម័យ សមធម៌យែនឌ័រ ការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់ និងការឆ្លើយតប ដើម្បីរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ(ទម្រង់ទី១) និងផែនការថវិកា(ទម្រង់ទី២)។ | |
| | **ឧទាហរណ៍ ៖** ទិន្នន័យពីកម្មវិធីវិនិយោគឃុំប្រាប់យើងអំពីអាទិភាពបច្ចុប្បន្ន និងការបែងចែកធនធាន ហើយទិន្នន័យពីមណ្ឌលសុខភាពប្រាប់យើងអំពីចំនួនស្ត្រី ដែលបានមកពិនិត្យផ្ទៃពោះមុន ពេលសម្រាល និងមកពិនិត្យសុខភាពក្រោយពេលសម្រាល និងចំនួនស្ត្រីដែលបានមកសម្រាលកូននៅមណ្ឌលសុខភាព។<br>☞ **ការសង្ខេប ៖**<br>• រួមសេចក្តីមក ការប្រមូលទិន្នន័យពីប្រភពផ្សេងៗគ្នា វាជាបញ្ហាសំខាន់។ នៅពេលដែល គ.ក.ន.ក ប្រមូលនិងវិភាគទិន្នន័យ វានឹងជួយឱ្យពួកគេកំណត់ និងចាត់អាទិភាពបញ្ហាដែលធ្វើឱ្យប៉ះពាល់ដល់ស្ត្រី និងកុមារដែលងាយរងគ្រោះក្នុងឃុំសម្រាប់ធ្វើផែនការសកម្មភាពដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែង។<br>• នៅក្នុងជំហានបន្ទាប់ យើងនឹងហាត់អនុវត្តន៍វិភាគទិន្នន័យពីឃុំ អំពិល តាមរយៈសូចនាកររបស់ឃុំអំពិល កំណត់បញ្ហាអាទិភាពដើម្បីរៀបចំ សេវាសង្គមប្រកបដោយសមធម៌។ | |
| ១០៥នាទី | **៣. ការប្រើប្រាស់សូចនាករសំខាន់ៗដើម្បីរៀបចំផែនការសកម្មភាពប្រកបដោយសមធម៌និងឆ្លើយតបទៅនឹងតម្រូវការរបស់ស្ត្រីនិងកុមារ ព្រមទាំងជនដែលងាយរងគ្រោះ**<br>• បែងចែកក្រុមពិភាក្សាជា៦ក្រុម និងបែងចែកឯកសារសូចនាកររបស់ឃុំ អំពិល | |

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | |
|---|---|---|
| | (ចែកសិក្ខាកាមនូវសូចនាករតាមប្រធានបទ ដូចមានក្នុងឯកសារ ១.៤.១ និង ១.៤.២ ដូចខាងក្រោម)<br>– ក្រុមនីមួយៗត្រូវជ្រើសរើសអ្នកសម្របសម្រួលម្នាក់ និងអ្នកកត់ត្រាម្នាក់<br>– ក្រុមនីមួយៗត្រូវអាននូវសូចនាករដោយលម្អិត (៧នាទី)<br>– បន្ទាប់មកឆ្លើយតបនឹងសំណួរដូចខាងក្រោម (១៥នាទី)<br>~ តើទិន្នន័យទាំងនោះប្រាប់លោក លោកស្រីដូចម្តេចខ្លះ អំពីផែនការសកម្មភាពរបស់លោក លោកស្រី?<br>~ តើសូចនាករណាមួយដែលកំណត់អំពីស្ត្រី កុមារ និងជនងាយរងគ្រោះបំផុតក្នុងឃុំ អំពិល? ហេតុអ្វីបានជាបញ្ហាទាំងនេះ ជាបញ្ហាអាទិភាព?<br>– ៣ក្រុមឡើងបង្ហាញ និងក្រុមផ្សេងៗ ចូលរួមផ្តល់ជាយោបល់ (២៥នាទី)<br>– អ្នកសម្របសម្រួលធ្វើការបូកសរុប<br>– អ្នកសម្របសម្រួលឱ្យសិក្ខាកាមតាមក្រុមនីមួយពិភាក្សា (៤៥នាទី)<br>~ តើក្នុងនាមជាគ.ក.ន.ក ឬក្រុមប្រឹក្សាឃុំ សង្កាត់ លោក លោកស្រីមានបានរៀបចំផែនការអ្វីខ្លះ ដើម្បីឆ្លើយតបទៅនឹងការផ្តល់សេវាសង្គមប្រកបដោយសមធម៌?<br>~ សិក្ខាកាមពិភាក្សារៀបចំផែនការសកម្មភាព<br>~ តំណាងក្រុមនីមួយៗ បង្ហាញពីលទ្ធផលពិភាក្សាពីផែនការសកម្មភាពដល់ក្រុមផ្សេងៗ តាមវិធីសាស្ត្រលំហាត់ទីផ្សារព័ត៌មាន (ក្រុមនីមួយត្រូវប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់)។<br><br>**កំណត់ចំណាំ៖**<br>អ្នកសម្របសម្រួលធ្វើការគូសបញ្ជាក់ពីបញ្ហាសមធម៌ និងបញ្ជាក់ផងដែរថា សេវាសង្គមមិនមែនផ្តោតទៅលើតែបញ្ហាស្ត្រី និងកុមារប៉ុណ្ណោះទេ គឺផ្តោតផងដែរទៅលើបញ្ហាសុខភាពបន្តពូជ ការពន្យារកំណើត ការពិនិត្យសុខភាពមុនពេល និងក្រោយពេលសម្រាល បញ្ហាយុវជន ចាស់ជរា បញ្ហា ចំណាកស្រុកជាដើម។ ដូច្នេះ លោក លោកស្រីដែល ជា គ.ក.ន.ក ក៏ដូចជា ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវផ្តោតការយកចិត្តទុកដាក់ផងដែរទៅលើបញ្ហាទាំងអស់នោះ។<br><br>• អ្នកសម្របសម្រួលសួរសំណួរឆ្លុះបញ្ចាំងដូចខាងក្រោម៖ (១៥នាទី)<br>– ការហាត់ធ្វើលំហាត់នេះខុសគ្នាយ៉ាងដូចម្តេចជាមួយនឹងអ្វី ដែលធ្វើប្រចាំក្នុងការបង្កើតផែនការសកម្មភាពរបស់លោក លោកស្រី?<br>– តើលោក លោកស្រី រៀនសូត្របានអ្វីខ្លះ?<br>– តើលោក លោកស្រីនឹងផ្លាស់ប្តូរអ្វីខ្លះ នៅពេលបង្កើតផែនការសកម្មភាពសម្រាប់ឃុំរបស់លោក លោកស្រី? | |

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | |
|---|---|---|
| | • អ្នកសម្របសម្រួលធ្វើការកត់ត្រាចម្លើយរបស់សិក្ខាកាមដាក់លើក្រដាសផ្ទាំងធំ បន្ទាប់មកធ្វើការបូកសរុប<br>កំណត់ចំណាំ៖<br>• មុនពេលបញ្ចប់ផ្នែកអ្នកសម្របសម្រួលអាចឱ្យសិក្ខាកាមមើលខ្លួនឯងនូវទម្រង់ទី៥ នៃសៀវភៅណែនាំពីទំព័រ ៣៨ដល់៤២ | |
| ១០នាទី | **៤. ការឆ្លុះបញ្ចាំងដំណើរការពិភាក្សា**<br>• អ្នកសម្របសម្រួលនឹងដឹកនាំក្រុមធំដើម្បីធ្វើការឆ្លុះបញ្ចាំងទៅលើការងារជាក្រុម ៗ ខ្ញុំបានស្នើឱ្យលោក លោកស្រី ជ្រើសរើសអ្នកសម្របសម្រួលម្នាក់ និងអ្នកកត់ត្រា ម្នាក់ប្រចាំក្រុមនីមួយៗ។<br>ក). ក្នុងនាមជាអ្នកសម្រសម្រួលក្រុម តើមានអ្វីដែលជួយលោក លោកស្រី ដំណើរការសម្របសម្រួលក្រុមពិភាក្សាបាន?<br>ខ). ក្នុងនាមជាសមាជិកក្រុម តើអ្នកសម្របសម្រួលធ្វើយ៉ាងដូចម្តេច ដើម្បីជួយឱ្យអ្នកចូលរួមពិភាក្សាយ៉ាងសកម្ម?<br>គ). ក្នុងនាមជាអ្នកកត់ត្រាវិញ ថាតើលោក លោកស្រីគិតថាងាយស្រួលទេក្នុងការ កត់ត្រា និងសង្ខេបចំណុចសំខាន់ៗដែលបានពិភាក្សា? | |

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ឧបសម្ព័ន្ធ១**
រាជធានី ខេត្ត........................................
ក្រុង ស្រុក ខណ្ឌ..................................
ឃុំ សង្កាត់..........................................

**ផែនការសកម្មភាពប្រចាំឆ្នាំ..............**
**ស្តីពីការអភិវឌ្ឍផ្នែកសង្គមប្រកបដោយសមធម៌**

| ល.រ | សកម្មភាពនិងលទ្ធផល | លទ្ធផលគ្រោង | | ទីតាំង | អ្នកទទួលខុសត្រូវ | អ្នកទទួលផលផ្ទាល់ | | ខែ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ឯកតា | ចំនួន | | | ប្រុស | ស្រី | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ១ | ធានាការចុះអត្រានុកូលដ្ឋានឱ្យមានប្រសិទ្ធភាព | | | | | | | | | | | | | | | | | | |
| ២ | អប់រំអំពីសុខភាពបន្តពូជ ការពន្យារកំណើត ការថែទាំសុខភាពមុន និងក្រោយពេលសម្រាលកូន និងការសម្រាលនៅមណ្ឌលសុខភាព | | | | | | | | | | | | | | | | | | |
| ៣ | ការពារ និងការឆ្លើយតបចំពោះភាពពាក់ព័ន្ធនឹងកិច្ចការពារកុមារក្នុងចំណោមកុមារ និងគ្រួសារងាយរងគ្រោះបំផុត | | | | | | | | | | | | | | | | | | |
| ៤ | អប់រំអំពីការលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី និងកុមារ | | | | | | | | | | | | | | | | | | |
| ៥ | ធានាឱ្យមានសេវាសុខភាព និងអាហារូបត្ថម្ភនៅមូលដ្ឋាន និងទទួលបានសេវាកម្មសុខភាព និងអាហារូបត្ថម្ភមានគុណភាព | | | | | | | | | | | | | | | | | | |
| ៦ | អប់រំយុវជនយុវនារី អំពីសុខភាពបន្តពូជ ការប្រើប្រាស់គ្រឿងស្រវឹង និងគ្រឿងញៀន | | | | | | | | | | | | | | | | | | |
| ៧ | វិនិយោគទៅក្នុងសាលាមត្តេយ្យសិក្សាសហគមន៍ | | | | | | | | | | | | | | | | | | |
| ៨ | អប់រំលើកទឹកចិត្តដល់មនុស្សចាស់ឱ្យមានការចូលរួមអភិវឌ្ឍសង្គម និងលើកកម្ពស់ការថែទាំសុខភាព | | | | | | | | | | | | | | | | | | |
| ៩ | បង្កើនគុណភាព អនាម័យ ទឹកស្អាត និងរស់នៅស្អាតក្នុងសហគមន៍ | | | | | | | | | | | | | | | | | | |
| ១០ | ការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់ និងការឆ្លើយតប | | | | | | | | | | | | | | | | | | |
| ១១ | ការប្រជុំ និងតាមដានរបស់ គ.ក.ន.ក | | | | | | | | | | | | | | | | | | |

ថ្ងៃទី.................ខែ.................ឆ្នាំ...........
**មេឃុំ ចៅសង្កាត់**

ថ្ងៃទី.................ខែ.................ឆ្នាំ..........
**អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់**

**ឧបសម្ព័ន្ធទី២**

រាជធានី ខេត្ត.....................

ក្រុង ស្រុក ខណ្ឌ ................

ឃុំ សង្កាត់ ........................

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ផែនការថវិកាប្រចាំឆ្នាំ......................**

**សម្រាប់ការអភិវឌ្ឍផ្នែកសង្គមប្រកបដោយសមធម៌**

| ល.រ | មុខចំណាយ | ឯកតា | ចំនួន | តម្លៃឯកតា | សរុប |
|---|---|---|---|---|---|
| ១ | ធានាការចុះអត្រានុកូលដ្ឋានឱ្យមានប្រសិទ្ធភាព | | | | |
| ២ | អប់រំអំពីសុខភាពបន្តពូជ ការពន្យារកំណើត ការថែទាំសុខភាពមុននិងក្រោយសម្រាលកូន និងការសម្រាលនៅមណ្ឌលសុខភាព | | | | |
| | **សរុប** | | | | |
| ៣ | ការពារ និងការឆ្លើយតបចំពោះភាពពាក់ព័ន្ធនឹងកិច្ចការពារកុមារក្នុងចំណោមកុមារ និងគ្រួសារងាយរងគ្រោះបំផុត | | | | |
| ៤ | អប់រំអំពីការលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី និងកុមារ | | | | |
| | **សរុប** | | | | |
| ៥ | ធានាឱ្យមានការផ្តល់ និងទទួលបាននូវសេវាសុខភាពនៅតាមមូលដ្ឋានទាន់ពេលវេលា និងប្រកបដោយគុណភាព | | | | |
| ៦ | អប់រំយុវជនយុវនារីអំពីសុខភាពបន្តពូជ ការប្រើប្រាស់គ្រឿង ស្រវឹង និងគ្រឿងញៀន | | | | |
| | **សរុប** | | | | |
| ៧ | វិនិយោគទៅក្នុងសាលាមត្តេយ្យសិក្សាសហគមន៍ | | | | |
| ៨ | អប់រំលើកទឹកចិត្តដល់មនុស្សចាស់ឱ្យមានការចូលរួមអភិវឌ្ឍន៍សង្គម និងលើកកម្ពស់ការថែទាំសុខភាព | | | | |
| | **សរុប** | | | | |
| ៩ | បង្កើនគុណភាពអនាម័យ ទឹកស្អាត និងរស់នៅស្អាតក្នុងសហគមន៍ | | | | |
| | **សរុប** | | | | |
| ១០ | ការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់ និងការឆ្លើយតប | | | | |
| | **សរុប** | | | | |
| ១១ | ការប្រជុំ និងតាមដានរបស់ គ.ក.ន.ក | | | | |
| | **សរុប** | | | | |
| | សរុបរួម | | | | |

*ថ្ងៃទី.......ខែ........ឆ្នាំ..........*

**មេឃុំ ចៅសង្កាត់**

*ថ្ងៃទី.......ខែ........ឆ្នាំ..........*

**ស្មៀនឃុំ សង្កាត់**

## ឯកសារ ១.៤.១ ÷ សូចនាករឃុំអំពិល

| | |
|---|---|
| • ចំនួនទារកទើបនឹងកើតដែលបានចុះបញ្ជីនៅក្នុងរយៈពេល៣០ថ្ងៃ | ៥៥ក្នុងចំណោម១០០ |
| • ចំនួនអាពាហ៍ពិពាហ៍ដែលបានចុះបញ្ជី(នៅឆ្នាំថ្មីៗនេះ) | ២ក្នុងចំណោម២០ |
| • ចំនួនកុមារងាយរងគ្រោះដែលទទួលបានផលប្រយោជន៍តាមរយៈ វិធានការការពារ(ផ្តល់អាហារ មធ្យោបាយធ្វើដំណើរ សម្លៀកបំពាក់ឯកសណ្ឋានសាលាសិក្សា) | ៤៣ ក្នុងចំណោម៧០ |
| • ចំនួនកុមារមានអាយុក្រោម៥ឆ្នាំ ទទួលបានការបញ្ចុះសត្វល្អិតក្នុងរយៈពេល ៦ខែចុងក្រោយ តាមរយៈដំណើរការកសាងផែនការខ្នាតតូចមានប្រសិទ្ធភាព រវាងគណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព និងឃុំ | ២០០ ក្នុងចំណោម ១០៤២ |
| • តើកុមារទាំងអស់ដែលមានអាយុពី ៣ ទៅ ៥ឆ្នាំចូលរៀនក្នុងមត្តេយ្យសិក្សាសហគមន៍ទេ? | ទេ មានតែ ៨០០ ក្នុងចំណោម ១.៤៥៩ |
| • តើមត្តេយ្យសាលា សាលារៀន និងមណ្ឌលសុខភាពទាំងអស់បានកែលម្អអនាម័យអាងលាងដៃនឹងសាប៊ូ និងកន្លែងប្រើប្រាស់ទឹកស្អាតដែរឬទេ? | ទេ |
| • ចំនួនគ្រួសារដែលរងគ្រោះដោយសារគ្រោះធម្មជាតិដែលឃុំបានផ្តល់ការគាំទ្រ | ២០ |

## ឯកសារ ១.៤.២. សូចនាកររបស់ឃុំអំពិល

| ១. ធានាការចុះបញ្ជីអត្រានុកូលដ្ឋានឱ្យមានប្រសិទ្ធភាព | |
|---|---|
| សូចនាករ | |
| • ចំនួនប្រជាពលរដ្ឋសរុប | ១០,០០០ |
| • ចំនួនមនុស្សពេញវ័យសរុបបែងចែកតាមភេទ | ៦,០០០ (ប្រុស៣,០០០; ស្រី៣,០០០) |
| • ចំនួនកុមារសរុបបែងចែកតាមភេទ | ៤,០០០ (ប្រុស២,០០០; ស្រី២,០០០) |
| • ចំនួនទារកទើបនឹងកើតដែលបានចុះបញ្ជីនៅក្នុងរយៈពេល៣០ថ្ងៃ | ៥៥ ក្នុងចំណោម ១០០ |
| • ចំនួនអាពាហ៍ពិពាហ៍ដែលបានចុះបញ្ជី(នៅឆ្នាំថ្មីៗនេះ) | ២ ក្នុងចំណោម ២០ |
| • ចំនួនមរណៈភាពនៃទារកដែលបានចុះបញ្ជី(តិចជាង១ខែ) | ១ |
| • ចំនួនមរណៈភាពនៃកុមារដែលបានចុះបញ្ជី (តិចជាង១ឆ្នាំ) | ២ |
| • ចំនួនមរណៈភាពនៃកុមារដែលបានចុះបញ្ជី (តិចជាង៥ឆ្នាំ | ១ |
| • ចំនួនមរណៈភាពនៃកុមារដែលបានចុះបញ្ជី (តិចជាង១៨ឆ្នាំ) | ១ |
| • ចំនួនមរណៈភាពនៃមាតានៅពេលមានផ្ទៃពោះ ឬសម្រាលកូនរួចបានចុះបញ្ជី | ៣ |
| • ចំនួនមរណៈភាពនៃឪពុកដែលមានកូនបានចុះបញ្ជី | ២ |

| ២. កិច្ចការពារ និងការឆ្លើយតបចំពោះកុមាររងគ្រោះ កុមារងាយរងគ្រោះ និងក្រុមគ្រួសារងាយរងគ្រោះបំផុត | |
|---|---|
| សូចនាករ | |
| • ចំនួនកុមារងាយរងគ្រោះដែលទទួលបានផលប្រយោជន៍តាមរយៈវិធានការការពារ (ផ្តល់អាហារ មធ្យោបាយធ្វើដំណើរ សម្លៀកបំពាក់ ឯកសណ្ឋានសាលា សម្ភារសិក្សា) | ៤៣ ក្នុងចំណោម ៧០ |
| • ចំនួនស្ត្រី និងកុមារដែលធ្លាប់រងគ្រោះដោយអំពើហិង្សាបានបញ្ជូនទៅរកសេវាសមស្រប | ១ |
| • ចំនួនគ្រួសារដែលរងការប៉ះពាល់ដោយស្ថានភាពអាសន្ន និងទទួលបានជំនួយពីឃុំ | ២០ |

| ៣. ធានាឱ្យមានការផ្តល់សេវាសុខភាព និងអាហារូបត្ថម្ភនៅតាមមូលដ្ឋាន និងទទួលបានសេវាសុខភាពនិងអាហារូបត្ថម្ភប្រកបដោយគុណភាពទាន់ពេល | |
|---|---|
| សូចនាករ | |
| • ចំនួនស្ត្រីងាយរងគ្រោះមានផ្ទៃពោះ ដែលឃុំគាំទ្រឱ្យទៅពិនិត្យសុខភាពមុនពេលសម្រាលនៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យ យ៉ាងហោចណាស់ពីរដង | ២០ ក្នុងចំណោម ៥០ |
| • ចំនួនស្ត្រីងាយរងគ្រោះមានផ្ទៃពោះ ដែលឃុំគាំទ្រឱ្យទៅ សម្រាលកូននៅមណ្ឌលសុខភាព មន្ទីរពេទ្យរដ្ឋឬឯកជន | ២០ ក្នុងចំណោម ៥០ |
| • ចំនួនមាតាងាយរងគ្រោះមានកូនដំបូង និងទារកទើបនឹងកើត ដែលឃុំគាំទ្រឱ្យទៅពិនិត្យសុខភាពក្រោយពេលសម្រាលនៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យ យ៉ាងហោចណាស់មួយដង | ២០ ក្នុងចំណោម ៥០ |
| • ចំនួនទារកដែលបានចាក់ថ្នាំបង្ការគ្រប់មុខ តាមរយៈដំណើរការកសាងផែនការខ្នាតតូចរវាងគណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព និងឃុំ | ៥៥ ក្នុងចំណោម ១០០ |
| • ចំនួនទារកទើបនឹងកើត ខ្វះទម្ងន់ ដែលគ្រួសារទទួលបានការគាំទ្រពីឃុំ | ២០ ក្នុងចំណោម ១០០ |
| • ចំនួនកុមារខ្វះអាហារូបត្ថម្ភដែលគ្រួសារទទួលបានជំនួយពីឃុំ | ៣០ក្នុងចំណោម ១០០ |
| • ចំនួនប្រជាពលរដ្ឋដែលមានជម្ងឺរ៉ាំរ៉ៃទទួលបានជំនួយពីឃុំ | ៥ |
| • ចំនួនកុមារមានអាយុក្រោម៥ឆ្នាំ ទទួលបានការបញ្ចុះសត្វល្អិតក្នុងរយៈពេល ៦ខែចុងក្រោយតាមរយៈដំណើរការកសាងផែនការខ្នាតតូចមានប្រសិទ្ធភាពរវាងគណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព និង ឃុំ | ២០០ ក្នុងចំណោម ១,០៤២ |
| • ចំនួនកុមារមានអាយុក្រោម៥ឆ្នាំ ទទួលបានជីវជាតិអាបន្ថែម ក្នុងរយៈពេល ៦ខែ ចុងក្រោយ តាមរយៈដំណើរការកសាងផែនការខ្នាតតូចរមានប្រសិទ្ធភាពរវាងគណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព និងឃុំ | ២០០ ក្នុងចំណោម ១,០៤២ |
| • ចំនួនករណីជម្ងឺរាគ ដែលបានកំណត់ និងព្យាបាលទាន់ពេលតាមរយៈដំណើរការកសាង ផែនការខ្នាតតូចរមានប្រសិទ្ធភាពរវាងគណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព និងឃុំ | ២០០ |
| • ចំនួនមណ្ឌលសុខភាពដែលឃុំគាំទ្រឱ្យមានសម្ភារៈប្រសើរឡើង (ឧទាហរណ៍. គ្រែ ទឹកម៉ាស៊ីន អគ្គីសនី) | ១ |
| • ចំនួនមណ្ឌលសុខភាពដែលឃុំគាំទ្រឱ្យមានអនាម័យប្រសើរឡើង (ឧទាហរណ៍៖ បង្គន់ មានសាប៊ូ អាងលាងដៃ) | ១ |
| • ចំនួនមណ្ឌលសុខភាពដែលឃុំបានជួយផ្តល់ ទឹក ស្អាត | ១ |

| ៤. គាំទ្រមត្តេយ្យសិក្សាសហគមន៍ | |
|---|---|
| សូចនាករ | |
| • ចំនួនមត្តេយ្យសិក្សាសហគមន៍កំពុងដំណើរការ (ប្តូរវេន ពីរម៉ោងឬច្រើនជាង ក្នុងមួយសប្តាហ៍ក្នុងអំឡុងពេល៩ខែ) | ១ |
| • ចំនួនអ្នកគ្រូមត្តេយ្យសិក្សាសហគមន៍ដែលបានចុះកុងត្រារួច | ១ |
| • ចំនួន(លោកគ្រូ)មត្តេយ្យសិក្សាសហគមន៍ បានចុះកុងត្រានិង ដែលឃុំគាំទ្រឱ្យមាន អនាម័យប្រសើរឡើង | ០ |
| • ចំនួនមត្តេយ្យសិក្សាសហគមន៍ ដែលឃុំគាំទ្រឱ្យមានអនាម័យប្រសើរឡើង | ១ |
| • ចំនួនមត្តេយ្យសហគមន៍ដែលឃុំគាំទ្រឱ្យមានទឹកស្អាត | ១ |
| • ចំនួនកុមារមានអាយុ៣-៤ ឆ្នាំចុះឈ្មោះចូលរៀននៅមត្តេយ្យសាលា បែងចែក តាមភេទ ជនជាតិដើមភាគតិច និងពិការ | កុមារា ៧; កុមារី ៩ |
| • ចំនួនកុមារមានអាយុ៥ ឆ្នាំចុះឈ្មោះចូលរៀននៅមត្តេយ្យសាលា បែងចែកតាមភេទ ជនជាតិដើមភាគតិច និងពិការ | កុមារា៤; កុមារី៤ |
| • ចំនួនកុមារអាយុពី០ទៅ៥ឆ្នាំដែលមិនបានចុះឈ្មោះចូលរៀននៅក្នុងកម្មវិធីអប់រំកុមារ តូច (មត្តេយ្យសិក្សាសហគមន៍ មត្តេយ្យសិក្សារដ្ឋ កម្មវិធី អប់រំតាមផ្ទះ) | ៦២៧ |

| ៥. ធានាថា កុមារដែលមានអាយុពី ៦-១១ឆ្នាំបញ្ចប់ បឋមសិក្សា | |
|---|---|
| សូចនាករ | |
| • ចំនួនសាលាបឋមសិក្សាដែលឃុំគាំទ្រឱ្យមានការ កែលម្អអនាម័យ (ឧទាហរណ៍៖ បង្គន់ មានសាប៊ូលាងដៃ និងអាងលាងដៃ) | ១ |
| • ចំនួនសាលាបឋមសិក្សាដែលឃុំគាំទ្រឱ្យមានទឹកស្អាត | ១ |
| • ចំនួនកុមារនៅសាលាបឋមសិក្សាទទួលបានថ្នាំគ្រប់ទម្លាក់សត្វល្អិតអំឡុងពេល ការផ្តល់សេវាសុខភាពដល់មូលដ្ឋាន (ចំនួន២ដងក្នុង១ឆ្នាំដែលរៀបចំ ដោយមណ្ឌលសុខភាពនិងដោយមានការសហការជាមួយនឹងសាលា) | ៩០០ ក្នុងចំណោម ១,៤៥៩ |
| • ចំនួនកុមារមានអាយុ៦ ឆ្នាំចុះឈ្មោះចូលរៀននៅថ្នាក់ទី១ បែងចែកតាមភេទ ជនជាតិដើមភាគតិច និងពិការ | កុមារា៦៧ ក្នុងចំណោម១១៦; កុមារី ៧០ ក្នុងចំណោម១១៨ |
| • ចំនួនកុមារបោះបង់ចោលការសិក្សាដែលដែលឃុំគាំទ្រឱ្យមានឱ្យចូលរៀនវិញ បែងចែកតាមភេទ ជនជាតិដើមភាគតិច និងកុមារពិការ | កុមារា ២៨៦; កុមារី ២៧៥ |
| • អត្រាបញ្ចប់ការសិក្សាថ្នាក់បឋមសិក្សា បែងចែកតាមភេទ ជនជាតិដើមភាគតិច និងកុមារពិការ | ៦០% |

| ៦. កែលម្អសុវត្ថិភាពសហគមន៍ | |
|---|---|
| **សូចនាករ** | |
| • ចំនួនកុមារបួស (បែងចែកតាមអាយុ ប្រភេទរបួសដោយគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះ ធ្លាក់ ថ្នាំពុល ពស់ចឹក លង់ទឹក ត្រូវគ្រាប់ អំពើហិង្សា គ្រោះថ្នាក់តាមផ្លូវ) ដែលឃុំបានស៊ើប អង្កេតចាត់វិធានការការពារករណីទាំងនោះសម្រាប់អនាគត | ១៥ |
| • ចំនួនករណីចោរដែលប៉ូលីសប៉ុស្តិ៍ បានស៊ើបអង្កេត | ១ |
| • ចំនួនករណីហិង្សាក្នុងគ្រួសារដែលប៉ូលីសប៉ុស្តិ៍ បានស៊ើបអង្កេត | ១ |
| • ចំនួនករណីរំលោភដែលប៉ូលីសប៉ុស្តិ៍ បានស៊ើបអង្កេត | ០ |

## បញ្ជីត្រួតពិនិត្យសម្រាប់ការរៀបចំផែនការសកម្មភាព

| | ការពិពណ៌នា | បាន/បានទេ | ទេ |
|---|---|---|---|
| ១ | តើផែនការសកម្មភាពរបស់លោកអ្នកបានឆ្លើយតបនឹងតម្រូវការចាំបាច់របស់សហគមន៍ដែរឬទេ? | | |
| ២ | តើផែនការសកម្មភាពរបស់លោកអ្នកបានឆ្លើយតបនឹងតម្រូវការជាអាទិភាពរបស់ស្ត្រី កុមារ និងជនងាយរងគ្រោះឬទេ? | | |
| ៣ | តើផែនការសកម្មភាពរបស់លោកអ្នកបានឆ្លើយតបនឹងតម្រូវការរបស់ក្រុមជនជាតិភាគតិចឬទេ? | | |
| ៤ | តើផែនការសកម្មភាពរបស់លោកអ្នកបានឆ្លើយតបនឹងតម្រូវការរបស់សហគមន៍ ដែលមានហានិភ័យឬទេ? | | |
| ៥ | តើផែនការសកម្មភាពរបស់លោកអ្នកបានដោះស្រាយបញ្ហាទាក់ទំនងការថែទាំសុខភាពមាតាមុន និងក្រោយពេលសម្រាលកូនឬទេ? | | |
| ៦ | តើផែនការសកម្មភាពរបស់លោកអ្នកបានដោះស្រាយបញ្ហាទាក់ទំនងនឹងការជួញដូរស្ត្រី ការរំលោភបំពាន និងការកេងប្រវ័ញ្ចឬទេ? | | |
| ៧ | តើផែនការសកម្មភាពរបស់លោកអ្នកបានដោះស្រាយបញ្ហាទាក់ទំនងការអប់រំ ការរំលោភបំពានលើកុមារ និងការកេងប្រវ័ញ្ចកំលាំងពលកម្មឬទេ? | | |
| ៨ | តើផែនការសកម្មភាពរបស់លោកអ្នកបានដោះស្រាយបញ្ហាទាក់ទំនងការត្រៀមរៀបចំ និងការឆ្លើយតបនឹងភាពអាសន្នឬទេ? | | |

# ប្លង់មេរៀនទី៥
# ការកសាងផែនការថវិកាផ្តោតលើសមធម៌ និងការគៀរគរធនធាន

## ប្លង់មេរៀនទី៥

## ការកសាងផែនការថវិកាផ្តោតលើសមធម៌ និង ការគៀរគរធនធាន

| | |
|---|---|
| **គោលបំណង** | នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមអាច ៖<br>• រៀបចំផែនការថវិកាដែលមានលក្ខណៈជាក់លាក់ដោយផ្អែកលើផែនការសកម្មភាពដែលបានសិក្សារួចក្នុងមេរៀនទី៤<br>• បង្ហាញការយល់ដឹងពីសេវាសង្គមប្រកបដោយសមធម៌ តាមរយៈការបែងចែកធនធានរបស់ពួកគេ ក្នុងវិធីមួយដែលឆ្លើយតបនឹងសេចក្តីត្រូវការ របស់ស្ត្រី កុមារ និងជនងាយរងគ្រោះ |
| **ខ្លឹមសារមេរៀន** | • ប្រើប្រាស់សៀវភៅណែនាំអំពីការអនុវត្តមុខងាររបស់ គ.ក.ន.ក ដើម្បីលើកផែនការថវិកាដោយផ្តោតលើសមធម៌<br>• ការគៀងគរធនធាន |
| **រយៈពេល** | ៦០នាទី |
| **សម្ភារៈ** | • ប៊ិចហ្វឺត ក្រដាសផ្ទាំងធំ កាតពណ៌ ស្លាយបញ្ចាំង<br>• កូនសៀវភៅណែនាំសម្រាប់សមាជិក គ.ក.ន.ក ផ្នែកទី៥ អំពីការកសាងផែនការថវិកាផ្តោតលើសមធម៌ និងការគៀរគរធនធាន |
| **វិធីសាស្ត្រ** | ការងារក្រុមតូច ការពិភាក្សាក្នុងក្រុមធំ និង បទបង្ហាញ |

**ដំណើរការសម្របសម្រួល ÷**

| **រយៈពេល** | **ជំហាន និងវិធីសាស្ត្រ** | **ធនធាន** |
|---|---|---|
| ០៥នាទី | **១. សេចក្តីផ្តើម និងគោលបំណងមេរៀន**<br>• សេចក្តីផ្តើម៖ កាលពីមេរៀនមុន លោកអ្នកធ្វើការនៅក្នុងក្រុម គ.ក.ន.ក របស់អ្នក ដោយផ្អែកលើស្ថានភាពឃុំអំពិល ដើម្បីបង្កើតផែនការសកម្មភាពក្នុងការ ដោះស្រាយបញ្ហាប្រឈមជាអាទិភាពចំពោះស្ត្រី កុមារ និងជនងាយរងគ្រោះក្នុងឃុំ សង្កាត់របស់អ្នក។ មេរៀននេះនឹងផ្តោតទៅលើការរៀបចំ ផែនការថវិកាប្រកបដោយសមធម៌។ អ្នកសម្របសម្រួលបង្ហាញពីគោលបំណងមេរៀនទី៥ | |
| ៥០នាទី | **២. ធនធាន និងប្រភពធនធាន**<br>**ក). ការពិភាក្សាក្រុម**<br>• អ្នកសម្របសម្រួលរំលឹកពីសកម្មភាពដែលកំណត់ដោយក្រុមពិភាក្សា និងចែកសិក្ខាកាមតាមក្រុមដដែល និងសួរសំណួរបំផុសមួយចំនួនទៅសិក្ខាកាម ៖ | |

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | ធនធាន |
| --- | --- | --- |
| | – តើលោក លោកស្រីមានធនធានអ្វីខ្លះ ដើម្បីឆ្លើយតបសកម្មភាព ដែលលោក លោកស្រីបានលើកឡើងនៅមេរៀនទី៤? តើប្រភពធនធានទាំងនោះបានមកពីណាខ្លះ?<br>– តើធ្វើដូចម្តេច ដើម្បីកៀរគរថវិកា?<br>• ក្រុមនីមួយៗ ត្រូវពិភាក្សាសំណួរទាំងពីរ។ អ្នកសម្របសម្រួលជ្រើសរើសសិក្ខាកាមស្ម័គ្រចិត្ត២ ក្រុមដើម្បីចែករំលែកចម្លើយរបស់ពួកគេ។<br>• អ្នកកត់ត្រា កត់ត្រានូវចម្លើយរបស់សិក្ខាកាមដាក់លើក្រដាសផ្ទាំងធំ។<br>• អ្នកសម្របសម្រួលបង្ហាញខ្លឹមសារទាក់ទងនឹងធនធាន ព្រមទាំងប្រភពនៃធនធាន។<br><br>**៣. លំហាត់អនុវត្តការរៀបចំផែនការថវិកាប្រកបដោយសមធម៌**<br>**ក). ការពិភាក្សាក្រុមតូច**<br>• អ្នកសម្របសម្រួលឱ្យសិក្ខាកាមធ្វើការក្នុងក្រុមរៀបចំផែនការដែលក្រុមនីមួយៗត្រូវរៀបចំផែនការថវិកា ឆ្លើយតបទៅនឹងសកម្មភាពដែលបានកំណត់ ដោយផ្តោតទៅលើបញ្ហាសមធម៌។<br>• បន្ទាប់មក អ្នកសម្របសម្រួលត្រូវបង្ហាញអំពីទម្រង់ថវិកា ដូចដែលបានផ្តល់ជូនក្នុងកូនសៀវភៅណែនាំ ហើយស្នើឱ្យក្រុមបំពេញទម្រង់នោះ។ (សូមមើលឯកសារភ្ជាប់)<br>– ដំបូងបង្កើតផែនការថវិកាដោយប្រើប្រាស់ទិន្នន័យរបស់ឃុំអំពិល<br>– បន្ទាប់មកសួរថា៖ ដោយផ្អែកតាមអ្វីដែល លោក លោកស្រីបានសិក្សាថ្ងៃនេះ តើលោក លោកស្រីនឹងពិនិត្យ និងកែសម្រួលឡើងវិញនូវផែនការថវិការបស់ឃុំលោក លោកស្រីយ៉ាងដូចម្តេច?<br>**កំណត់ចំណាំ ៖**<br>– អ្នកសម្របសម្រួលគួរតែរំលឹកសិក្ខាកាមឡើងវិញកាលពីថ្ងៃទីមួយ នៅពេលដែលពិភាក្សាគ្នាអំពីសមធម៌ និងធានាថា សិក្ខាកាមអាចរំលឹកឡើងវិញអំពីអត្ថន័យនៃពាក្យសមធម៌។<br>– អ្នកសម្របសម្រួលគួរតែបញ្ជាក់អំពីសារៈសំខាន់នៃការធានាថា ការបែងចែកធនធានរបស់ គ.ក.ន.ក ប្រកបដោយសមធម៌ ដើម្បីដោះស្រាយបញ្ហាជាអាទិភាពរបស់ស្ត្រី និងកុមារ ។<br>– ក្រុមពិភាក្សានឹងបែងចែកមូលនិធិឱ្យសមស្របតាមសកម្មភាព | |

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| | អន្តរាគមន៍ដូចដែលបានកំណត់ក្នុងផែនការ។ ឧទាហរណ៍ ៖ ការធានាថា មានថវិកាសម្រាប់អប់រំស្ត្រីអំពីសុខភាពមាតាក្រោយពេលសម្រាល ឬមានថវិកាសម្រាប់ទឹកស្អាតនិងមានសុវត្ថិភាពសម្រាប់កុមារនៅតាមសាលារៀន ។<br><br>**ខ). ការឆ្លុះបញ្ចាំងក្នុងក្រុមធំ**<br>• បន្ទាប់ពីគណៈកម្មាធិការនីមួយៗ បានបំពេញនូវផែនការថវិការបស់ខ្លួនរួចមក អ្នកសម្របសម្រួលនឹងដឹកនាំការពិភាក្សាក្នុងក្រុមធំអំពីការលើកផែនការថវិកាប្រកបដោយសមធម៌ និងការគៀងគរធនធាន។<br>• អ្នកសម្របសម្រួលសួរសំណួរទៅកាន់គណៈកម្មាធិការថា ៖<br>១. តើលោកអ្នកបានរៀនសូត្រអ្វីខ្លះអំពីការលើកផែនការថវិកាប្រកបដោយសមធម៌?<br>២. តើលោកអ្នកនឹងចែករំលែកមេរៀនទាំងយ៉ាងដូចម្តេចដល់សមាជិក គ.ក.ន.ក ផ្សេងទៀត ឬ ដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់?<br>• អំឡុងពេលដែលអ្នកសម្របសម្រួលដឹកនាំការពិភាក្សា អ្នកកត់ត្រាត្រូវជួយសរសេររាល់សំណួរ បញ្ហាប្រឈម និងចម្លើយទាំងនោះ ដាក់លើក្រដាសផ្ទាំងធំ។<br>• អ្នកសម្របសម្រួលនឹងចែកផែនការថវិកាជាឧទាហរណ៍របស់ឃុំអំពិលដល់សិក្ខាកាមដូចដែលមានក្នុងកូនសៀវភៅណែនាំពីទំព័រទី ២៣-៣៥។ | |
| ៥នាទី | **៤. សន្និដ្ឋានបញ្ចប់មេរៀន**<br>• សង្ខេបមេរៀន<br>• តើអ្នកបានរៀនចំណុចសំខាន់អ្វីខ្លះពីមេរៀននេះ?<br>• ថ្លែងអំណរគុណសិក្ខាកាមដែលបានចូលរួមផុសផុល | |

**ឧបសម្ព័ន្ធទី២**

រាជធានី ខេត្ត ៖ ...........................
ក្រុង ស្រុក ខណ្ឌ ៖ .........................
ឃុំ សង្កាត់ ៖ ...............................

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ផែនការថវិកាប្រចាំឆ្នាំ.........................**

**សម្រាប់ការអភិវឌ្ឍផ្នែកសង្គមប្រកបដោយសមធម៌**

| លរ | មុខចំណាយ | ឯកតា | ចំនួន | តម្លៃឯកតា | សរុប |
|---|---|---|---|---|---|
| ១ | ធានាការចុះអត្រានុកូលដ្ឋានឱ្យមានប្រសិទ្ធភាព | | | | |
| | | | | | |
| | សរុប | | | | |
| ២ | ការពារ និងការឆ្លើយតបចំពោះភាពពាក់ព័ន្ធនឹងកិច្ចការពារកុមារក្នុងចំណោមកុមារ និងគ្រួសារងាយរងគ្រោះបំផុត | | | | |
| | | | | | |
| | សរុប | | | | |
| ៣ | ធានាឱ្យមានសេវាសុខភាពនិងអាហាររូបត្ថម្ភនៅមូលដ្ឋាន និងទទួលបានសេវាកម្មសុខភាព និងអាហាររូបត្ថម្ភមានគុណភាពទាន់ពេលវេលា | | | | |
| | | | | | |
| | សរុប | | | | |
| ៤ | វិនិយោគទៅក្នុងសាលាមត្តេយ្យសិក្សាសហគមន៍ | | | | |
| | | | | | |
| | សរុប | | | | |
| ៥ | បង្កើនគុណភាព អនាម័យ ទឹកស្អាត និងរស់នៅស្អាតក្នុងសហគមន៍ | | | | |
| | | | | | |
| | សរុប | | | | |
| ៦ | ការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់ និងការឆ្លើយតប | | | | |
| | | | | | |
| | សរុប | | | | |
| ៧ | ការប្រជុំនិងតាមដានរបស់ គ.ក.ន.ក | | | | |
| | | | | | |
| | សរុប | | | | |
| | សរុបរួម | | | | |

ថ្ងៃទី....... ខែ........... ឆ្នាំ...........

**មេឃុំ ចៅសង្កាត់**

ថ្ងៃទី........ ខែ......... ឆ្នាំ...............

**ស្មៀនឃុំ សង្កាត់**

**អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់**

# ប្លង់មេរៀនទី៦

# ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

# និងរបាយការណ៍

| ប្លង់មេរៀនទី៦ | |
|---|---|
| **ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ និងរបាយការណ៍** | |
| **គោលបំណង** | នៅចុងបញ្ចប់នៃមេរៀនសិក្ខាកាមនឹងអាច ៖<br>• រៀបរាប់បានពីមូលហេតុសំខាន់ៗ ដើម្បីតាមដានត្រួតពិនិត្យ និងវាយតម្លៃ និងរបៀបប្រើប្រាស់ទិន្នន័យ ដើម្បីត្រួតពិនិត្យការរីកចម្រើន<br>• ប្រើប្រាស់សូចនាករនៃសេវាសង្គមប្រកបដោយសមធម៌<br>• កំណត់បាននូវប្រភពទិន្នន័យ និងទិន្នន័យដែលត្រូវការសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ<br>• បំពេញបានទម្រង់តាមដានត្រួតពិនិត្យ និងវាយតម្លៃ និងទម្រង់របាយការណ៍ ដូចដែលបានផ្តល់ជូនក្នុងកូនសៀវភៅណែនាំ |
| **ខ្លឹមសារមេរៀន** | • និយមន័យ និងមូលហេតុនៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃ និងពាក្យគន្លឹះផ្សេងៗ<br>• ប្រភព និងតម្រូវការព័ត៌មានសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ<br>• របៀបបំពេញទម្រង់តាមដានត្រួតពិនិត្យ និងវាយតម្លៃ និងទម្រង់របាយការណ៍ ដែលមាននៅក្នុងសៀវភៅណែនាំ |
| **រយៈពេល** | ១០០ នាទី |
| **សម្ភារៈ** | ហ្វីត ក្រដាសពណ៌ ក្រដាសផ្ទាំងធំ ស្លាយ សៀវភៅណែនាំសម្រាប់ គ.ក.ន.ក ផ្នែកទី៦ អំពីការតាមដានត្រួតពិនិត្យ និងវាយតម្លៃ និងរបាយការណ៍ |
| **វិធីសាស្ត្រ** | ការពិភាក្សាក្រុមតូច ការពិភាក្សាក្រុមធំ និងការបង្ហាញ |

**សកម្មភាពសម្របសម្រួលមេរៀន ÷**

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| ៥នាទី | **១. សេចក្តីផ្តើម និងការបង្ហាញពីគោលបំណង**<br>• អ្នកសម្របសម្រួលបញ្ជាក់ថា យើងបានសិក្សាមេរៀនមួយចំនួនរួចហើយ ដែលទាក់ទងនឹងការងាររបស់ គ.ក.ន.ក ឥឡូវនេះយើងនឹងសិក្សាបន្ថែមទៀតអំពីរបៀបតាមដានត្រួតពិនិត្យ និងវាយតម្លៃ និងរបាយការណ៍ ដើម្បីធានាថា គ.ក.ន.ក ធ្វើការងារប្រកបដោយគុណភាព និងប្រសិទ្ធភាព។ បន្ទាប់មកអ្នកសម្របសម្រួលបង្ហាញអំពីគោលបំណងមេរៀន ។ | |
| ១៥ នាទី | **២. ការយល់ដឹងពីគោលបំណងនៃការត្រួតពិនិត្យ និងវាយតម្លៃ និងពាក្យគន្លឹះ**<br>**សំណួរបំផុសគំនិត**<br>**ជំហានទី១ ៖**<br>• អ្នកសម្របសម្រួលសួរសិក្ខាកាមក្នុងក្នុងក្រុមធំ ដើម្បីរំលឹកឡើងវិញអំពីតួនាទី និងការទទួលខុសត្រូវរបស់ គ.ក.ន.ក។ បន្ទាប់មកអ្នកសម្របសម្រួលសួរសំណួរខាងក្រោម ៖<br>– តើលោក លោកស្រីនឹងធ្វើយ៉ាងដូចម្តេចទើបដឹងថា គ.ក.ន.ក បំពេញ | |

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| | តួនាទី និងការទទួលខុសត្រូវរបស់ខ្លួនបានជោគជ័យ?<br>– តើលោក លោកស្រីនឹង ធ្វើការតាមដានត្រួតពិនិត្យការរីកចម្រើន យ៉ាងដូច ម្តេច?<br>– តើលោក លោកស្រីធ្វើយ៉ាងដូចម្តេចទើបដឹងថា គណៈកម្មាធិការ បំពេញ មុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងសមធម៌?<br>– ហេតុអ្វីបានជា គ.ក.ន.ក ចូលរួមក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ?<br>• អ្នកសម្របសម្រួលឱ្យសិក្ខាកាម ១ ឬ ២នាក់ឆ្លើយតបនឹងសំណួរខាងលើ<br>**ជំហានទី២ ៖**<br>• អ្នកសម្របសម្រួលបង្ហាញអំពីពាក្យគន្លឹះមួយចំនួនទាក់ទងនឹងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ និងវែកញែកឱ្យដាច់រវាងពាក្យសកម្មភាព លទ្ធផល រំពឹងទុក និងសូចនាករនៃសេវាសង្គមប្រកបដោយសមធម៌។<br>• អ្នកសម្របសម្រួលបង្ហាញខ្លឹមសារមេរៀន ។<br>☞ **និយមន័យ ៖**<br>– **សូចនាករ** ៖ គឺជាព័ត៌មានបង្ហាញពីកម្រិតវាស់វែងជាបរិមាណ ឬគុណភាពដែលអាចជឿទុកចិត្តបានសម្រាប់វាយតម្លៃលទ្ធផលរីកចម្រើន និង ការផ្លាស់ប្តូរ<br>**សកម្មភាព** ៖ គឺកិច្ចការដែលត្រូវអនុវត្ត ដើម្បីធ្វើឱ្យសម្រេច គោលបំណង | |
| ៣៥នាទី | **៣. ការកំណត់តម្រូវការព័ត៌មាន និងប្រភពព័ត៌មានសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ**<br>• អ្នកសម្របសម្រួលឱ្យសិក្ខាកាមមើលទម្រង់ទី៥ ៖ សូចនាករនៃសេវាសង្គមប្រកបដោយសមធម៌ក្នុងកូនសៀវភៅណែនាំ<br>• បែងចែកសិក្ខាកាមជា៦ក្រុម ពិភាក្សាលើប្រធានបទចំនួន៦ ៖ កិច្ចការសម្រាប់កិច្ចការស្ត្រី និងកុមារ សុខភាព អប់រំ ការចុះបញ្ជីអត្រានុកូលដ្ឋាន សន្តិសុខ និងសណ្តាប់ធ្នាប់ និងហិរញ្ញវត្ថុ។<br>• អ្នកសម្របសម្រួលសួរសំណួរបំផុសដូចខាងក្រោម ៖<br>– តើលោក លោកស្រីចង់សម្រេចអ្វីខ្លះក្នុងនាមជាសមាជិក គ.ក.ន.ក នៅ ក្នុងផ្នែកនីមួយៗ?។ ឧទាហរណ៍៖ ផ្នែកអត្រានុកូលដ្ឋាន<br>– អ្នកសម្របសម្រួលឱ្យសិក្ខាកាមពិនិត្យមើលសូចនាករ និងអ្វីដែលត្រូវសម្រេចឱ្យបាន (នៅក្នុងទម្រង់ទី៥)<br>– តើលទ្ធផលដែលសម្រេចបាននេះត្រូវវាស់វែងយ៉ាងដូចម្តេច? (ធ្វើដូចម្តេចទើបដឹងថាជោគជ័យ ឬមានប្រសិទ្ធភាព?) | |

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| | – តើព័ត៌មានអំពីអ្វីខ្លះ ដែលលោក លោកស្រីត្រូវការ ដើម្បីវាស់វែងអំពីការរីកចម្រើន?<br>– តើលោក លោកស្រី ស្វែងរកទិន្នន័យពីប្រភពណាខ្លះ?<br>– តើលោក លោកស្រី ត្រូវការតាមដានត្រួតពិនិត្យញឹកញាប់ប៉ុណ្ណា?<br>កំណត់ចំណាំ ៖<br>• អ្នកសម្របសម្រួលគួរសួរបញ្ជាក់ឱ្យច្បាស់ថា តើមានសមាជិក គ.ក.ន.ក ណាខ្លះដែលអាចប្រើប្រាស់សូចនាករផែនទីសេវាសង្គម ទិន្នន័យភូមិ ឃុំ និងសូចនាករនៃសេវាសង្គមប្រកបដោយសមធម៌ (ដូចដែលបានពិភាក្សាក្នុងមេរៀនទី៤)<br>• អ្នកសម្របសម្រួលគួរលើកបញ្ជាក់បន្ថែមទៀតថា ទំនាក់ទំនងរវាងទិន្នន័យផែនទីសេវាសង្គម និងទិន្នន័យភូមិ ឃុំមានសារៈសំខាន់ណាស់សម្រាប់ គ.ក.ន.ក យល់ដឹង ឱ្យច្បាស់ និងវិភាគឱ្យបានស៊ីជម្រៅអំពីបញ្ហាជាក់លាក់ និង ដើម្បីកំណត់អំពីការឆ្លើយតបដែលសមស្របត្រឹមត្រូវ។ | |
| ៤០នាទី | **៤. ការអនុវត្តបំពេញទម្រង់ត្រួតពិនិត្យ និងវាយតម្លៃ និងទម្រង់របាយការណ៍**<br>**ក). បទបង្ហាញស្តីពីទម្រង់ត្រួតពិនិត្យ និងវាយតម្លៃ និងទម្រង់របាយការណ៍**<br>• អ្នកសម្របសម្រួលបញ្ជាក់ថា យើងបានពិភាក្សាគ្នារួចហើយពីព័ត៌មានដែលត្រូវការប្រភពព័ត៌មាន និងរបៀបប្រមូលព័ត៌មានទាំងនោះ។ ឥឡូវនេះគិតថា ជាពេលដែលត្រូវធ្វើរបាយការណ៍ជូនទៅ គ.ក.ន.ក.(ប្រជុំប្រចាំខែ ត្រីមាស ឆមាស ឬប្រចាំឆ្នាំ ឬអ្នកទៅចូលរួមប្រជុំប្រចាំត្រីមាសជាមួយ គ.ក.ស.ក ថ្នាក់ស្រុក។<br>**ខ). បទបង្ហាញពីទម្រង់របាយការណ៍**<br>• អ្នកសម្របសម្រួលបង្ហាញទម្រង់ទាំងនោះ និងឱ្យសិក្ខាកាមអានឯកសារនៅក្នុងសេចក្តីណែនាំពីទំព័រទី៤៦ ដល់៥៨។<br>**គ). អនុវត្តបំពេញទម្រង់របាយការណ៍**<br>• បែងចែកសិក្ខាកាមជា៦ក្រុម ដើម្បីហាត់បំពេញទម្រង់របាយការណ៍ រួមមាន ៖ របាយការណ៍សកម្មភាពទាក់ទងនឹងស្ត្រី និងកុមារនៅក្នុងឃុំសង្កាត់ របាយការណ៍ស្តីពីសុខភាព អប់រំ អត្រានុកូលដ្ឋាន និងរបាយការណ៍ស្តីពីបញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់ និងហិរញ្ញវត្ថុ។<br>• សិក្ខាកាមអាចបំពេញទម្រង់របាយការណ៍ផ្សេងទៀត បើពួកគេចង់ហាត់អនុវត្តន៍។ | |

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| | ឃ). សំណួរឆ្លុះបញ្ចាំង<br>• តើលោក លោកស្រីមានអារម្មណ៍បែបណានៅពេលបំពេញទម្រង់របាយការណ៍?<br>• តើរបាយការណ៍នេះដូចគ្នានឹងអ្វីដែលលោក លោកស្រីធ្លាប់ធ្វើ ឬមានលក្ខណៈខុសគ្នា? | |
| ៥នាទី | **៥. សន្និដ្ឋាន**<br>• សង្ខេបមេរៀន<br>• តើអ្នកបានរៀនចំណុចសំខាន់អ្វីខ្លះពីមេរៀននេះ?<br>• ថ្លែងអំណរគុណសិក្ខាកាមដែលបានចូលរួមផុសផុល។ | |

# ផ្នែកទី២

# ការផ្តោតស៊ីជម្រៅលើសមធម៌សង្គម

# ប្លង់មេរៀនទី១

# ធ្វើការជាមួយសហគមន៍

# ដើម្បីត្រៀមបម្រុងសម្រាប់ការសង្គ្រោះ

# បន្ទាន់ និងការដោះស្រាយ

| | |
|---|---|
| **ប្លង់មេរៀនទី១**<br>**ធ្វើការជាមួយសហគមន៍ដើម្បីត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់ និងការដោះស្រាយ** | |
| **គោលបំណង** | នៅចុងបញ្ចប់នៃមេរៀននេះសិក្ខាកាមទាំងអស់នឹងអាចៈ<br>• យល់ពីសារៈសំខាន់នៃការកសាងសហគមន៍ឱ្យរឹងមាំ<br>• យល់ដឹងពីរបៀបដែល គ.ក.ន.ក ធ្វើការជាមួយសហគមន៍ដើម្បីត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់និងការដោះស្រាយ |
| **ខ្លឹមសារមេរៀន** | ១. ផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ<br>២.គ្រោះមហន្តរាយអាចបង្អាក់ការអភិវឌ្ឍកុមារ<br>៣. សហគមន៍ងាយរងគ្រោះ<br>៤. សហគមន៍រឹងមាំ<br>៥. ការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់<br>៦. បញ្ជីប៉ាន់ប្រមាណបន្ទាន់ |
| **រយៈពេល** | ១ម៉ោង៣០នាទី |
| **សម្ភារៈ** | • ហ្វីតក្រដាសព័ណ៌ក្រដាសផ្ទាំងធំឯកសារ ស្លាយបញ្ចាំង<br>• សៀវភៅណែនាំសម្រាប់សមាជិកគ.ក.ន.កផ្នែកទីពីរ មេរៀនទី១ទំព័រ៥៩ និង<br>• សៀវភៅជំនួយស្មារតី |
| **វិធីសាស្ត្រ** | ការពិភាក្សាក្រុមតូចការពិភាក្សាក្រុមធំការសម្តែងតួ និងការបញ្ចាំងស្លាយ |

**សកម្មភាពសម្របសម្រួលមេរៀន ÷**

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| ៥នាទី | **១. ការបង្ហាញគោលបំណងនៃមេរៀន**<br>• អ្នកសម្របសម្រួល ៖ សូមស្វាគមន៍ចំពោះមេរៀនទីមួយរបស់យើងគឺ "ធ្វើការជាមួយសហគមន៍ដើម្បីត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់និងការដោះស្រាយ" ៖<br>– ឃុំនីមួយៗមានបទពិសោធន៍ពីគ្រោះមហន្តរាយមិនដូចគ្នាទេ។<br>– ឃុំខ្លះអាចជួបប្រទះនឹងគ្រោះទឹកជំនន់ឃុំខ្លះអាចជួបប្រទះនឹងបញ្ហាភ្លើង ឆេះព្រៃនិងខ្លះទៀត អាចជួបប្រទះនឹងព្យុះភ្លៀង។ល។<br>– ទោះបីជាបទពិសោធបែបណាក៏ដោយក៏គ្រោះមហន្តរាយជះឥទ្ធិពលដល់សហគមន៍ទាំងមូល ជាពិសេសការជះឥទ្ធិពលដោយគ្មានសមាមាត្រទៅ លើជនដែលងាយរងគ្រោះបំផុត។<br>– នៅក្នុងមេរៀននេះនឹងមានការរំលឹកឡើងវិញខ្លះៗ ពីការជះឥទ្ធិពលនៃគ្រោះអាសន្នទៅលើស្ត្រី និងកុមារ។<br>– យើងក៏មើលផងដែរថា តើ គ.ក.ន.ក នឹងធ្វើរបៀបណា ក្នុងការធ្វើការ | |

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| | ជាមួយសហគមន៍ ដើម្បីត្រៀមបម្រុងនិងដោះស្រាយចំពោះគ្រោះសន្ទ។ | |
| ២៥នាទី | **២. ការកសាងសហគមន៍ឱ្យមានភាពរឹងមាំ**<br>**២.១. គ្រោះមហន្តរាយជះឥទ្ធិពលដល់ស្ត្រីនិងកុមារ**<br>• សណ្តួរបំផុសគំនិត ៖<br>– តើការបម្រែបម្រួលអាកាសធាតុមានផលប៉ះពាល់អ្វីខ្លះ?<br>• អ្នកសម្របសម្រួល ៖<br>– បង្ហាញ "ផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ"<br>– ផ្សាភ្ជាប់ខ្លឹមសារនៃផលប៉ះពាល់នីមួយៗ ទៅនឹង៖<br>~ ផលប៉ះពាល់ដល់កុមារ<br>~ ការថប់អារម្មណ៍ និងភាពងាយរងគ្រោះរបស់កុមារ<br>**២.២. សហគមន៍ងាយរងគ្រោះ**<br>• សណ្តួរបំផុសគំនិត ៖<br>– តើអ្វីទៅជាសហគមន៍ងាយរងគ្រោះ?<br>– តើមានសមាសភាពអ្វីខ្លះដែលចង្អុលបង្ហាញថាសហគមន៍មួយងាយរងគ្រោះ ឬរឹងមាំ?<br>• អ្នកសម្របសម្រួល ៖<br>– សហគមន៍មួយចំនួនងាយនឹងទទួលភាពរងគ្រោះជាងសហគមន៍ឯទៀត<br>– ភាពងាយរងគ្រោះនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងភាពក្រីក្រនិងភាពនៅដាច់ឆ្ងាយពីសង្គម<br>– ភាពងាយរងគ្រោះមានសមាសភាពសំខាន់ៗពីរ៖<br>១. ហានិភ័យ ៖ ទឹកជំនន់វិបត្តិសេដ្ឋកិច្ចការប្រមូលផលមិនបាន សង្គ្រាម ភាពអត់ការងារធ្វើនិងជំងឺធ្ងន់ផ្សេងៗ។<br>២. សមត្ថភាព ៖ សមត្ថភាពឆ្លើយតបទៅនឹងគ្រោះមហន្តរាយ និងសមត្ថភាពសម្របខ្លួននៅពេលដែលជួបគ្រោះមហន្តរាយ។<br>• សណ្តួរបំផុសគំនិត ៖<br>– តើគ្រោះមហន្តរាយជះឥទ្ធិពលអ្វីខ្លះដល់អារម្មណ៍ និងសកម្មភាពជនរងគ្រោះ?<br>☞ **សញ្ញាណខ្លះៗនៃការកើនឡើងនូវភាពតានតឹងផ្លូវចិត្ត ៖**<br>– ប្រើប្រាស់គ្រឿងស្រវឹងនិងថ្នាំញៀន<br>– ខឹង(ឆាប់ផ្ទុះកំហឹង)<br>– នៅដាច់ឆ្ងាយពីសង្គម<br>– មានការថប់អារម្មណ៍និងបាក់ទឹកចិត្ត | |

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| | – សម្ពន្ធភាពប្រេះឆា<br>– ខ្វះការយកចិត្តទុកដាក់លើការរៀនសូត្រការងារ និងលទ្ធផលការងារធ្លាក់ចុះ<br>– មានជំងឺរ៉ាំរ៉ៃ រោគសញ្ញាមិនច្បាស់លាស់ឬមូលហេតុមិនគ្រប់គ្រាន់។<br>**២.៣. សហគមន៍រឹងមាំ**<br>• សណ្ដូរបំផុសគំនិត ៖<br>– តើអ្វីទៅជាសហគមន៍រឹងមាំ?<br>• អ្នកសម្របសម្រួល ៖<br>– ភាពរឹងមាំ៖ គឺជាសមត្ថភាពនៃប្រព័ន្ធមួយ ដូចជាសហគមន៍ ឬសង្គមក្នុងការសម្របខ្លួនឱ្យត្រឡប់មកដំណើរការល្អឡើងវិញបន្ទាប់ពីជួបគ្រោះមហន្តរាយណាមួយ។<br>– នេះមានន័យថាសហគមន៍នោះអាចបង្កើនសមត្ថភាពរបស់ខ្លួនតាមរយៈគ្រោះមហន្តរាយពីអតីតកាលនិងសម្រាប់ការការពារពេលអនាគត និងធ្វើឱ្យប្រសើរឡើងនូវវិធានការកាត់បន្ថយហានិភ័យ។<br>• សណ្ដូរបំផុសគំនិត ៖<br>– តើមូលហេតុអ្វីខ្លះដែលធ្វើឱ្យសហគមន៍មួយរឹងមាំ?<br>☞ **សហគមន៍ខ្លះមានភាពរឹងមាំដោយសារ ៖**<br>– ស៊ាំទៅនឹងភាពតក់ស្លុតដែលកើតឡើង ហើយសហគមន៍នៅតែដំណើរការការងាររបស់ខ្លួនបានដដែល<br>– អាចរៀបចំចាត់ចែង និងដោះស្រាយបានដោយខ្លួនឯងនៅពេលដែលសហគមន៍ជួបវិបត្តិ<br>– ពួកគេបង្កើតឡើងដើម្បីសង្គ្រោះជីវិត។<br>☞ **សហគមន៍ដែលរឹងមាំគឺជាសហគមន៍ដែល ៖**<br>– គាំទ្រនិងពង្រីកការប្រាស្រ័យទាក់ទង និងភាពសុខដុមក្នុងសង្គម<br>– ពង្រឹងការជួយគ្នាក្នុងសហគមន៍និងអ្នកជិតខាង<br>ឧទាហរណ៍ ៖ ក្រុមជួយខ្លួនឯង<br>– ពង្រឹងបន្ថែមលើចំណុចខ្លាំងមិនមែនចំណុចខ្សោយ<br>– លើកកម្ពស់ការចូលរួមរៀបចំដោយខ្លួនឯងនិងភាពជាម្ចាស់<br>– ប្រើប្រាស់ធនធាននៅក្នុងសហគមន៍ដើម្បីឆ្លើយតបទៅនឹងគ្រោះមហន្តរាយ និងកាត់បន្ថយផលប៉ះពាល់នោះ។ | |

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| ៣០នាទី | **៣. ការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់ និងគ្រឿងប្រដាប់សង្គ្រោះបន្ទាន់**<br>៣.១. ការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់<br>• អ្នកសម្របសម្រួល ៖<br>– បង្ហាញ និងផ្តល់ឧទាហរណ៍ដល់សិក្ខាកាម ដើម្បីធ្វើផែនការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់។<br>• សំណួរបំផុសគំនិត ៖<br>– តើមានស្ត្រីប៉ុន្មាននាក់ដែលទំនងជាសម្រាលនៅក្នុងរដូវភ្លៀង?<br>– តើនៅរដូវភ្លៀងនិងពេលមានទឹកជំនន់ស្ត្រីមានផ្ទៃពោះទាំងនោះអាចទៅមណ្ឌលសុខភាពដើម្បីពិនិត្យផ្ទៃពោះសម្រាលនិងថែរក្សាសុខភាពក្រោយពេលសម្រាលបានដែរឬទេ?<br>☞ **ការសម្តែងតួ**<br>• អ្នកសម្របសម្រួល ៖<br>– បែងចែកសិក្ខាកាមជា ៣ ក្រុម៖<br>ក្រុមទី១ ៖ សំណួរមួយចំនួនជាជំនួយក្នុងការត្រៀមបម្រុងសម្រាប់គ្រោះទឹកជំនន់<br>ក្រុមទី២ ៖ គ្រឿងប្រដាប់សម្រាប់សង្គ្រោះបន្ទាន់<br>ក្រុមទី៣ ៖ បញ្ជីប៉ាន់ប្រមាណបន្ទាន់<br>• ក្រុមនីមួយៗ ត្រូវអានឯកសារទាក់ទងនឹងប្រធានបទរៀងៗខ្លួន<br>• ក្រុមនីមួយៗ ត្រូវធ្វើការសម្តែងតួ "កិច្ចប្រជុំ"<br>បញ្ជាក់ ៖ ការសម្តែងតួ គឺផ្តោតទៅលើខ្លឹមសារប្រធានបទនីមួយៗ មិនមែនដំណើរការនៃកិច្ចប្រជុំឡើយ។<br>• អ្នកសម្របសម្រួល ៖<br>– សង្ខេបខ្លឹមសារប្រធានបទនីមួយៗ តាមរយៈការបង្ហាញខ្លឹមសារមេរៀន<br>– ប៉ុន្តែត្រូវបង្ហាញ និងពន្យល់ត្រួសៗបំផុត ព្រោះសិក្ខាកាមបានយល់ដឹងច្រើនមកហើយ តាមរយៈ "ការសម្តែងតួ"។ | |
| ១០នាទី | **៤. ការឆ្លុះបញ្ចាំង**<br>អ្នកសម្របសម្រួល ៖ តាមរយៈការពិភាក្សាមួយព្រឹកពេញនេះដោយចាប់ផ្តើមពី ៖<br>• គ្រោះមហន្តរាយជះឥទ្ធិពលដល់ស្ត្រី និងកុមារ<br>• ការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់និង<br>• ឧបករណ៍ប៉ាន់ប្រមាណបន្ទាន់ក្រោយគ្រោះមហន្តរាយ<br>– តើមានអ្វីខ្លះដែលថ្មីសម្រាប់លោកលោកស្រីក្នុងមេរៀននេះ?<br>– តើមានចំណុចណាខ្លះដែលលោក លោកស្រី អាចយកទៅអនុវត្តនៅឃុំសង្កាត់ របស់លោក លោកស្រី? | |

| រយៈពេល | ដំណាក់ និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| ៥នាទី | **៥. សេចក្ដីសន្និដ្ឋាន**<br>• អ្នកសម្របសម្រួល សន្និដ្ឋានសម្រាប់មេរៀនទាំងមូល ៖<br>– កុមារងាយនឹងរងគ្រោះជាងគេក្នុងស្ថានភាពគ្រោះមហន្តរាយ<br>– ផែនការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់មានន័យថា៖<br>~ សួរសំណួរឱ្យបានត្រឹមត្រូវ<br>~ ធានាថាគ្រប់អ្នកពាក់ព័ន្ធទាំងអស់ដឹងពីការទទួលខុសត្រូវរៀងៗខ្លួន<br>~ ធានាថាសហគមន៍របស់ខ្លួនរឹងមាំអាចដោះស្រាយបញ្ហា និងឆាប់ត្រឡប់មកសភាពដើមវិញ និងពង្រឹងសម្ព័ន្ធភាពសហគមន៍ (កែប្រែការសង្គ្រោះបន្ទាន់ឱ្យទៅជាឱកាស)<br>– គ.ក.ន.ក អាចជួយសហគមន៍បានដោយប្រាប់ពីរបៀបដែលពួកគាត់ត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់<br>– ការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ គឺធ្វើការប៉ាន់ប្រមាណបន្ទាន់និងសហការជាមួយសមាជិក គ.ក.ន.ក | |

**ឯកសារ ២.១.១**

សំណួរមួយចំនួនជាជំនួយក្នុងការត្រៀមបម្រុងសម្រាប់គ្រោះទឹកជំនន់[1]

- សំណួរទី១ដល់៨ ជាជំនួយនៅក្នុងការកសាងផែនការត្រៀមលក្ខណៈសម្រាប់គ្រោះទឹកជំនន់
- សំណួរទី៩ ជាជំនួយក្នុងការកសាងផែនការឆ្លើយតបទៅនឹងគ្រោះទឹកជំនន់(មុនពេលរដូវវស្សា)

| **សំណួរ** | **ការឆ្លើយតបមួយចំនួន** |
|---|---|
| ១. តើប្រជាជនដែលនៅតំបន់ដែលរងគ្រោះដោយទឹក ជំនន់ដឹងពីរបៀបដែលរក្សាទុកឯកសារ(សំបុត្រកំណើត ប្លង់ដី សំបុត្រអាពាហ៍ពិពាហ៍ឱ្យមានសុវត្ថិភាពដើម្បី ងាយស្រួលរកនៅពេលមានទឹកជំនន់ឬទេ? | • យកកិច្ចប្រជុំភូមិដើម្បីជូនដំណឹងដល់ប្រជាពលរដ្ឋពីសារៈសំខាន់នៃបញ្ជីអត្រានុកូលដ្ឋាន និងរក្សាបញ្ជីទាំងនោះទុកឱ្យមានសុវត្ថិភាព។ ពន្យល់ពួកគាត់ពីការលំបាកប្រសិនបើសំបុត្រទាំងនោះបាត់បង់។ |
| ២. តើមានស្ត្រីប៉ុន្មាននាក់ដែលទំនងជាសម្រាលនៅក្នុងរដូវភ្លៀង? | • បង្កើតជាតារាងឈ្មោះរបស់ស្ត្រីមានផ្ទៃពោះទាំងអស់ព្រមទាំងទីកន្លែងដែលគាត់រស់នៅ (ក្នុងភូមិណា?)<br>• ពិពណ៌នាពីចម្ងាយពីផ្ទះរបស់គាត់ទៅមណ្ឌល សុខភាព និងលក្ខខណ្ឌនៃចម្ងាយផ្លូវនោះក្នុងរដូវភ្លៀង និងពេលមានទឹកជំនន់។<br>• ពិភាក្សាជាមួយបុគ្គលិកសុខាភិបាលដើម្បីធានាថាស្ត្រីមានគត៌ទាំង អស់អាចទៅមណ្ឌលសុខភាពដើម្បីពិនិត្យផ្ទៃពោះ សម្រាលនៅមណ្ឌលសុខភាពនិង ថែទាំសុខភាពក្រោយពេលសម្រាលនៅអំឡុងពេលរដូវភ្លៀង និងទឹកជំនន់។<br>– តើនរណាគួរជួយ ឬទៅជាមួយគាត់?<br>– តើអាចមានសេវាសុខភាពចល័តរៀបចំឡើងឬទេ<br>– តើស្ត្រីមានគត៌ទាំងនោះដឹងឬទេថាតើពួកគាត់ត្រូវទៅពិនិត្យផ្ទៃពោះញឹកញាប់ប៉ុណ្ណា?<br>– តើអ្វីខ្លះដែល គ.ក.ន.ក អាចគាំទ្រពួកគាត់បាន? |
| ៣. តើមានការកំណត់តំបន់ណាមួយដែល មានគ្រោះថ្នាក់(hotspots) នៅពេលមានគ្រោះទឹកជំនន់ដែរទេ? | • កំណត់តំបន់ដែលមានគ្រោះថ្នាក់ដោយភាពកង្វក់នៅពេលដែលមានទឹកជំនន់មកដល់ (តំបន់រ៉ែ តំបន់ធ្វើជី និងកន្លែងចាក់សម្រាម ។ល។)<br>• ធ្វើការជាមួយសមាជិកសហគមន៍ ដើម្បីធានាថាពួកគាត់រក្សាទុកជី និងសារធាតុគីមីផ្សេងៗឱ្យមានសុវត្ថិភាពល្អ |

[1] នេះជាឧទាហរណ៍ដែលទាក់ទងទៅនឹងគ្រោះទឹកជំនន់ទោះបីជាយ៉ាងនេះក៏ដោយដំណើរការដូចគ្នានេះអាចយកទៅធ្វើតាមក្នុងការត្រៀមលក្ខណៈសម្រាប់ភាពអាសន្នផ្សេងៗទៀត។សំណួរខ្លះៗអាចត្រូវសម្រួលទៅតាមហានិភ័យនៅក្នុងឃុំរបស់លោក លោកស្រី។

| សំណួរ | ការឆ្លើយតបមួយចំនួន |
|---|---|
| ៤. តើមានសមាជិកណាម្នាក់ក្នុងសហគមន៍ តាមដាន កម្រិតទឹកឡើង ឬស្រកនោះទេ? | • ធ្វើការជាមួយមេភូមិដើម្បីធានាថាមានការតាមដានកម្រិតទឹកជាប្រចាំហើយ<br>– ធានាថាព័ត៌មាននេះត្រូវបានកត់ទុក និងរាយការណ៍ជាប្រចាំជូនថ្នាក់ស្រុក និងថ្នាក់ខេត្ត<br>– កំណត់កំរិតសំខាន់ជាយុត្តិសាស្ត្រដែលគួរកំណត់ការចាប់ផ្តើមនៃការផ្លាស់ប្តូរទីតាំង និងជម្លៀស។ |
| ៥. ទីទួលសុវត្ថិភាព<br>• តើអ្នកមានក្រណាត់កៅស៊ូ ធុងជ័រ គ្រែ។ល។ គ្រប់គ្រាន់សម្រាប់ជម្រកបណ្តោះអាសន្នដែរឬទេ?<br>• តើមានបង្គន់គ្រប់គ្រាន់ទេនៅលើទីទួលសុវត្ថិភាព? (បង្គន់មួយសម្រាប់មនុស្ស ២០នាក់)?<br>• តើពួកគាត់អាចទទួលបានទឹកស្អាតដែរឬទេ? តើមានអាងលាងដៃដែលមាន សាប៊ូទុកនៅជាប្រចាំដែរឬទេ?<br>• តើអ្នកគួរដាក់វត្ថុសំខាន់ៗនៅក្នុងកន្លែងត្រឹមត្រូវហើយឬនៅ?<br>• តើអ្នកអាចដាក់ម្ហូបអាហារបានត្រឹមត្រូវហើយឬនៅ?<br>• តើអ្នកអាចទុកអាហារសម្រាប់សត្វពាហនៈបានត្រឹមត្រូវហើយឬនៅ?<br>• តើអ្នកមានទុកកន្លែងទំនេរខ្លះសម្រាប់ជាកន្លែងលេងរបស់កុមារ និងកន្លែងសុវត្ថិភាពរបស់កុមារ។ | • ធ្វើការជាមួយមេភូមិ ដើម្បីផ្សព្វផ្សាយប្រជាពលរដ្ឋអំពី ៖<br>– តើទីទួលសុវត្ថិភាពនៅឯណា?ដីទួល?<br>– តើការជន្លៀសនឹងធ្វើតាមរបៀបណា? តើយើងគួរប្រមូលប្រជាពលរដ្ឋមកពីតំបន់ណាខ្លះ?<br>– តើអ្វីខ្លះដែលប្រជាពលរដ្ឋគួរយកតាមខ្លួន?<br>– តើពួកគាត់គួរតែទុកផ្ទះចោលឱ្យមានសុវត្ថិភាពតាមរបៀបណា?<br>– តើពួកគាត់រក្សាទុកឯកសារសំខាន់ៗតាមរបៀបណា? (បញ្ជីកំណើត ប្លង់ដី ។ល។)<br>– ធានាថាមានការអនុវត្តអនាម័យបានត្រឹមត្រូវដូចជាលាងដៃជាមួយសាប៊ូ និងមានបង្គន់ប្រើប្រាស់នៅទីទួលសុវត្ថិភាព<br>– ធានាថាពួកគាត់ទទួលបានទឹកដែលមានសុវត្ថិភាព<br>– ធានាសម្ភារៈផ្គត់ផ្គង់ការរៀនសូត្រជាមូលដ្ឋានអាចរកបាន<br>– រៀបចំថ្នាក់រៀន និងកន្លែងលេងដែលមានសុវត្ថិភាពសម្រាប់កុមារ ដែលត្រូវជម្លៀសទៅទីសុវត្ថិភាព<br>– ធានាថាពួកគាត់ទទួលបានការថែទាំសុខភាពជាមូលដ្ឋាន<br>កំណត់សម្គាល់ ៖<br>– សាលារៀនគួរតែជាជម្រើសចុងក្រោយក្នុងការធ្វើការសម្រេចចិត្តក្នុងការជម្លៀស ឬផ្លាស់ប្តូរទីកន្លែង។ ដោយសារតែការផ្លាស់ប្តូរនេះធ្វើឱ្យបង្អាក់នូវប្រព័ន្ធអប់រំ។ |
| ៦. តើសមាជិកសហគមន៍ រួមទាំងកុមារដឹងថាតើអ្វីដែលពួកគេត្រូវការក្នុងករណីមានភាពអាសន្នដែរឬទេ? | • ផ្តល់ឱ្យសមាជិកសហគមន៍នូវព័ត៌មានគ្រឿងប្រដាប់សម្រាប់ការសង្គ្រោះបន្ទាន់។<br>• លើកទឹកចិត្តឱ្យពួកគាត់រៀបចំគ្រឿងប្រដាប់មុន ពេលរដូវភ្លៀង<br>• លើកទឹកចិត្តឱ្យពួកគាត់ពិភាក្សាជាមួយកុមារ |

| សំណួរ | ការឆ្លើយតបមួយចំនួន |
|---|---|
| | កំណត់សម្គាល់ ៖<br>– សាប៊ូដុំយ៉ាងហោចណាស់មានធុងទឹកពីរ មួយសម្រាប់ដឹកទឹក និងមួយទៀតសម្រាប់ផ្ទុកទឹក ខោអាវ សម្រាប់ផ្លាស់ប្តូរគ្រាប់ពូជសម្រាប់ការដាំដុះ លើកក្រោយទៀត។ |
| ៧. ទឹក និងអនាម័យ<br>• តើទួលសុវត្ថិភាពមានទឹកស្អាតសម្រាប់ដាំបាយនិងអនាម័យផ្ទាល់ខ្លួនទេ?<br>• បើសិនជាមិនមានតើពួកគាត់គួរទទួលបានទឹកនៅទួលសុវត្ថិភាពបានតាមរបៀបណា (ដាំទឹក ចម្រោះទឹក ប្រើថ្នាំក្លរ៉ាមីន)?<br>• តើទឹកនៅត្រូវផ្គតផ្គង់ និងរក្សាទុកតាមរបៀបណា?<br>• តើសហគមន៍ដឹងពីរបៀបរក្សាទឹកស្អាតនិងមានសុវត្ថិភាពនៅពេលមានទឹកជំនន់ដែរឬទេ? (ធុងទឹកធំៗដើម្បីផ្ទុកទឹកឱ្យមានសុវត្ថិភាព? ធុង ចម្រោះ ថ្នាំក្លរ៉ាមីន បើសិនជាដាំទឹកតើមានអុស ធ្យូង ឬហ្គាស ឈើគូស និង ដែកកេស គ្រប់គ្រាន់ដែរឬទេ?<br>• តើស្ត្រី និងកុមារទាំងអស់ដឹងពីគ្រោះថ្នាក់នៃសុខភាពដោយសារជម្ងឺនានានៅពេលទឹកជំនន់ដែរឬទេ?( គ្រុនចាញ់ គ្រុនឈាម រាគរូសស្រួចស្រាវ រាមូល ពស់ចឹក)<br>• តើពួកគាត់មានកំណាត់ប្លាស្ទិកគ្រប់គ្រាន់សម្រាប់ ជម្រកបណ្តោះអាសន្នរបស់ពួកគាត់ដែរឬអត់។ | • ធ្វើការជាមួយតំណាងគ្រូពេទ្យដើម្បី ៖<br>– ផ្តល់ព័ត៌មានពីគ្រោះថ្នាក់នៃការមិនមានអនាម័យ និងវិធីការពាមួយចំនួន( ទឹកអណ្តូងមានមេរោគ សារៈសំខាន់នៃការដាំទឹកចម្រោះទឹក និងដាក់ថ្នាំក្លរ៉ាមីន លាងដៃជាមួយសាប៊ូមុនពេលញ៉ាំបាយ ពេលរៀបចំអាហារក្រោយចេញពីបង្គន់ក្រោយពេលប៉ះពាល់សត្វនិងក្រោយពេលលាងគូទកូន។ល។<br>– ត្រួតពិនិត្យការអនុវត្តអនាម័យចម្បង (key hygiene practice) ព្រមទាំងការប្រដាប់ប្រដាមួយចំនួនដូចជាតើមានម៉ាស៊ីនបូមទឹក និងឧបករណ៍ចម្រោះទឹកនៅដំណើរការល្អឬទេ? តើបង្គន់ថៃទាំបានស្អាតឬទេ? តើមានសាប៊ូនៅអាងលាងដៃដែរឬទេ?<br>– ផ្សព្វផ្សាយពីរបៀបរក្សាទឹកស្អាត (ដាំទឹកចម្រោះទឹក និងដាក់ថ្នាំក្លរ៉ាមីន)<br>• ធានាថាបុគ្គលិកផ្នែកសុខាភិបាលរក្សាបញ្ជីថ្នាំដែលត្រូវការចាំបាច់ឱ្យមាននៅក្នុងដៃនិងដឹងពីរបៀបនិងកន្លែងដែលត្រូវស្នើសុំថ្នាំសម្រាប់ផ្គត់ផ្គង់នៅអំឡុងពេលមានទឹកជំនន់។<br>– តើសេវាកម្មវេជ្ជសាស្ត្រចល័ត( mobile medical service ) អាចធ្វើឡើងនៅពេលបន្ទាន់បានទេ?<br>– តើសម្ភារៈបរិក្ខាពេទ្យនិងថ្នាំពេទ្យការពារបានល្អទេ? |
| ៨. ការបន្តការអប់រំ ៖ ត្រលប់ជាប្រក្រតីឡើងវិញ(ជាការសំខាន់ណាស់ក្នុងការត្រលប់ជាប្រក្រតីឡើងវិញឱ្យបានឆាប់បំផុត ដើម្បីមានការគាំទ្រផ្នែកផ្លូវចិត្ត)<br>– តើកុមារ និងគ្រូនឹងអាចទៅសាលាដោយសុវត្ថិភាព?<br>– តើពួកគេទាំងនោះយល់ពីគ្រោះថ្នាក់ | • ធ្វើការជាមួយសមាជិក គ.ក.ន.ក ជាពិសេសអ្នកតំណាងសាលានិងមាតាបិតាសិស្ស ដើម្បីការពារហានិភ័យនានាដែលអាចកើតឡើងនៅពេលធ្វើដំណើរពេលទឹកជំនន់។<br>• តើយើងគួរធ្វើអ្វីដើម្បីកុំឱ្យមានហានិភ័យនោះកើតឡើង ។ គិតមើលប្រសិនបើថ្នាករៀនអាចរៀបចំនៅទីទួលសុវត្ថិភាព។ |

| សំណួរ | ការឆ្លើយតបមួយចំនួន |
| --- | --- |
| ដែលពួកគាត់ត្រូវទៅរៀននៅពេលមានទឹកជំនន់ដែរឬទេ?<br>– តើសៀវភៅសិក្សា(សម្ភារៈសិក្សា គ្រឿងសង្ហារឹមនានា ក្នុងសាលាត្រូវបានការពារបានត្រឹមត្រូវឬទេ?<br>– បើសិនជាមានការជម្លៀសទៅទីទួលសុវត្ថិភាព តើមានរៀបចំសាលាឱ្យកុមាររៀនដែរឬទេ? | |
| ៩. កិច្ចការពារកុមារ<br>• តើមានកុមារកំព្រា កុមារងាយរងគ្រោះ ឬកុមារដែលមិនមានអ្នកអ្នកថែរក្សាដែរឬទេ ហើយតើនរណានឹងថែរក្សាពួកគេ?<br>• តើនរណាជួយពួកគេក្នុងពេលជម្លៀស? | • ធ្វើការជាមួយសមាជិក គ.ក.ន.ក ដើម្បីឱ្យគាត់ដឹងពីតម្រូវការរបស់កុមារកំព្រា និងកុមារងាយរងគ្រោះឬកុមារឯការដែលអាចត្រូវការជំនួយពិសេសណាមួយ។ តែងតាំងអ្នកទទួលខុសត្រូវ ដែលជាអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ។ |
| ១០. តើមានផែនការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់រួចរាល់ហើយឬនៅ? | • ធ្វើការជាមួយប្រធានក្រុមប្រឹក្សានិងអ្នកពាក់ព័ន្ធដើម្បីកសាងផែនការត្រៀមលក្ខណៈសម្រាប់ភាពអាសន្នរួមមាន៖<br>– កំណត់របៀបដែលឃុំនឹងរៀបចំការឆ្លើយតបទៅនឹងគ្រោះទឹកជំនន់<br>– កំណត់ថាតើនរណានឹងធ្វើការប៉ាន់ប្រមាណបន្ទាន់ (សូមមើលតារាងខាងក្រោម១.៦) និងរបៀបដែលអ្នកនឹងចែករំលែកព័ត៌មានជាមួយឃុំខេត្តនិងដៃគូអភិវឌ្ឍន៍(អង្គការក្នុងស្រុកនិងអង្គការអន្តរជាតិ)<br>– កំណត់ពីរបៀបសហការណ៍ក្នុងការឆ្លើយតបរបស់ឃុំ (តើនរណានឹងធ្វើអ្វី?) ធានាថាសមាជិកម្នាក់ៗដឹងពីតួនាទី និងការទទួលខុសត្រូវរបស់ពួកគាត់ និងរបៀបដែលពួកគាត់ចែករំលែកតួនាទី និងភារកិច្ច (នរណានឹងកោះ ហៅការប្រជុំ? ទំនាក់ទំនងជាមួយប៉ូលីស? តើនរណានឹងធ្វើការទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍តើនរណានឹងធ្វើការទំនាក់ទំនងជាមួយគ្រួសារដែលរងគ្រោះ។ល។ |
| ១០. ផ្សេងៗ<br>• សួរខ្លួនឯងនូវសំណួរផ្សេងៗដែលទាក់ទងទៅនឹងសហគមន៍ របស់អ្នក? | • កំណត់តួនាទីនិងការទទួលខុសត្រូវ<br>• បែងចែកការងារក្នុងចំណោមសមាជិកគ.ក.ន.ក |

## ឯកសារ ២.១.២

## បញ្ជីប៉ាន់ប្រមាណបន្ទាន់

**(ត្រូវធ្វើនៅអំឡុងពេលពី៤៨ទៅ៧២ម៉ោងបន្ទាប់ពីមហន្តរាយកើតឡើង)**

**សម្ភាសន៍ការពិភាក្សាក្រុមនិងការអង្កេតបើចាំបាច់**

សួរសំណួរឱ្យបានត្រឹមត្រូវ ៖ ការឆ្លើយតបនឹងភាពអាសន្នឱ្យមានប្រសិទ្ធភាពចាប់ផ្តើមពីការធ្វើការប៉ាន់ប្រមាណ បន្ទាន់ដោយសហការណ៍ជាមួយ គ.ក.ន.ក។

| | |
|---|---|
| ១. ការកំណត់ព័ត៌មាន | - នៅតាមភូមិ ឃុំ សង្កាត់ |
| ២. ចំនួនប្រជាជន ការតាំងទីលំនៅ ការប្តូរទីលំនៅ | - ជំនួនប្រជាជនសរុបដែលបានធ្វើការប៉ាន់ប្រមាណ (ចែកតាមភេទ អាយុ០ដល់ ០៥ឆ្នាំ ០៦ដល់១១ឆ្នាំ ក្មេងជំទង់ មនុស្សពេញវ័យ)<br>ជនដែលរងគ្រោះដោយ មហន្តរាយ (ចែកតាមអាយុ ភេទ ចំនួនអ្នកស្លាប់ អ្នកបាត់ខ្លួន និងអ្នកដែលខូច ខាតផ្ទះសម្បែង) |
| ៣. ការការពារកុមារ | - តើមានកុមារដែលព្រាត់ប្រាស់ឪពុកម្តាយដែរឬទេ?<br>- តើមានក្មេងកំព្រាទេ?<br>- តើនរណាថែរក្សាកុមារកំព្រា កុមារដែលព្រាត់ប្រាស់ឪពុកម្តាយ? |
| | - តើមានការព្រួយបារម្ភចំពោះសុវត្ថិភាពដែរឬទេ?<br>- តើមានការព្រួយបារម្ភចំពោះកាយសម្បទាដែរឬទេ? |
| ៤. ការអប់រំ | - ចំនួនសាលាដែលអាចប្រើការបានមុនពេលមានគ្រោះមហន្តរាយ (មត្តេយ្យសិក្សា បឋមសិក្សា អនុវិទ្យាល័យ<br>- ចំនួនសាលារៀនដែលត្រូវបំផ្លាញខូចខាត<br>- ចំនួនគ្រូដែលរងគ្រោះដោយមហន្តរាយ<br>- ប្រភេទសម្ភារៈ ឬឧបករណ៍ដែលទទួលរងការខូចខាត<br>- ប្រភេទសម្ភារៈ ឬឧបករណ៍ដែលចាំបាច់សម្រាប់ការអប់រំ<br>- តើសម្ភារៈសម្រាប់ការរៀនសូត្រអាចជួសជុលបានវិញសម្រាប់ការរៀនសូត្រឬទេ? |
| ៥. សុខភាព | - ចំនួនស្ត្រីមានផ្ទៃពោះ ស្ត្រីបំបៅកូនដោយទឹកដោះ<br>- ចំនួនកុមារអាយុក្រោម០៥ឆ្នាំ<br>- សេវាសុខភាព (មណ្ឌលសុខភាព ផ្គត់ផ្គង់ថ្នាំពេទ្យ និងសម្ភារៈបរិក្ខារពេទ្យ) ដែលសហគមន៍អាចទទួលបាន<br>និងចម្ងាយផ្លូវដែលសហគមន៍ទៅទទួលសេវានោះ<br>- តំណាងបុគ្គលិកសុខាភិបាលនៅមណ្ឌលសុខភាព រួមទាំងឆ្មប<br>- ចំនួនកុមារដែលឆ្លងជំងឺ មានរបួស រាករូស រាកមួល ជំងឺផ្លូវដង្ហើម ជំងឺគ្រុន ឈាម ជំងឺគ្រុនចាញ់ ឬពស់ចឹក។ល។ |
| ៦. កង្វះអាហារូបត្ថម្ភ | - ចំនួនកុមារខ្វះអាហារូបត្ថម្ភដែលបានព្យាបាលនៅមណ្ឌលសុខភាព (ទទួលបានបទពិសោធន៍អ្វីខ្លះនៅពេលមានគ្រោះទឹកជំនន់កើនឡើងជាបន្តបន្ទាប់?) |

| | |
|---|---|
| ៧. សុវត្ថិភាពស្បៀង | - តើមានផ្សារបើកលក់ឬទេ?<br>- តើផ្ទះនីមួយៗមានស្បៀងសម្រាប់បរិភោគដែរឬទេ?<br>- តើផ្ទះនីមួយៗមានប្រាក់សម្រាប់ទិញស្បៀងដែរឬទេ?<br>- តើផ្ទះនីមួយៗអាចទទួលបានទឹកសុវត្ថិភាពដែរឬទេ?<br>- តើស្បៀងប្រភេទណាដែលអាចរកបាន?<br>- តើអាចរកបានចំណីសត្វឬទេ? |
| ៨. ទីជម្រក និងសម្ភារៈសំខាន់ៗ | - ចំនួនគ្រួសារដែលបាត់បង់ផ្ទះសម្បែង<br>- ចំនួនផ្ទះដែលខូចខាត<br>- ចំនួនគ្រួសារដែលរស់នៅក្នុងជម្រកបណ្ដោះអាសន្ន (ស្ថានភាពជម្រក[2])<br>- តើគ្រួសារនានា ស្ត្រី និងកុមារ មានភាពឯកជនឬទេ? តើពួកគេមានសុវត្ថិភាពដែរឬទេ?<br>- តើជម្រកនោះស្ថិតនៅឯណា?<br>- តើនរណាជាអ្នកផ្ដល់ជម្រក?<br>- តើពួកគេមានបង្គន់[3]គ្រប់គ្រាន់ និងកន្លែងលាងដៃសម្រាប់មនុស្សគ្រប់គ្នាដែរ ឬទេ?<br>- ការទទួលបានសម្ភារៈដូចជាសម្លៀកបំពាក់សម្រាប់ប្ដូរ ភួយ អនាម័យ កញ្ចប់ សម្រាប់បុរស និងស្ត្រី ធុងទឹក និងគ្រឿងប្រដាប់សម្រាប់ចម្អិន រួមមានដែក កេសជាដើម។ល។ |
| ៩. ទឹក និងអនាម័យ | - ការទទួលបានទឹក (ទឹកផឹក ទឹកងូត ទឹកដាំបាយ)[4]<br>- តើមានចែកបន្ទប់ទឹកសម្រាប់ស្ត្រីផ្សេង និងបុរសផ្សេងដែរឬទេ?<br>- តើមានប្រភពទឹកស្អាតសម្រាប់ទឹកផឹកដែរឬទេ?<br>- តើប្រជាពលរដ្ឋត្រូវធ្វើដំណើរឆ្ងាយប៉ុណ្ណាដើម្បីទៅរកទឹក?<br>- តើអ្នកណាជាអ្នកផ្គត់ផ្គង់ទឹក?<br>- តើបង្គន់អនាម័យនៅដំណើរការល្អឬទេ?<br>- តើប្រជាពលរដ្ឋបន្ទោរបង់នៅឯណា? |
| ១០.ការឆ្លើយតបរបស់ដៃគូអភិវឌ្ឍន៍នានាក្នុងពេលមានទឹកជំនន់ | បញ្ជីដៃគូអភិវឌ្ឍន៍នានា (អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ភ្នាក់ងារ រដ្ឋាភិបាល) ដែលបានចូលរួមធ្វើអន្តរាគមន៍ តាម ៖<br>- វិស័យនីមួយៗ<br>- តំបន់ភូមិសាស្ត្រនានា។<br>គួរមានផែនទីទីតាំងធ្វើអន្តរាគមន៍ដើម្បីដឹងពីគម្លាត និងការជាន់គ្នា។ |

[2] បទដ្ឋានរបស់ Sphere បានណែនាំថា ត្រូវមានកន្លែងទំហំ៣.៥ម៉ែ[2] និងទឹក១៥លីត្រសម្រាប់ជម្រករបស់មនុស្សម្នាក់

[3] បទដ្ឋានរបស់ Sphere បានណែនាំថា ត្រូវមានបង្គន់អនាម័យ០១ សម្រាប់មនុស្ស២០នាក់

[4] បទដ្ឋានរបស់ Sphere បានណែនាំថា ត្រូវមានទឹក១៥លីត្រក្នុង០១ថ្ងៃសម្រាប់មនុស្សម្នាក់

# ប្លង់មេរៀនទី២
# ការថែទាំកុមារនៅជាមួយគ្រួសារ និង
# យន្តការគាំទ្រសហគមន៍

# មេរៀនទី២
## ការថែទាំកុមារនៅជាមួយគ្រួសារ និងយន្តការគាំទ្រសហគមន៍

| | |
|---|---|
| **គោលបំណង** | នៅចុងបញ្ចប់នៃមេរៀននេះសិក្ខាកាមនឹងអាច ៖<br>• ពិពណ៌នាបានពីសារៈសំខាន់របស់គ្រួសារ សហគមន៍ និងយន្តការគាំទ្រសម្រាប់ការអភិវឌ្ឍកុមារ<br>• ទាញបានជាសារជាក់លាក់ដែលពួកគាត់អាចប្រើប្រាស់បាន ដើម្បីនិយាយប្រាប់មនុស្សផ្សេងៗទៀតពីហានិភ័យនៃមណ្ឌលថែទាំ |
| **ខ្លឹមសារមេរៀន** | ១. មណ្ឌលថែទាំ ខុសពីការគាំទ្រ និងមូលដ្ឋានថែទាំនៅសហគមន៍<br>២. ផលជះដ៏យូរអង្វែងនៃមណ្ឌលថែទាំទៅលើការអភិវឌ្ឍកុមារ<br>៣. សារគន្លឹះក្នុងការផ្លាស់ប្តូរទស្សនៈមនុស្សដែលធ្លាប់យល់ពីមណ្ឌលថែទាំ |
| **រយៈពេល** | ១ ម៉ោង |
| **សម្ភារៈ** | ករណីសិក្សា និងការបញ្ចាំងស្លាយ សៀវភៅណែនាំសម្រាប់សមាជិក គ.ក.ន.ក ផ្នែកទី ២ មេរៀនទី២ ទំព័រ៣៣ និងឯកសារជំនួយស្មារតី |
| **វិធីសាស្ត្រ** | ការពិភាក្សាក្រុមធំ និងក្រុមតូច |

**ដំណើរការសម្របសម្រួល**

| **រយៈពេល** | **ជំហាន និងវិធីសាស្ត្រ** | **ធនធាន** |
|---|---|---|
| ១០នាទី | **១. សេចក្តីផ្តើម និងគោលបំណង**<br>• នៅក្នុងមេរៀននេះយើងនឹងបរិយាយអំពីនិន្នាការដែលមានសារៈសំខាន់នៅក្នុងប្រទេសកម្ពុជា ចំពោះការកើនឡើងនៃចំនួនរបស់កុមារនៅក្នុងមណ្ឌលថែទាំ សារៈសំខាន់របស់គ្រួសារ សហគមន៍ និងយន្តការគាំទ្រសម្រាប់ការអភិវឌ្ឍកុមារ។ | |
| ៣០នាទី | **២. ករណីសិក្សាពីការថែទាំកុមារនៅក្នុងគ្រួសារ និងនៅក្នុងមណ្ឌលថែទាំ**<br>• អ្នកសម្របសម្រួលណែនាំពីករណីសិក្សា(ឯកសារ២.២) ដែលក្រសួងសង្គមកិច្ចការងារអតីតយុវជន និងយុវនីតិសម្បទាបានធ្វើឡើងពីតរិយាបថដែលមាននៅក្នុងមណ្ឌលថែទាំនៅក្នុងប្រទេសកម្ពុជា និងបង្ហាញពីព័ត៌មានសំខាន់ៗស្តីពីមណ្ឌលថែទាំនៅក្នុងប្រទេសកម្ពុជា។<br>• បន្ទាប់មកអ្នកសម្របសម្រួលបែងចែកសិក្ខាកាមជាក្រុមតូចៗ អានឯកសារ និងពិភាក្សាសំណួរដូចខាងក្រោម ៖<br>– តើមានព្រឹត្តិការណ៍អ្វីខ្លះ ដែលលេចឡើងក្នុងអត្ថបទករណីសិក្សា?<br>– តើការថែទាំកុមារក្នុងមណ្ឌលជាជម្រើសល្អដែរឬទេ? ហេតុអ្វី?<br>– ហេតុអ្វីបានជាមណ្ឌលថែទាំនាំទុក្ខដល់ការអភិវឌ្ឍកុមារ?<br>– តើ គ.ក.ន.ក អាចធ្វើអ្វីខ្លះដើម្បីលើកកម្ពស់ការថែទាំកុមារជាមួយគ្រួសារ?<br>• អ្នកសម្របសម្រួលដឹកនាំពិភាក្សាក្រុមធំទៅលើចំនុចសំខាន់ៗខាងលើ។ | |

| | |
|---|---|
| | • ប្រសិនបើ អង្គហេតុដែលពួកគាត់ផ្តល់ជាយោបល់មិនទាន់បានត្រឹមត្រូវទេនោះ៖ អ្នកសម្របសម្រួលអាចឱ្យសិក្ខាកាមមើលទៅផ្នែកដែលមាននៅក្នុងព្រឹត្តិការណ៍ពិត<br>• សំណួរខ្លះៗ ដែលជួយឱ្យការពិភាក្សាមានលក្ខណៈកាន់តែផុសផុលគឺ ៖<br>– តើអ្វីដែលធ្វើឱ្យអ្នកភ្ញាក់ផ្អើល?<br>– តើអ្វីដែលអ្នករៀនបានថ្មីហើយអ្នកមិនដែលដឹងពីមុនមក?<br>• មុនពេលបញ្ចប់ការពិភាក្សា អ្នកសម្របសម្រួលផ្តល់សារគន្លឹះសម្រាប់សិក្ខាកាមប្រើដើម្បីធ្វើការប្រាស្រ័យទាក់ទងជាមួយអ្នកផ្សេងទៀត។<br>• បទបង្ហាញពីភាពខុសគ្នារវាងការថែទាំកុមារតាមគ្រួសារ និងការថែទាំតាមមណ្ឌល។ អ្នកសម្របសម្រួលបង្ហាញខ្លឹមសារនៃភាពខុសគ្នា<br>• សិក្ខាកាមនឹងអានអត្ថបទដែលទាក់ទងនឹងព្រឹត្តិការណ៍ពិត និងពិភាក្សាទាំងអស់គ្នានៅខណៈដែលក្រុមកំពុងតែអាន ពិភាក្សា អ្នកសម្របសម្រួលគួរតែដើរនិងស្តាប់កិច្ចពិភាក្សារបស់ក្រុមទាំងមូល (ដើម្បីមើលថាតើមានការយល់ស្រប និងការជំទាស់) និងមានសំណួមពរអ្វីដែលទាក់ទងនឹងអត្ថបទនេះទេ។<br><br>**កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល ៖**<br>• ជាការរកឃើញដ៏សំខាន់មួយដែល ក្រសួងសង្គមកិច្ចការងារ អតីតយុទ្ធជន និងយុវនីតិសម្បទាបានធ្វើការសិក្សាថា ៖ គោលការណ៍ដែលនិយាយថាមណ្ឌលថែទាំគួរតែជាជម្រើសចុងក្រោយ និងជាដំណោះស្រាយបណ្តោះអាសន្នមិនទាន់បានយល់ឱ្យបានទូលំទូលាយនៅក្នុងផ្នត់គំនិតជាទូទៅរបស់ប្រជាពលរដ្ឋខ្មែរនោះទេ។<br>• មនុស្សជាច្រើនយល់ថាមណ្ឌលថែទាំជាដំណោះស្រាយដ៏ល្អមួយ។ ហើយក្រុមប្រឹក្សាខ្លះអាចគាំទ្រគំនិតទាំងនេះ។ ដូចនេះហើយនៅក្នុងការពិភាក្សានេះនឹងមានការជំទាស់ ឬការការពារចំពោះគំនិតដែលថាមណ្ឌលថែទាំជាដំណោះស្រាយបណ្តោះអាសន្ន។ ផ្តោតទៅលើអង្គហេតុនេះ ការស្រាវជ្រាវដែលបានធ្វើឡើង ដែលស្របទៅនឹងការស្រាវជ្រាវរបស់ពិភពលោក។ ការគិតដែលអាចអនុវត្តបានប្រសើរបំផុតនោះ៖ គឺការបញ្ជ្រាបកុមារដែលងាយរងគ្រោះទៅក្នុងសហគមន៍។ |
| ១៥ នាទី | **៣. តួនាទីគ.ក.ន.ក ដើម្បីលើកកម្ពស់ការថែទាំកុមារជាមួយគ្រួសារ**<br>• សំណួរបំផុសគំនិត ៖<br>– តើលោក លោកស្រី នឹងយកសកម្មភាពអ្វីខ្លះ ទៅអនុវត្តនៅក្នុងឃុំ របស់លោក លោកស្រី ដើម្បីឱ្យមានការផ្លាស់ប្តូរគំនិតទាក់ទងនឹងការថែទាំនៅមណ្ឌល?<br>• បទបង្ហាញពីតួនាទី គ.ក.ន.ក ដើម្បីលើកកម្ពស់ការថែទាំកុមារជាមួយគ្រួសារ |

| | | |
|---|---|---|
| ៥នាទី | **៤. សេចក្ដីសន្និដ្ឋាន**<br>• អ្នកសម្របសម្រួលបង្ហាញពីសារគន្លឹះសម្រាប់ការប្រាស្រ័យទាក់ទងជាមួយមនុស្សផ្សេងទៀតដល់សិក្ខាកាម។<br>"មនុស្សជាច្រើនគិតថាមណ្ឌលថែទាំ ជាដំណោះស្រាយដ៏ប្រពៃសម្រាប់កុមារងាយរងគ្រោះ។ ប៉ុន្តែវាមិនដូចជាការគិតនោះទេ នៅក្នុងករណីខ្លះមណ្ឌលថែទាំអាចនាំទុក្ខទោសដល់ការអភិវឌ្ឍរបស់កុមារទៅវិញទេ។<br>ថ្ងៃនេះយើងបានពិភាក្សាគ្នាពីការផលប៉ះពាល់ជាអវិជ្ជមានខ្លះៗដល់កុមារដូចជា យឺតយ៉ាវក្នុងការចេះនិយាយស្ដី និងការអភិវឌ្ឍបញ្ញាស្មារតី។ កុមារអាចប្រឈម និងការរំលោភបំពាន ព្រមទាំងកេងប្រវ័ញ្ចកំលាំងពលកម្ម។ការផ្លាស់ប្ដូរអ្នកថែទាំកុមារញឹកញាប់នាំឱ្យមានមានភាពខ្វះចន្លោះនៃសុវត្ថិភាពនៃផ្នែកអារម្មណ៍។<br>គ.ក.ន.ក មានតួនាទីដ៏សំខាន់ក្នុងការជួយអប់រំអ្នកផ្សេងទៀត និងក្នុងការផ្លាស់ប្ដូរឥរិយាបថរបស់ពួកគេ។"<br>• នេះជាសារគន្លឹះខ្លះៗសម្រាប់ជួយឱ្យលោក លោកស្រីប្រើប្រាស់សម្រាប់ការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃទៀត។<br>– កុមារមានសិទ្ធទទួលបានការថែទាំពីគ្រួសាររបស់ពួកគេ<br>– កុមារត្រូវការគ្រួសាររបស់គេសម្រាប់ការការពារ និងការអភិវឌ្ឍ<br>– ការគាំទ្រចាំបាច់ពីក្រុមគ្រួសារក្នុងការថែទាំកុមារគួរតែផ្ដល់ឱ្យដោយភ្ជាប់ជាមួយការគាំទ្រ<br>– បរិយាកាសគ្រួសារដែលសមរម្យនៅក្នុងសហគមន៍ គួរតែរៀបចំឱ្យកុមារដែលគ្រួសាររបស់គេមិនអាចថែទាំពួកគេបាន<br>– មណ្ឌលថែទាំគួរតែជាជម្រើសចុងក្រោយសម្រាប់កុមារដែលត្រូវការដែលត្រូវការការថែទាំជាជម្រើស។ ការថែទាំនៅមណ្ឌលត្រូវតែយកមកប្រើប្រាស់នៅការរស់ស្នង់ជាបណ្ដោះអាសន្នប៉ុណ្ណោះ។<br>– ការថែទាំកុមារនៅមណ្ឌលថែទាំចំណាយច្រើនជាងគាំទ្រកុមារឱ្យរស់នៅជាមួយក្រុមគ្រួសាររបស់ពួកគេ។<br>• មុនពេលបញ្ចប់មេរៀននេះ សូមប្រាប់ទៅដល់សិក្ខាកាមថា ព្រឹត្តិការណ៍ពិស្ដារអាចរកបាននៅក្នុងធនធានរៀនសូត្រ។ | |

## ឯកសារ ២.២ ÷ ករណីសិក្សា

### ការថែទាំកុមារនៅជាមួយក្រុមគ្រួសារជាជាងដាក់ពួកគាត់នៅមណ្ឌលថែទាំ

សូមមេត្តាអានសេចក្តីដកស្រង់ចេញពីការសិក្សារបស់ ក្រសួងសង្គមកិច្ចការងារ អតីតយុវជននិងយុវនីតិសម្បទាស្តីពីផលប៉ះពាល់នៃការថែទាំកុមារនៅមណ្ឌលថែទាំ និងធ្វើការជាក្រុមតូចៗដើម្បីពិភាក្សាពីសំណួរមួយចំនួន។ ការថែទាំកុមារដែលងាយរងគ្រោះនៅក្នុងមណ្ឌលថែទាំជាជម្រើសដំបូងរបស់ក្រុមគ្រួសារ និងសហគមន៍ មិនទាន់ត្រូវបានពិចារណាឱ្យបានល្អិតល្អន់នៅឡើយ មិនទាន់បានប្រត្តិបត្តិតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងពីមាត្រដ្ឋានអប្បរមាពី បំលាស់ប្តូរនៃការថែទាំកុមារនៅឡើយ។ ការថែទាំកុមារនៅក្នុងមណ្ឌលគួរតែជាមធ្យោបាយចុងក្រោយបំផុត និងដំណោះស្រាយជាបណ្តោះអាសន្ន តែគោលការណ៍នេះមិនទាន់បានយល់បានជារួមនៅក្នុងប្រទេសកម្ពុជានៅឡើយ។

☞ **ហេតុអ្វីបានជាការរក្សាកុមារនៅក្នុងមណ្ឌលថែទាំមិនមែនជាជម្រើសល្អបំផុតសម្រាប់កុមារ?**

- ការថែរក្សាកុមារនៅក្នុងមណ្ឌលថែទាំអាចនាំឱ្យមានផលជះជាអវិជ្ជមានចំពោះការអភិវឌ្ឍកុមារ រួមមាន ៖ ការអភិវឌ្ឍសង្គម កាយសម្បទា ប្រាជ្ញា និងអារម្មណ៍ ដែលផលជះនេះនឹងនៅជាមួយពួកគាត់រហូតដល់ធំ។ ការស្រាវជ្រាវបានបង្ហាញថា កុមារដែលបានទទួល ការចិញ្ចឹមបីបាច់នៅមណ្ឌលថែទាំអាចទទួលរងទុក្ខពីភាពយឺតយ៉ាវនៃការអភិវឌ្ឍខួរក្បាល ក្រចេះនិយាយ និងភាពយឺតយ៉ាវនៃការលូតលាស់ ផ្នែកកាយសម្បទា ងាយឆ្លងជម្ងឺ និងអាកប្បកិរិយាមិនមានរបៀប និងអាម្មណ៍មិនមានសុវត្ថិភាព។
- ការផ្លាស់ប្តូរអ្នកថែទាំជាញឹកញាប់អាចបង្ករជាផលជះជាអវិជ្ជមានដល់កុមារ ដោយសារតែកុមារត្រូវ ព្យាយាមក្នុងការបង្កើតចំណងអារម្មណ៍ជាមួយអ្នកថែទាំដែលត្រូវផ្លាស់ប្តូរហើយម្តងទៀត។ ក្នុងការកសាងឱ្យមានភាពប្រក្រតី កុមារទាមទារឱ្យភ្ជាប់ចំណងរឹងមាំ ជាមួយអ្នកថែទាំដែលពួកគាត់ នៅបង្កើតឡើងតាំងពីនៅក្នុងផ្ទៃ និងបន្តជីវិតជាកុមារភាពរបស់គាត់។
- មណ្ឌលថែទាំកុមារមានហានិភ័យខ្ពស់ក្នុងការរំលោភបំពានទាំងផ្លូវកាយ និងផ្លូវភេទ។ កុមារភាគច្រើនរងទុក្ខដោយសារតែមិនបានទទួលការយកចិត្តទុកដាក់លើផ្នែកកាយសម្បទា និងអារម្មណ៍ ឬដោយសារត្រូវគេសំឡុត និងត្រូវគេប្រើអំពើហឹង្សាលើ(ដោយអ្នកថែទាំ អ្នកមកសួរសុខទុក្ខ និងកុមារផ្សេងៗទៀត)
- ជាញឹកញាប់កុមារដែលរស់នៅក្នុងមណ្ឌលថែទាំ ក្នុងរយៈពេលវែងជួបប្រទះនូវការលំបាកក្នុងការសម្របខ្លួនទៅក្នុងសហគមន៍វិញនៅពេលដែលពួកគេចេញពីមណ្ឌលថែទាំ។ ជាញឹកញាប់ពួកគេមិនអាចធ្វើអ្វីបានដោយឯករាជ្យ ពួកគេអាចនឹងប្រឈមនឹងការរើសអើងនៅក្នុងសហគមន៍ ជាពិសេសពួកគេខ្វះជំនាញសង្គមដែលជួយពួកគេឱ្យសម្របខ្លួនបានក្នុងការប្រើប្រាស់ជីវិតសហគមន៍របស់ពួកគេ។
- កម្ពុជាមានការថែទាំជាប្រពៃណីដ៏យូរអង្វែងសម្រាប់កុមារដែលងាយរងគ្រោះតាមរយៈសហគមន៍ និងការថែទាំកុមារជាមួយគ្រួសារដែលមានសមាជិកច្រើន ហើយនេះជាកន្លែងអាទិភាពដែលកុមារគំព្រារស់នៅបច្ចុប្បន្ននេះ។ ការកើនឡើងយ៉ាងឆាប់រហ័សនៃមណ្ឌលថែទាំនាំឱ្យមានការសឹករិចរិលនៃប្រព័ន្ធថែទាំក្មេងឱ្យនៅជាមួយគ្រួសារ ព្រមទាំងទុកឱ្យកុមារប្រឈមនឹងហានិភ័យខ្ពស់។
- នៅក្នុងប្រទេសកម្ពុជាមណ្ឌលថែទាំខ្លះប្រឈមនឹងបញ្ហាខ្វះខាតថវិកា។ នេះមានន័យថាកុមារអាចខ្វះខាតអាហារ និងការអប់រំ។ ការរស់នៅក្នុងលក្ខ័ណ្ឌបែបនេះមិនមែនជាការគួរឱ្យពេញចិត្តនោះទេ។ ការខ្វះខាតថវិកាអាចនាំឱ្យមានការប្រើប្រាស់ពលកម្មកុមារដូចជា ការបង្ខំកុមារឱ្យទៅនេសាទ ធ្វើស្រែ និងចំការ ឬទៅ

សម្តែងរបាំបុរាណជូនអ្នកទេសចរទស្សនា ដើម្បីប្រមែប្រមូលថវិកា។ នេះក៏អាចជាហេតុក្នុងការដាក់កុមារនៅក្នុងស្ថានភាពគ្រោះថ្នាក់ ដូចជាការរែអង្គាសប្រាក់សម្រាប់មណ្ឌលថែទាំកុមារនៅពេលយប់។

មានករណីជាច្រើនដែលទាមទារឱ្យមានហត្ថលេខារបស់មេភូមិ ដើម្បីទុកកុមារនៅក្នុងមណ្ឌលថែទាំ។ តាមរយៈ ការសិក្សាថ្មីៗនេះដែលបានធ្វើឡើងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានរកឃើញថាមេភូមិជាច្រើនគាំទ្រការទុកកុមារនៅមណ្ឌលថែទាំ ដោយពួកគាត់ជឿថាការទុកកុមារនៅមណ្ឌលថែទាំមានប្រយោជន៍បំផុតចំពោះកុមារ។ ទោះជាយ៉ាងណាក៏ដោយ ក៏មានមេភូមិជាច្រើនទៀតបានបង្ហាញពីការគំនិតបើកទូលាយពីការថែទាំកុមារនៅផ្ទះ និងនៅក្នុងសហគមន៍ ដោយគាត់ធ្វើការកត់សម្គាល់ថាជាការជួយមួយយ៉ាងធំ បើថែទាំកុមារនៅជាមួយគ្រួសាររបស់គេ។ ប្រសិនបើមេភូមិទាំងអស់យល់ពីផលប៉ះពាល់ជាអវិជ្ជមាននៃការទុកកុមារនៅមណ្ឌលថែទាំ និងសារៈប្រយោជន៍នៃការលូតលាស់របស់កុមារក្នុងបរិស្ថានជាមួយក្រុមគ្រួសារនោះ ពួកគាត់អាចភ្ជាប់ការថែទាំកុមារនៅក្នុងសហគមន៍ និងជម្រើសនៃការគាំទ្រនានា ដូចនេះពួកគាត់អាចជួយណែនាំក្រុមគ្រួសារក្រីក្រឱ្យរក្សាកូនៗរបស់គាត់នៅផ្ទះ។

☞ **តើតួនាទីអ្វីខ្លះដែល គ.ក.ន.ក អាចធ្វើបានដើម្បីលើកកម្ពស់ការថែទាំកុមារនៅជាមួយក្រុមគ្រួសារ?**

គ.ក.ន.ក អាចដើរតួយ៉ាងសំខាន់នៅក្នុងការជួយការពារកុមារងាយរងគ្រោះ និងគ្រួសាររបស់គេ ព្រមទាំងធានាថាកុមារទាំងអស់ធំធាត់នៅក្នុងគ្រួសារ និងសហគមន៍។ ខាងក្រោមនេះជាសកម្មភាពមួយចំនួនដែល គ.ក.ន.ក អាចធ្វើបាន ៖

- ប្រើប្រាស់ព័ត៌មាន និងសារគន្លឹះនៅក្នុងព្រឹត្តិការណ៍ពិត ក្នុងការផ្សព្វផ្សាយការយល់ដឹងដល់សមាជិកក្រុមប្រឹក្សាឃុំ មេឃុំ សហគមន៍ និង ក្រុមគ្រួសារពីផលប៉ះពាល់ជាអវិជ្ជមានពីការរក្សាកុមារនៅមណ្ឌលថែទាំ និងសារៈប្រយោជន៍ដែលកុមាររីកលូតលាស់ជាមួយគ្រួសារនិងសហគមន៍របស់ពួកគេ។
- ប្រសិនបើកុមារមិនត្រូវបានថែទាំឱ្យសមរម្យនៅក្នុងបរិស្ថានគ្រួសារ ប្រហែលដោយសារតែសេចក្តីស្លាប់ ឬជម្ងឺធ្ងន់ធ្ងរនៃអ្នកថែទាំដំបូង ហើយកុមារត្រូវការការថែទាំពិសេសដែលគ្រួសារមិនអាចផ្តល់ឱ្យបាន ឬកុមារទទួលរងនូវអំពើហិង្សា ឬការរំលោភបំពានផ្លូវភេទនៅក្នុងគ្រួសារ ត្រូវយកកុមារទៅសេវាសង្គមដែលសមរម្យមួយដោយសហការណ៍ជាមួយការិយាល័យសង្គមកិច្ចការងារ អតីតយុទ្ធជននិងយុវនីតិសម្បទាថ្នាក់ស្រុក។
- រៀបចំការថែទាំកុមារនៅសហគមន៍ជាបណ្តោះអាសន្ន រួមមានការរក្សាកុមារនៅជាមួយក្រុមគ្រួសារគ្រួសារកុមារដែលមានសមាជិកច្រើន ឱ្យសាច់ញាតិថែទាំ ឬការថែទាំជាកូនធម៌អាចជាហានិភ័យភ្លាមៗសម្រាប់កុមារ រួមជាមួយកុមារដែលត្រូវគេបោះបង់ ក្នុងការសហការណ៍ដ៏ជិតស្និតជាមួយអាជ្ញាធរ ដែលពាក់ព័ន្ធ និងការិយាល័យសង្គមកិច្ចការងារ អតីតយុទ្ធជននិងយុវនីតិសម្បទាថ្នាក់ស្រុក។
- កិច្ចសហប្រតិបត្តិការជាមួយការិយាល័យសង្គមកិច្ចការងារ អតីតយុទ្ធជននិងយុវនីតិសម្បទាថ្នាក់ស្រុក ថ្នាក់ខេត្ត និងអង្គការនានា ក្នុងការជួយគាំទ្រកុមារដែលបានចាកឆ្ងាយពីគ្រួសារទៅរស់នៅក្នុងមណ្ឌលថែទាំ ឱ្យសម្របខ្លួនមកនៅជាមួយគ្រួសារ និងសហគមន៍បានវិញ។ ទាំងនេះរួមមាន ការធ្វើការប៉ាន់ប្រមាណភាពរួចរាល់របស់គ្រុមគ្រួសារ ការត្រៀមគ្រួសារសម្រាប់ការវិលត្រឡប់ ត្រៀមធនធានដើម្បីឆ្លើយតបតាមតម្រូវការរបស់គ្រួសារ និងការធ្វើការចុះសួរសុខទុក្ខក្រុមគ្រួសារដែលកូនៗរបស់ពួកគាត់ទើបតែបានវិលត្រលប់ចូលក្នុងក្រុមគ្រួសារវិញ។

- ក្នុងករណីគ្រួសារងាយរងគ្រោះ គាំទ្រគ្រួសារនោះក្នុងការពង្រាងផែនការសេវាសង្គមដោយដាក់ពួកគាត់ក្នុងទំនាក់ទំនងដែលងាយរកសម្រាប់ការគាំទ្រសង្គម និងក្នុងកម្មវិធីផែនការមូលដ្ឋានផ្សេងៗទៀតដើម្បីធានាថា ការគាំទ្រពិតជាចាំបាច់ណាស់ក្នុងការការពារកុមារដោយមិនចាំបាច់ឱ្យពួកគេឃ្លាតឆ្ងាយពីក្រុមគ្រួសារឡើយ។
- ពង្រឹងបណ្តាញនានា ជាមួយសេវាគាំទ្រមូលដ្ឋាន រួមមាន អង្គការនានា វត្តអារាម និងបណ្តាញផ្សេងៗទៀត ដើម្បីឱ្យបណ្តាញទាំងនេះគាំទ្រក្រុមគ្រួសារកុមារមុនពេលមានការបែកបាក់កើតឡើង។
- តស៊ូមតិសម្រាប់មេភូមិដើម្បីលើកទឹកចិត្ត និងគាំទ្រមាតាបិតាក្នុងការថែទាំកូនៗរបស់គាត់នៅផ្ទះជាជាងបញ្ជូនកូនគាត់ទៅនៅក្នុងមណ្ឌលថែទាំ។
- ប្រើប្រាស់សៀវភៅអាស័យដ្ឋានសេវាកម្មជាតិសម្រាប់អ្នកដែលរងគ្រោះនៅពេលដែលស្វែងរកការគាំទ្រសម្រាប់គ្រួសារដែលងាយរងគ្រោះជម្រើសផ្សេងទៀតក្រៅពីមណ្ឌល ប្រើប្រាស់មូលនិធិសង្គមការពារកុមារដើម្បីគាំទ្រពីតម្រូវការរបស់កុមារងាយរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ។
- ប្រមូល និងវិភាគព័ត៌មានពីកុមារដែលងាយរងគ្រោះនៅក្នុងឃុំរបស់គាត់ និងធានាថាបញ្ហារបស់កុមារត្រូវយកមកឆ្លុះបញ្ចាំងនៅក្នុងផ្នែការអភិវឌ្ឍន៍ និងវិនិយោគឃុំ។

# ប្លង់មេរៀនទី៣

# ការប្រើប្រាស់ទិន្នន័យ ដើម្បីឱ្យមាន ឥទ្ធិពលទៅលើអ្នកដទៃ

| | |
|---|---|
| | **ប្លង់មេរៀនទី ៣**<br>**ការប្រើប្រាស់ទិន្នន័យ ដើម្បីឱ្យមានឥទ្ធិពលទៅលើអ្នកដទៃ** |
| **គោលបំណង** | នៅចុងបញ្ចប់នៃមេរៀននេះសិក្ខាកាមនឹងអាច ៖<br>• កំណត់បានបញ្ហាជាយុទ្ធសាស្ត្រដែលមានឥទ្ធិពលដល់ស្ត្រី និងកុមារងាយរងគ្រោះនៅក្នុងសហគមន៍របស់ពួកគេ។<br>• បង្កើតហេតុផលមួយ(បញ្ហា តម្រូវការ សំណើសកម្មភាព និងលទ្ធផលរំពឹងទុក) ដើម្បីស្វែងរកមតិគាំទ្រសម្រាប់ស្ត្រី និងកុមារដែលងាយរងគ្រោះ។<br>• ជ្រើសរើសសារដែលច្បាស់លាស់ និងមានប្រយោជន៍រួមទាំងរបាយការណ៍របស់ពួកគេសម្រាប់អ្នកពាក់ព័ន្ធផ្សេងៗ។<br>• កំណត់អ្នកពាក់ព័ន្ធសំខាន់ៗ ក្នុងការរៀបចំបណ្តាញជាមួយពួកគាត់ដើម្បីឱ្យមានឥទ្ធិពលក្នុងការប្រើប្រាស់ធនធានសម្រាប់ដោះស្រាយបញ្ហាដែលមានឥទ្ធិពលដល់ស្ត្រី និងកុមារងាយរងគ្រោះ។ |
| **ខ្លឹមសារមេរៀន** | • កំណត់បញ្ហាជាយុទ្ធសាស្ត្រស្វែងរកមតិគាំទ្រដោយ ផ្អែកលើភស្តុតាង ដើម្បីមានឥទ្ធិពលលើការសម្រេចចិត្តរបស់អ្នកផ្តល់ធនធានឬអ្នកពាក់ព័ន្ធផ្សេងៗ។ |
| **រយៈពេល** | ១ម៉ោង ៤៥នាទី |
| **សម្ភារៈ** | ក្រដាសពណ៌ ហ្វឺត ស្កុត កន្ត្រៃ ក្រដាសធំ កាំបិត និងការបញ្ចាំងស្លាយ<br>សៀវភៅណែនាំសម្រាប់សមាជិក គ.ក.ន.កផ្នែកទី ២ មេរៀនទី៣ ទំព័រ ៧១<br>ធនធានរៀនសូត្រ |
| **វិធីសាស្ត្រ** | ការបំផុសគំនិត ការពិភាក្សាក្រុមធំ បទបង្ហាញ ការពិភាក្សាក្រុមតូច<br>ការដើរទស្សនាតាមក្រុម និង ការសម្តែងតួ ការឆ្លុះបញ្ចាំង |

**ដំណើរការសម្របសម្រួល ÷**

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | សម្ភារៈ |
|---|---|---|
| ១០នាទី | **១. សេចក្តីផ្តើម**<br>• រំលឹកតួនាទីសំខាន់របស់ គ.ក.ន.ក ៖<br>– កំណត់រកគ្រួសារដែលងាយរងគ្រោះបំផុតនៅក្នុងឃុំ សង្កាត់<br>– វិភាគ និងរកមើលអ្វីដែលនៅបង្កប់ពីក្រោយបញ្ហា<br>– និងរៀបចំការផ្តល់សេវាសង្គម។<br>• តាមរយៈ ការវិភាគបញ្ហាដែលរួមចំណែកទៅដល់ភាពងាយរងគ្រោះរបស់ស្ត្រី និងកុមារ គ.ក.ន.ក អាចយល់ដឹងយ៉ាងច្បាស់ពីតម្រូវការ និងអាចស្នើសុំអន្តរាគមន៍ ដើម្បីស្វែងរកដំណោះស្រាយក្នុងមូលដ្ឋានចំពោះការព្រួយបារម្ភមួយចំនួន។ គ.ក.ន.ក ត្រូវធ្វើការតស៊ូមតិជំនួសមុខឱ្យស្ត្រី និងកុមារងាយរងគ្រោះទាំងឡាយ ដើម្បីគៀរគរធនធានពីអ្នកពាក់ព័ន្ធផ្សេងៗដែលអាចរួមជាកម្លាំងក្នុងការនាំឱ្យមានការផ្លាស់ប្តូរនៅមូលដ្ឋាន។ | |

<table>
<tr><th>រយៈពេល</th><th>ជំហាន និងវិធីសាស្ត្រ</th><th>សម្ភារៈ</th></tr>
<tr><td></td><td>នៅក្នុងមេរៀនផ្តោតពីរបៀបដែល គ.ក.ន.ក អាចទាញយកទិន្នន័យ ដើម្បីកំណត់ និងវិភាគពីបញ្ហាជាយុត្តិសាស្ត្រដែលមានឥទ្ធិពលដល់ស្ត្រី និងកុមាររងគ្រោះ។ មើលពីរបៀបដែលលោក លោកស្រីអាចរៀបចំគំនិត ទៅក្នុងហេតុផលដ៏សមរម្យមួយដើម្បីស្វែងរកមតិគាំទ្រសម្រាប់ស្ត្រី និងកុមាររងគ្រោះ និងដើម្បីមានឥទ្ធិពលក្នុងការបែងចែកធនធាន ពីអ្នកពាក់ព័ន្ធផ្សេងៗទៀត។<br>• បន្ទាប់មក អ្នកសម្របសម្រួលនឹងបង្ហាញពីគោលបំណងនៃមេរៀន។</td><td></td></tr>
<tr><td>៦០ នាទី</td><td>២. កំណត់បញ្ហាជាយុទ្ធសាស្ត្រ<br>ដើម្បីធ្វើការផ្តល់សេវាសង្គមប្រកបដោយសមធម៌ ទាមទារឱ្យមានការកំណត់នូវបញ្ហាជាយុទ្ធសាស្ត្រជាក់លាក់ ដើម្បីលោក លោកស្រី រៀបចំផែនការឆ្លើយតបនឹងតម្រូវការ និងកំណត់បាននូវធនធាន និងអ្នកពាក់ព័ន្ធក្នុងការគាំទ្រសកម្មភាពរបស់លោក លោកស្រី។<br><br>ការពិភាក្សាក្រុមតូច និងការពិពណ៌នាលទ្ធផលពិភាក្សា<br>• អ្នកសម្របសម្រួលចែកសិក្ខាកាមពិភាក្សាតាមឃុំនិងសួរខាងក្រោម ៖ (១០នាទី)<br>– តើក្នុងឃុំលោក លោកស្រីមានគ្រួសារណាខ្លះដែលងាយរងគ្រោះជាងគេ?<br>– ចាត់អាទិភាពគ្រួសារ ដែលត្រូវធ្វើអន្តរាគមន៍ចំនួន៣។<br>– ចម្លងអាទិភាពគ្រួសារដែលរងគ្រោះទាំងបីចូលក្នុងតារាងទី១<br>
<table>
<tr><th>អាទិភាពគ្រួសារងាយរងគ្រោះ និងបញ្ហាដែលជះឥទ្ធិពលដល់ស្ត្រី និងកុមារ</th><th>មូលហេតុ</th><th>ភស្តុតាង ឬអំណះអំណាង</th><th>តើត្រូវធ្វើអ្វីដើម្បីដោះស្រាយបញ្ហា?</th><th>តើមាននរណាខ្លះចូលរួមដោះស្រាយ? ដោយវិធីណា?</th></tr>
<tr><td></td><td></td><td></td><td></td><td></td></tr>
</table>
• បន្ទាប់ពីចាត់អាទិភាព សិក្ខាកាមពិភាក្សាបន្តនូវសំណួរខាងក្រោម (៣០នាទី) ៖<br>– ហេតុអ្វីបានជាលោក លោកស្រី ថាគ្រួសារទាំងនោះ ជាគ្រួសារដែលងាយរងគ្រោះជាងគេ? (អ្នកសម្របសម្រួលគួរផ្តោតសំខាន់ទៅលើបញ្ហាដែលដែលប៉ះពាល់ដល់ស្ត្រី និងកុមារ)<br>– តើមានអ្វីជាភស្តុតាង ឬសំអាង? (ព័ត៌មានពីណាខ្លះ?)<br>– តើលោក លោកស្រី ត្រូវធ្វើដូចម្តេចដើម្បីដោះស្រាយបញ្ហា និងឆ្លើយតបនឹងតម្រូវការចាំបាច់របស់គ្រួសារ ដែលងាយរងគ្រោះជាងគេនៅក្នុងឃុំរបស់លោក លោកស្រី?<br>– តើនរណាខ្លះអាចជួយគាំទ្រសកម្មភាពទាំងនោះ? នរណាខ្លះអាចអាចជួយ</td><td></td></tr>
</table>

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | សម្ភារៈ |
|---|---|---|
| | ឱ្យមានការផ្លាស់ប្តូរ?<br>– តើលោក លោកស្រី ត្រូវធ្វើដូចម្តេចដើម្បីប្រាស្រ័យទាក់ទងចំពោះពួកគាត់ និងកៀរគរការគាំទ្រពីពួកគាត់?<br>• សិក្ខាកាមអង្គុយពិភាក្សាតាមក្រុម ដែលមកពីឃុំជាមួយគ្នាពិភាក្សា និងបំពេញតារាងទី១។<br>• ក្រុមនីមួយៗ ពិពណ៌នាលទ្ធផលពិភាក្សានៅតាមជញ្ជាំង ដោយទុកសមាជិកម្នាក់ដើម្បីបង្ហាញ និងឆ្លើយតបនូវសំណួរផ្សេងៗរបស់អ្នកដើរទស្សនា។ (២០នាទី)<br><br>**កំណត់ចំណាំសម្រាប់អ្នកសម្របសម្រួល**<br>• ចំណុចសំខាន់គឺផ្តោតជាដំបូងលើការប្រើប្រាស់ទិន្នន័យ ដើម្បីកំណត់គ្រួសារងាយរងគ្រោះ<br>• បង្កើតហេតុផលជាក់លាក់ដែលអាចប្រើសម្រាប់ស្វែងរកមតិគាំទ្រ( ដើម្បីមានឥទ្ធិពលទៅអ្នកដទៃ ) និង កៀរគរធនធាន។<br>• វិភាគរកហេតុផលដែលបង្កប់ក្នុងបញ្ហា និងផលប៉ះពាល់មុននឹងធ្វើសំណើអំពីសកម្មភាពដំណោះស្រាយ ( ច្បាស់លាស់ )។<br>• ការសំខាន់បំផុតនោះគឺដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហានេះ និងកៀងគរការគាំទ្រសម្រាប់សកម្មភាព និងដំណោះស្រាយ។<br>• តើមានទិន្នន័យអ្វីខ្លះ អាចឱ្យលោក លោកស្រី កំណត់ពីគ្រួសារ ដែលងាយរងគ្រោះបំផុត ?<br>• តើលោក លោកស្រី មានដែលប្រើទិន្នន័យពី ផែនទីសេវាសង្គមតារាងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ប្រព័ន្ធព័ត៌មានគ្រប់គ្រាងការអប់រំ ប្រព័ន្ធព័ត៌មានដើម្បីធ្វើការកំណត់ពីបញ្ហាអាទិភាពដែរឬទេ ? | |
| ៣០នាទី | **៣. ការតស៊ូមតិដើម្បីសេវាសង្គមប្រកបដោយសមធម៌**<br>លោក លោកស្រីបានពិភាក្សារួចហើយនូវចំណុចសំខាន់ៗខាងលើ។ ដើម្បីផ្តល់សេវាសង្គមប្រកបដោយសមធម៌ លោក លោកស្រីត្រូវការនូវធនធាន និងកំណត់បាននូវអ្នកពាក់ព័ន្ធ ដូចជា អ្នកផ្តល់ធនធាន អ្នកជួយផ្នែកបច្ចេកទេស។ ដូច្នេះត្រូវរកវិធីសាស្ត្រ និងមធ្យោបាយនានា ដើម្បីស្វែងរកការគាំទ្រ(ការតស៊ូមតិ)។<br><br>**សំណួរបំផុសគំនិត និងបទបង្ហាញ**<br>• ដូចម្តេចដែលហៅថាការទាក់ទាញមតិគាំទ្រ ឬការតស៊ូមតិ?<br>• តើដើម្បីរៀបចំសកម្មភាពតស៊ូមតិ ឬទាក់ទាញមតិគាំទ្របាន យើងត្រូវធ្វើអ្វីខ្លះ?<br>• បទបង្ហាញស្តីពីមូលដ្ឋានគ្រឹះនៃការតស៊ូមតិ និងវដ្តនៃការតស៊ូមតិ | |

| រយៈពេល | ជំហាន និងវិធីសាស្ត្រ | សម្ភារៈ |
|---|---|---|
| | កំណត់ចំណាំ ៖<br>• ចំពោះ គ.ក.ន.ក ការតស៊ូមតិ គឺជាឧបករណ៍ដើម្បីធានាថាស្ត្រី ឬកុមារ និងជនងាយរងគ្រោះនៅក្នុងសហគមន៍ ដែលជាទូទៅ គឺជាអ្នកដែលបាត់ប្រៀបមានមធ្យោបាយយល់ដឹងអំពីអ្វីមួយ ឬទទួលបាននូវឱកាសក្នុងការទទួលបានសេវាសាធារណៈនានា។ | |
| ១០ នាទី | **៤. សេចក្តីសន្និដ្ឋាន**<br>• អ្នកសម្របសម្រួលធ្វើការបូកសរុបមេរៀន | |

## តារាងទី១ ÷ កំណត់គ្រួសារងាយរងគ្រោះ បញ្ហា តម្រូវការ និងដំណោះស្រាយ

| គ្រួសារងាយរងគ្រោះ និងបញ្ហា ដែលជះឥទ្ធិពលដល់ស្ត្រី និងកុមារ | មូលហេតុជាមូលដ្ឋាន ដែលរួមចំណែកដល់បញ្ហា | តើត្រូវធ្វើអ្វីដើម្បី ដោះស្រាយបញ្ហា? | តើមាននរណាទៀតដែលត្រូវចូលរួម ដោះស្រាយ? ដោយវិធីណា? |
| --- | --- | --- | --- |
| | | | |

# ប្លង់មេរៀន

# ការសន្និដ្ឋានបញ្ចប់វគ្គបណ្តុះបណ្តាល

# ប្លង់មេរៀន
# ការសន្និដ្ឋានបញ្ចប់វគ្គបណ្ដុះបណ្ដាល

| | |
|---|---|
| **គោលបំណង** | នៅចុងបញ្ចប់នៃមេរៀននេះសិក្ខាកាមនឹងអាច ៖<br>• រំលឹកឡើងវិញ និងទាញយកចំណុចរៀនសូត្រវគ្គបណ្ដុះបណ្ដាល<br>• វាយតម្លៃបញ្ចប់វគ្គ |
| **ខ្លឹមសារមេរៀន** | • ចំណុចសំខាន់ៗនៃគ្រប់មេរៀន<br>• វាយតម្លៃបញ្ចប់វគ្គ |
| **រយៈពេល** | ៦០នាទី |
| **សម្ភារៈ** | • ក្រដាសផ្ទាំងធំ ក្រដាសពណ៌ ហ្វឺត ស្កុត និងទម្រង់វាយតម្លៃបញ្ចប់វគ្គ |
| **វិធីសាស្ត្រ** | • ការរំលឹកមេរៀន និងការបំពេញព័ត៌មានវាយតម្លៃ |
| **សកម្មភាពសម្របសម្រួលមេរៀន** | |

| **រយៈពេល** | **ជំហាន និងវិធីសាស្ត្រ** | **សម្ភារៈ** |
|---|---|---|
| ០៥នាទី | **១. បង្ហាញសេចក្ដីផ្ដើម និងគោលបំណងមេរៀន**<br>• **សេចក្ដីផ្ដើម** ៖ ក្នុងផ្នែកនេះ យើងពិនិត្យអំពីលទ្ធផលនៃការសិក្សាឡើង វិញ ដោយធ្វើការរំលឹកមេរៀនទាំងមូលឡើងវិញដើម្បីការបង្កើនការចងចាំ រួច ហើយយើងនឹងវាយតម្លៃវគ្គ តាមរយៈការស្វ័យវាយតម្លៃ។<br>• **គោលបំណងមេរៀន** ៖ បង្ហាញគោលបំណងមេរៀនខាងលើ។ | |
| ៣០នាទី | **២. ការងារក្រុមអំពីការរំលឹកមេរៀន**<br>• អ្នកសម្របសម្រួលចែកសិក្ខាកាមជា៤ក្រុម (ក្រុមដដែល)<br>• ក្រុមនីមួយៗ កំណត់អ្វីដែលចេះច្បាស់ជាងគេ(មានទំនុកចិត្ត)មួយចំណុច និងការលំបាក(គ្មានទំនុកចិត្ត)មួយចំណុចនៃវគ្គបណ្ដុះបណ្ដាលទាំងមូល<br>• ក្រុមនីមួយៗ បង្ហាញការលំបាក( ចំណុចគ្មានទំនុកចិត្ត)ដល់ក្រុមធំ)<br>• អ្នកសម្របសម្រួលឱ្យក្រុមដទៃទៀតជួយបកស្រាយ ផ្អែកលើអ្វីដែល ក្រុមមានទំនុកចិត្ត<br>• អ្នកសម្របសម្រួលជួយបំភ្លឺបន្ថែម បើក្រុមមិនអាចឆ្លើយបាន<br>• អ្នកសម្របសម្រួលដឹកនាំអនុវត្តដូចនេះរហូតដល់អស់ក្រុម។ | |
| ១៥នាទី | **៤. ការវាយតម្លៃបញ្ចប់វគ្គបណ្ដុះបណ្ដាល**<br>• អ្នកសម្របសម្រួលចែក និងពន្យល់ទម្រង់វាយតម្លៃ អ្នកចូលរួម បំពេញទម្រង់វាយតម្លៃបញ្ចប់វគ្គរៀងខ្លួន | |
| ១០នាទី | **៥. សេចក្ដីសន្និដ្ឋាន**<br>• អញ្ជើញអ្នកចូលរួមមួយចំនួន បង្ហាញចំណាប់អារម្មណ៍ចំពោះវគ្គ<br>• ពិធីបិទវគ្គ | |

# ទម្រង់វាយតម្លៃបញ្ចប់វគ្គបណ្ដុះបណ្ដាល

១. តើវគ្គបណ្ដុះបណ្ដាលនេះឆ្លើយតបនឹងគោលបំណងដែលបានកំណត់កម្រិតណា? សូមគូសសញ្ញា ✓ ក្នុងប្រអប់ខាងក្រោម ៖

☐ មិនឆ្លើយតបសោះ   ☐ បានបន្តិចបន្តួច   ☐ បានគួរសម   ☐ បានច្រើន   ☐ ឆ្លើយតបទាំងស្រុង

២. តើមេរៀន ឬផ្នែកណាដែលសំខាន់បំផុតសម្រាប់អ្នក?

..............................................................................................................

..............................................................................................................

..............................................................................................................

៣. តើមេរៀន ឬផ្នែកណាដែលសំខាន់តិចតួចសម្រាប់អ្នក?

..............................................................................................................

..............................................................................................................

..............................................................................................................

៤. សូមគូសសញ្ញា✓ នៅក្នុងតារាងខាងក្រោមនូវកម្រិតយល់ដឹងរបស់អ្នកពីវគ្គនេះ ៖

| ផ្នែក | ខ្សោយណាស់ | ខ្សោយ | មធ្យម | ល្អ | ល្អណាស់ |
|---|---|---|---|---|---|
| ប្រធានបទ ឬខ្លឹមសារមេរៀន | | | | | |
| ដំណើរការ ឬវិធីសាស្ត្រ ឬឧបករណ៍ | | | | | |
| អ្នកសម្របសម្រួល | | | | | |
| ទីកន្លែង | | | | | |

៥. សូមបង្ហាញពីការរីកចម្រើននៃចំណេះដឹងរបស់អ្នក ដោយគូសរង្វង់មូលលើលេខនៃខ្នាតដូចខាងក្រោម ៖

**បញ្ជាក់** ៖ ១ = គ្មានការរីកចម្រើនសោះ   ១០ = រីកចម្រើនទាំងស្រុង

ក). មុនពេលចូលវគ្គ   ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០

ខ). ក្រោយពីបញ្ចប់វគ្គ   ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០

៦. តើចំណុចណាខ្លះ ដែលអ្នកពេញចិត្តបំផុតក្នុងវគ្គបណ្ដុះបណ្ដាលនេះ?

..............................................................................................................

..............................................................................................................

..............................................................................................................

៧. សំណូមពរ និងយោបល់ផ្សេងៗ

..............................................................................................................

..............................................................................................................